# ខទីអធិប្បាយ
# សាសនសុភាសិត

ភាគ ១

ឧបត្ថម្ភការសិក្សាធម្មវិន័យថ្នាក់ត្រី

រក្សាសិទ្ធិ

ព.ស. ២៤៩៦ — គ.ស.១៩៥៣

ញ្ញាតព្រះរាជរដ្ឋាភិបាល លេខ ១៦៨ ចុះថ្ងៃ១២ ខែសីហា គ.ស.១៩៥៣

ប.135
294.3
២០១០០

www.elibraryofcambodia.org

# ទដីអធិប្បាយ
# សាសនសុភាសិត

ភាគ ១

ឧបត្ថម្ភការសិក្សាធម្មវិន័យថ្នាក់ត្រី

សិន ហ៊ាន

www.elibraryofcambodia.org

ក្រុមពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ

រៀបរៀង

រក្សាសិទ្ធិ

ព. ស. ២៤៩៦ — គ. ស. ១៩៥៣

www.elibraryofcambodia.org

# បញ្ជីរឿង

ទំព័រ


លំនាំដើម ១

វិធីតែងសេចក្ដីសុភាសិត ១៩

១. អប្បមាទ – អប្បមាទោ អមតំ បទំ ៣០

២. កម្ម – កម្មុនា វត្តតី លោកោ ៣២

៣- ចិត្ត – តេលបត្តំ យថា បរិហារេយ្យ

– ឯវំ សចិត្តមនុរក្ខេ សតិមោ ៣៥

៤. ក្រោធ – កោធជាតោ បរាភវោ ៣៨

៥- ភរិយា – ភត្តុ [illegible] ៤១

៦- បញ្ញា – បញ្ញាយត្ថំ វិបស្សតិ ៤៤

៧- ប្រមាទ – បមាទោ មច្ចុនោ បទំ ៤៦

៨- យាចនា – ទេស្សោ ច ហោតិ អតិយាចនាយ ៤៨

៩- វាចា – មោក្ខោ កល្យាណិយា សាធុ ៥០

១០-វីរិយៈ – វាយមេថេវ បុរិសោ យាវ

– អត្ថស្ស និប្បទា ៤៣

១១-សទ្ធា – សទ្ធា សាធុ បតិដ្ឋិតា ៥៦

១២-សីល – សីលំ លោកេ អនុត្តរំ ៥៩


www.elibraryofcambodia.org

| | | | |
|---|---|---|---|
| | | | ទំព័រ |
| ១៣- ពាក្យស័ត្យ | – | សច្ចមនុរក្ខេយ្យ | ៦២ |
| ១៤- សន្តោស | – | យំ លទ្ធំ តេន តុដ្ឋព្វំ | ៦៥ |
| ១៥- សាមគ្គី | – | សព្វេសំ សង្ឃភូតានំ | |
| | – | សាមគ្គី វុឌ្ឍិសាធិកា | ៦៨ |
| ១៦- បកិណ្ណកៈ | – | រូបំ ជីរតិ មច្ចានំ នាមគោត្តំ ន ជីរតិ | ៧១ |
| ១៧- កតញ្ញូកតវេទី | – | និមិត្តំ សាធុរូបានំ កតញ្ញូកតវេទិតា | ៧៤ |
| ១៨- កាម | – | ន កហាបណវស្សេន តិត្តិ កាមេសុ វិជ្ជតិ | ៧៨ |
| ១៩- មលៈ | – | អសជ្ឈាយមលា មន្តា | ៨១ |
| ២០- សន្តិ | – | នត្ថិ សន្តិបរំ សុខំ | ៨៣ |
| ២១- មិត្រ | – | មាតា មិត្តំ សកេ ឃរេ | ៨៦ |
| ២២- វិមុត្តិ | – | អនុបាទា វិមុច្ចន្តិ | ៩១ |

www.elibraryofcambodia.org

# មុននឹងអានសៀវភៅនេះ

## សូមកែតម្រូវដូចខាងក្រោមនេះសិន

| ទំព័រ | បន្ទាត់ | ពាក្យថា: | កែជា |
|---|---|---|---|
| ២ | ១៦ | ច្រឹន | ច្រើន |
| ១៣ | ១៤ | វិសែស | វិសេស |
| ១៥ | ១៦ | នាះ | នោះ |
| ១៧ | ១ | ឃីញ | ឃើញ |
| ២៦ | ៦ | ផែល | ដែល |
| ២៦ | ១១ | សំគាស់ | សំគាល់ |
| ២៦ | ១៨ | លោកុត្តធម៌ | លោកុត្តរធម៌ |
| ២៨ | ១ | ដើមរី | ដើម្បី |
| ៣៧ | ៤ | គឹ | គឺ |
| ៣៧ | ១១ | េ ប | ទើប |
| ៤៣ | ១ | កំយក | កុំយក |
| ៤៤ | ១៨ | សុតាមយបញ្ញា | សុតមយបញ្ញា |
| ៥៣ | ១១ | វិរិយៈ | វីរិយៈ |
| ៥៤ | ១០ | ជិវិត | ជីវិត |
| ៥៥ | ១៤ | ដូ.ច្នេះ ៗ | ដូច្នេះ ៗ |

www.elibraryofcambodia.org

| ទំព័រ | បន្ទាត់ | ពាក្យថា: | កែជា |
| --- | --- | --- | --- |
| ៥៨ | ១៤ | រាជគ្រិះ | រាជគ្រឹះ |
| ៦១ | ១៤ | ក្នុងណាកនេះ | ក្នុងលោកនេះ |
| ៦១ | ១៥ | គុណសេស | គុណវិសេស |
| ៦៥ | ១៧ | មិននមា | មិនមាន |
| ៨៨ | ១៤ | មាឲ្យន | ឲ្យមាន |
| ៨៩ | ៧ | ក្តុង | ក្នុង |
| ៩១ | ៣ | ទើបតាម | ទើបសម |
| ៩៣ | ៦ | របក់ទៅ | បក់ទៅ |

www.elibraryofcambodia.org

# អារម្ភកថា

សៀវភៅ "វិធីអធិប្បាយសាសនសុភាសិត" សម្រាប់ធម្មវិន័យថ្នាក់ត្រី ឬធម្មសិក្សាថ្នាក់ត្រីនេះ កើតឡើងដោយខ្ញុំយល់ឃើញថា ក្នុងសម័យនេះ កម្ពុជរដ្ឋយើង ការរៀនសូត្រខាងធម្មវិន័យកាន់តែចំរើនច្រើនឡើងជាលំដាប់ ហើយការតែងអធិប្បាយសាសនសុភាសិតនេះទៀត ក៏រាប់បញ្ចូលថាជាអង្គការមួយដ៏លំបាករបស់អ្នកសិក្សាធម្មវិន័យដែរ តែមិនសូវមានបែបបទសម្រាប់ជាជំនួយដល់ការប្រកបតែងប៉ុន្មាននៅឡើយ ៗ ទើបខ្ញុំខំរំលែកឱកាសប្រមែប្រមូល ធ្វើជាលំនាំដើមនៃវិធីតែងសេចក្ដីសុភាសិតឡើង ព្រមទាំងបានតែងអធិប្បាយ[illegible]ផង តាមលំអានដែលបានសិក្សាមកខ្លះ តាមក្បួនច្បាប់ជាភាសាសៀមខ្លះ ដោយមានបំណងចង់សម្រាលឲ្យអ្នកសិក្សាវិជ្ជាផ្នែកនេះបានធូរចិត្ត កុំឲ្យមានការលំបាកខ្លាំងពេក ៗ កាលខ្ញុំប្រមែប្រមូលរៀបរៀងរួចហើយ ក៏បានយកទៅប្រគេនព្រះតេជព្រះគុណសិរីសោភ័ណ កិម-ទូរ, ព្រះតេជព្រះគុណញាណវីរិយៈ វ៉ាន់-សាឌុម, ព្រះតេជព្រះគុណ ធម្មមុនី ហ៊ុំ-ជា ក្រុមជំនុំព្រះត្រៃបិដក-គណៈកម្មការធម្មវិន័យ នឹងឃុនបណ្ណានុរក្ស ប៊ូ-ប៉ូ, ឃុនសុន្ទរមេធី ញូង-សឿង ក្រុមពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ, សូមឲ្យជួយពិនិត្យកែសេចក្ដីខ្លះថែមទៀត ៗ លុះលោកទាំងនោះបានជួយពិនិត្យរួចហើយ ក៏យល់ឃើញថាជាច្បាប់ ១ មានប្រយោជន៍ដ៏ល្អនឹងជាទីសង្ឃឹមកក់ក្ដៅរបស់

www.elibraryofcambodia.org

អ្នកសិក្សាវិជ្ជាប្រភេទនេះបានយ៉ាងពិតប្រាកដ ៗ

ដោយអំណាចនៃសេចក្ដីខ្វល់ខ្វាយ ព្រមដោយចេតនារបស់ខ្ញុំ សូមប្រយោជន៍ដែលមានក្នុងសៀវភៅនេះ ចូរសម្រេចផលដល់អ្នកសិក្សាវិជ្ជាប្រភេទនេះសមតាមប្រាថ្នាគ្រប់ប្រការចុះ ៗ.

ថ្ងៃចន្ទ ទី ១០ សីហា { ព.ស. ២៤៩៦ / គ.ស. ១៩៥៣

ស៊ិន-ហ៊ែង

www.elibraryofcambodia.org

# លំនាំដើម

វិជ្ជារៀបរៀងសេចក្ដីសុភាសិត ជាចំណែកអង្គការ ១ របស់អ្នកសិក្សា ម្មវិន័យ ៗ អ្នកសិក្សាជាច្រើនមានសេចក្ដីលំបាកក្នុងមុខការនេះ តែសេចក្ដី ំបាកចំពោះប្រការណាមួយនោះ ស្រេចហើយតែអ្នកសិក្សាម្នាក់ៗ មិន មនដូចគ្នាទេ គឺខ្លះលំបាកត្រង់នេះ, ខ្លះត្រង់នោះ ប៉ុន្តែបើសរុបសេចក្ដី ឲ្យខ្លីទៅ អ្នកសិក្សាច្រើនបញ្ចេញរកបាថាលំបាកដូចតទៅនេះ ៖

១ – មិនដឹងជានឹងប្រើពាក្យផ្ដើមសុភាសិតយ៉ាងដូចម្ដេច;

២ – មិនចូលចិត្តគោលបំណងរបស់សុភាសិត;

៣ – មិនដឹងជានឹងលើកយកធម៌អ្វីមកបរិយាយ;

៤ – មិនដឹងជានឹងលើកហេតុផលបែបណាមកបរិយាយជាមុន;

www.elibraryofcambodia.org

៥ – មិនដឹងជានឹងតភ្ជាប់សុភាសិតយ៉ាងដូចម្ដេច;

៦ – មិនដឹងជានឹងបញ្ចប់សុភាសិតយ៉ាងដូចម្ដេច ៗ

គោលកំណត់ទាំង ៦ យ៉ាងនេះ ជាការលំបាករបស់អ្នកសិក្សាពន់ពេក តែកាលបើព្យាយាមអានពាក្យអធិប្បាយខាងក្រោមនេះឲ្យរឿយ ៗ ហើយ ង់នឹងអាចចូលចិត្តបានខ្លះពុំខាន តាមសមគួរដល់សតិបញ្ញានៃអ្នកសិក្សា រៀង ៗ ខ្លួន ៗ

ប្រការ ១. ដែលថា "មិនដឹងជានឹងប្រើពាក្យផ្ដើមសុភាសិតយ៉ាង ដូចម្ដេច" នោះ គប្បីប្រាប់ដូចតទៅនេះ ៖

ក) កាលបើឃើញសុភាសិតដែលតាំងឡើង (សុភាសិតគឺគោល

សុភាសិតដែលលោកបំប្រួញសេចក្ដីឬគោលធម៌នោះឯង) គប្បីពិចារណាមើលថាជាសុភាសិតរបស់អ្នកណា ព្រោះភាសិតនោះលោកចែកចេញជា៤ប្រភេទគឺ: ១-ពុទ្ធភាសិត ពាក្យដែលព្រះពុទ្ធត្រាស់, ២- សាវកភាសិត ពាក្យដែលសាវកពោល, ៣-ទេវតាភាសិត ពាក្យដែលទេវតាពោល, -៤ ឥសិភាសិត ពាក្យដែលឥសីពោល ។ កាលបើបានដឹងថាជាភាសិតរបស់អ្នកណាពិតប្រាកដហើយ (ការកំណត់ដឹងបាននោះមកពីអ្នកសិក្សាបានអានសៀវភៅច្រើន) ដូចជាពុទ្ធភាសិតជាដើម យើងត្រូវដឹងឲ្យជ្រៅតទៅទៀតថា: "ទ្រង់ត្រាស់ចំពោះអ្នកណា ? នៅទីណា? ដើម្បីអ្វី?" ដើម្បី[illegible] www.elibraryofcambodia.org [illegible]ទ់ឡើង ហើយគប្បីប្រើពាក្យផ្ដើមដូច្នេះ "ក្នុងព្រះពុទ្ធភាសិតនេះឬព្រះសាស្ដាទ្រង់ត្រាស់ភាសិតនេះចំពោះអ្នកនោះអ្នកនេះ" ហើយទើបបរិយាយរឿងដោយសេចក្ដីសង្ខេប ៗ នៃឧបត្តិហេតុល្មមជាសេចក្ដីណែនាំ ពន្លឹកអត្ថាធិប្បាយលើកធម៌ឡើងធៀបទឹងប្រើជាពាក្យកណ្ដាលៗថា "ភាសិត, សុភាសិត, ធម្មភាសិត, ឬសាសនសុភាសិត" ក៏បាន ។ បើជាសាវកភាសិតទឹងផ្ដើមឡើងថា "សាវកភាសិត (ចេញឈ្មោះផងក៏បាន) ឬសុភាសិត, ធម្មភាសិត" បានទាំងអស់ ។ ទេវតាភាសិតទឹងឥសិភាសិត នោះច្រើនផ្ដើមឡើងដោយពាក្យថា "សុភាសិត, ធម្មភាសិតឬសាសនសុភាសិត" ។

១) កាលបើមិនបានដឹងប្រាកដថាជាភាសិតរបស់អ្នកណាទេ ត្រូវប្រើ

ពាក្យផ្ដើមជាកណ្ដាល ៗ ដូចពាក្យថា "កុងភាសិតនេះ, កុងសុភាសិតនេះ" ឬប្រើពាក្យថា "សុភាសិតបទនេះ, ធម្មភាសិតបទនេះ" ដូច្នេះជាដើម ។

គ) ភាសិតរបស់អ្នកណាក៏ដោយ នឹងផ្ដើមឡើងត្រង់ៗលើកធម៌កុងភាសិតនោះមកសំដែងតែម្ដងក៏បាន ដូចភាសិត "សតិ" គប្បីផ្ដើមឡើងថា "សតិ" ប្រែថា "សេចក្ដីរឭកបាន ឬសេចក្ដីចាំបាន" ហើយទើបអធិប្បាយតទៅ ឬភាសិតដែលជាពួកធម៌ដទៃ ក៏លើកយកធម៌ពួកនោះមកអធិប្បាយតែម្ដង (គប្បីចូលចិត្តចំពោះពាក្យផ្ដើមនេះ ជួនកាលអាចផ្លាស់ប្ដូរទៅផ្សេងៗទៀតក៏បាន តាមតែការសង្កត់ធ្ងន់នាញនឹងសេចក្ដីយល់ត្រូវរបស់អ្នកសិក្សារៀងៗខ្លួន តែកុំឲ្យខុសចាកគោលដើម) ។

www.elibraryofcambodia.org

ប្រការ ២- គោលបំណងរបស់សុភាសិត ជាខមួយកម្រិតទំពក; អ្នកសិក្សាអាចពង្រីកសេចក្ដីឲ្យត្រូវតាមគោលទៅបាន ត្រូវអាស្រ័យការពិចារណាមើលឲ្យបានហ្មត់ចត់ជាមុន ដូចសុភាសិតខ្លះ ស៊ីសេចក្ដីខាងផ្លូវលោកមិនបានប៉ះដល់ផ្លូវធម៌ឡើយ ក៏ត្រូវផ្ទៃលកអធិប្បាយផ្លូវលោកឲ្យច្រើនព្រមទាំងឧទាហរណ៍ផង តែនឹងបៀសវាងគោលធម៌សោះក៏មិនបានគឺគោងទាញយកគោលធម៌មកបញ្ចូលផង ឬសុភាសិតដែលស៊ីសេចក្ដីខាងផ្លូវធម៌ ក៏គប្បីព្យាយាមអធិប្បាយគោលធម៌ឲ្យឃើញជាក់ច្បាស់យ៉ាងទូលាយ ព្រមទាំងហេតុផល តែនឹងចោលផ្លូវលោកចេញស្រឡះក៏មិន

បាន ព្រោះផ្លូវលោកនិងផ្លូវធម៌ តែងមានជាគូទាក់ទងជាមួយគ្នា កាលណាបើយើងអធិប្បាយចំពោះតែម្ខាងៗ នឹងនាំឲ្យខូចអត្ថរសនៃសុភាសិតនោះៗទៅវិញក៏សឹងមាន គឺថាសុភាសិតដែលនឹងតែងឲ្យល្អទៅបាននោះ ទោះជាសុភាសិតបែបណាក៏ដោយ ត្រូវមានទាំងផ្លូវលោកផ្លូវធម៌នឹងមានឧទាហរណ៍ប្រកប ហើយត្រូវប្រើពាក្យឲ្យពីរោះពីសារផង ។ ការរាយសេចក្ដីសុភាសិតនេះ ក៏ជាការកម្រពន់ពេក; អ្នកសិក្សាត្រូវពិចារណាមើលឲ្យហ្មត់ចត់ វិនិច្ឆ័យឲ្យដាច់ខាត បើរាយសេចក្ដីសុភាសិតខុស ក៏ប្រើការមិនបាន ព្រោះខនេះជាការលំបាកយ៉ាងក្រៃលែង ។

www.elibraryofcambodia.org

ប្រការ ៣ - ធម៌ដែលលោកយកមកបរិយាយក្នុងសុភាសិតនោះបើសុភាសិតសំដៅធម៌ត្រង់ៗ ដូចជាសតិ បញ្ញាជាដើមនោះ ក៏មិនជាការលំបាកប៉ុន្មានទេ គឺត្រូវលើកធម៌នោះៗ មកអធិប្បាយឲ្យឃើញជាក់ច្បាស់ទាំងហេតុផលតែម្ដងទៅ; តែឯខដែលកម្របំផុតគឺបកិណ្ណកសុភាសិត (សុភាសិតពាយរង) ដូចសុភាសិតថា "ន សិយា លោកវឌ្ឍនោ, កុំធ្វើខ្លួនឲ្យជាមនុស្សបង្កៀតលោក (១)" ដូច្នេះជាដើម; កាលយើងឃើញសុភាសិតរបៀបនេះហើយ ក៏តែងងឿងឆ្ងល់មិនដឹងថានឹងលើកយកធម៌ខណាមកបរិយាយ; តែទោះបីដូច្នោះ ក៏មិនជាការផុតវិស័យរបស់បញ្ញាទេ ត្រូវពិចារណាមើលថា អាការដូចម្ដេចជាអាការរបស់មនុស្ស

---

១ - កុំធ្វើខ្លួនឲ្យជាមនុស្សបំរើនក្នុងលោក ក៏បាន ។

បង្អៀតលោក អាការដែលជាមនុស្សល្បួចប្លន់បោកគោងកាចជាដើម ជាអាការរបស់មនុស្សបង្អៀតលោកឬ? ឬមនុស្សដែលមិនធ្វើសេចក្ដីល្អសោះ មានតែធ្វើអ្នកដទៃឲ្យក្ដៅក្រហាយតែម្យ៉ាងនោះឯង ជាអាការរបស់មនុស្សបង្អៀតលោក? កាលបើយើងបានដឹងថាអាការទាំងនេះជាអាការរបស់មនុស្សបង្អៀតលោកហើយ ព្រមទាំងបាននឹកធៀបចូលទៅរកផ្លូវធម៌បានហើយក៏គប្បីចាប់គោលធម៌ឡើងបរិយាយតទៅ ដូចយ៉ាងក្នុងសុភាសិតនេះ ត្រូវលើកទុច្ចរិតទាំង៣ឡើងបរិយាយថា អាការដែលធ្វើទុច្ចរិតនោះ ជាអាការរបស់មនុស្សបង្អៀតលោក ។ នេះឈ្មោះថាគេបានគោលធម៌អធិប្បាយហើយ តែត្រូវអធិប្បាយឲ្យបំ[illegible] កុំឲ្យល្អៀងពីអាការរបស់មនុស្សបង្អៀតលោក ។ សូម្បីសុភាសិតដទៃៗក៏គប្បីធៀបដោយន័យនេះដែរ គប្បីព្យាយាមអធិប្បាយសុភាសិតដោយអាងគោលធម៌ លើកយកធម៌ទៅដាក់បំពោះរូបបុគ្គល ទាញហេតុផលនិងឧទាហរណ៍ឲ្យសមនឹងរូបសុភាសិត នេះទុកជាប្រើបានការមួយផ្នែក ។

ប្រការ ៤- ហេតុនិងផលរបស់សុភាសិត ជាខសំខាន់បំផុត, សុភាសិតខ្លះសំដែងទាំងហេតុទាំងផល សុភាសិតខ្លះសំដែងតែហេតុមិនសំដែងផល ឬសុភាសិតខ្លះនិយាយតែផលមិននិយាយដល់ហេតុ ; តែទោះដូចម្ដេចក្ដី ការតែងសុភាសិតត្រូវនិយាយទាំងហេតុទាំងផល ។ ក្នុងខនេះ យើងនឹង

www.elibraryofcambodia.org

លើកហេតុឬផលឡើងសំដែងមុន ក៏ស្រេចតែលំនាំសុភាសិតនោះ ដូចមានគោលកំណត់តទៅនេះ ៖

ក) សុភាសិតមានទាំងហេតុទាំងផល នឹងអធិប្បាយហេតុឬផលមុនក៏បាន ស្រេចតែឃើញថាគួរ កាលអធិប្បាយហេតុក៏ព្យាយាមបង្អុលបង្ហាញផលរបស់ហេតុនោះៗ ឬសំដែងផលក៏ត្រូវព្យាយាមស្រាវជ្រាវរកហេតុមកបង្អុលបង្ហាញឲ្យបានសេចក្ដីច្បាស់លាស់កុំឲ្យនិយាយតែមួយហើយបដិសេធមួយហោលនោះឡើយ ។

ខ) សុភាសិតមានតែហេតុមិនមានផល ត្រូវលើកផលសំដែងជាមុន ផលនោះនឹងជាគុណឬទោសក៏ដោយ ត្រូវអធិប្បាយឲ្យឃើញជាក់ច្បាស់ ផលទីបំផុតក៏ត្រូវបង្អុលបង្ហាញថា ផលនោះកើតអំពីហេតុ ហើយអធិប្បាយហេតុឲ្យជាក់ច្បាស់ថាធ្វើដូចម្ដេចបានជាបានទទួលផលដូច្នោះ ៗ រួចហើយសឹមបញ្ចប់សុភាសិតជាខាងក្រោយ, យ៉ាងនេះទើបបានល្អ ។

គ) សុភាសិតមានតែផលមិនមានហេតុ ក៏គប្បីតែងដូចគ្នានឹងសុភាសិតដែលមានតែហេតុមិនមានផល គឺព្យាយាមអធិប្បាយបង្អុលបង្ហាញហេតុ ពង្រីកហេតុឲ្យឃើញជាក់ច្បាស់ជាមុន ហើយទើបបង្អោនទៅសំដែងផលថា ផលបែបនេះកើតមានឡើងព្រោះហេតុបែបនោះៗ ។ ហេតុផលនោះគឺអ្វី? ខនេះបើមិនចាំបាច់អធិប្បាយគន្លឹះនេះក៏បានព្រោះមិនមែនជាខលំបាកប៉ុន្មានទេ តែដើម្បីធ្វើឲ្យមានទំនងសេចក្ដីហូរហែ

www.elibraryofcambodia.org

ឬដើមទៀតអ្នកសិក្សាខ្លះ ដែលមិនទាន់ដឹងច្បាស់ដល់បានដឹងច្បាស់ឡើង ទើបខ្ញុំសូមពន្យល់ដោយសង្ខេបដូចតទៅនេះ ៖

ហេតុ គឺធម្មជាតិជាសមុដ្ឋានរបស់វត្ថុទាំងឡាយ ជាកន្លែងកើតឬជាមេនាំឲ្យកើតជាដូច្នោះ,ដូច្នេះ, ផលគឺធម្មជាតិឬវត្ថុដែលបញ្ចេញផ្លែកើតមកអំពីហេតុ ដូចអកុសលជាហេតុឲ្យកើតទុក្ខ កុសលជាហេតុឲ្យកើតសុខ, អកុសល កុសលឈ្មោះថាជាហេតុ ព្រោះជាមេនាំឲ្យកើត, ទុក្ខសុខជាផល ព្រោះជារបស់ដែលបញ្ចេញមកអំពីអកុសលនិងកុសលដែលជាហេតុនោះឯង អធិប្បាយមកត្រឹមប៉ុណ្ណេះក៏លមប្ងលចិត្តក្នុងរឿងហេតុនិងផលបានខ្លះហើយ ប៉ុន្តែតែងនៅមានសេចក្តីងឿងឆ្ងល់ក្នុងរឿងនេះទៀត នោះសូមឲ្យអ្នកសិក្សាពិចារណាសង្កេតមើលក្នុងសុភាសិតចុះ ព្រោះសុភាសិតទាំងឡាយតែងមានគោលកំណត់នៅក្នុងត្បែយោគនោះៗជាស្រេច ដូចសុភាសិតថា "មនាបោ ហោតិ ខន្តិកោ មនុស្សមានខន្តីរមែងជាទីគាប់ចិត្តរបស់មនុស្សដទៃ" ដូច្នេះ គឺថាមនុស្សមានខន្តីជាហេតុ, ការគាប់ចិត្តរបស់មនុស្សដទៃជាផល នេះសុភាសិតដែលសំដែងទាំងហេតុទាំងផល ។ សុភាសិតដែលសំដែងតែហេតុមិនសំដែងផលនោះ ដូច "សព្វភូតេសុ កាមេហិ ខេមតំ, អ្នកចូរធ្វើសេចក្តីក្សេមចំពោះសព្វសត្វ" ដូច្នេះសំដែងត្រឹមហេតុ គឺសំដែងតែត្រឹមឲ្យធ្វើសេចក្តីក្សេម មិនដឹងថាផលយ៉ាងដូចម្តេចទេ ។ ចំណែកសុភាសិតដែលសំដែងតែផលនោះដូច "សមណីធ អរណា

លោក, សមណៈទាំងឡាយមិនជាសត្រូវក្នុងលោក” ដូច្នេះសំដែងតែត្រឹមផលថាសមណៈមិនជាសត្រូវប៉ុណ្ណោះ មិនសំដែងដល់ហេតុថាមិនជាសត្រូវនោះព្រោះហេតុដូចម្ដេចផងទេ ព្រោះហេតុនោះ តាមគោលពុទ្ធសាសនាត្រូវមានហេតុផលជានិច្ច, របស់ទាំងឡាយនឹងប្រាសចាកហេតុផលមិនបាន. បើប្រាសចាកឯណាមួយហើយ គប្បីប្ដូលចិត្តថាជារបស់ក្រៅពុទ្ធសាសនា មិនមែនជារបស់ពុទ្ធសាសនាទេ វៀរលែងតែហេតុផលដែលស្រាវជ្រាវរកមិនទាន់ឃើញប៉ុណ្ណោះ ហើយនឹងលើកឡើងជាសុភាសិតមិនបាន ។

ប្រការ៥ - ការតភ្ជាប់សុភាសិត សំគាល់សេចក្ដីថា យកសេចក្ដីដែលកំពុងបរិយាយនោះមកតភ្ជាប់នឹងសុភាសិតថ្មីដែលលើក យកមកអាងដើម្បីធ្វើគោលសេចក្ដីបរិយាយមុននោះឲ្យមានទម្ងន់ឡើងគឺថាធានាអះអាងបញ្ជាក់ពាក្យដែលពោលមុននោះ ឲ្យរឹតតែមានគោលបារីកពិតប្រាកដមាំមួនឡើងទៀត. តែសុភាសិតដែលនឹងលើកយកមកតភ្ជាប់ឃើញជាក់ច្បាស់ជាកសិណដូច្នោះ តើនឹងតភ្ជាប់ដោយវិធីដូចម្ដេច? ខនេះមិនសូវជារបស់លំបាកទេ មុនដែលនឹងលើកសុភាសិតមកអាងនោះ ត្រូវធ្វើសេចក្ដីប្ដូលចិត្តក្នុងខាងដើមថា យើងនឹងលើកសុភាសិតអ្វីមកបរិយាយ គប្បីលៃលកអធិប្បាយសេចក្ដីរបស់សុភាសិតដែលលើកមកអាងនោះ ឲ្យបានសេចក្ដីល្មមជាគោលជាមុនសិន ទើបដម្រាលសេចក្ដីទាញលើកសុភាសិតថ្មីដែល

www.elibraryofcambodia.org

ជាក្រុមត្រូវគ្នាមកទទួល ព្រមទាំងអាគតដ្ឋាននៃសុភាសិតនោះៗ ផង ដូចយើងនឹងនិយាយឬនឹងធ្វើអ្វីដល់អ្នកណា យើងត្រូវសំដែងអាការយ៉ាងណាមួយឲ្យគេដឹងជាមុន ដើម្បីនឹងបានដឹងសេចក្ដីសំគាល់ ឬសេចក្ដីត្រូវការរបស់យើង ឬដើម្បីនឹងឲ្យគេបានដឹងខ្លួនថាយើងមានសេចក្ដីប្រាថ្នាដូចម្ដេច កុំឲ្យគេគិតភ័យទាំងមិនដឹងខ្លួន, សុភាសិតដែលលើកយកមកអាងក៏មានទំនងដូច្នោះដែរ, កាលតភ្ជាប់រួចហើយ គប្បីអធិប្បាយសេចក្ដីតទៅ តែកុំឲ្យវង្វេងបាត់គោលដើម ។

សុភាសិតដែលលើកយកមកតគ្នានោះ នឹងតត្រង់ណាទើបសមគួរ? ខនេះជារបស់លំបាកដែលនឹងពោលថា ត្រូវតវគ្គនោះវគ្គនេះដោយដាច់ខាតមិនបានទេ គឺនឹងតវគ្គណាក៏បាន មើលសុភាសិតដើមដែលអាងមកនឹងសុភាសិតបុងដែលត្រូវតភ្ជាប់នោះ ឲ្យល្មមសមគួរដល់គ្នា; តែសេចក្ដីចូលចិត្តដោយច្រើន ឬដែលនិយមច្រើនគ្នា ច្រើនតែតភ្ជាប់ក្នុងគោលសេចក្ដីនៃវគ្គសំខាន់របស់សុភាសិត ។ ឯសុភាសិតដែលលើកមកតនោះតើនឹងជ្រើសរើសរកសុភាសិតបែបដូចម្ដេច មានគោលកំណត់យ៉ាងដូចម្ដេចខ្លះ? ខនេះស្រេចតែនឹងឃើញថាសមគួរ មិនចាំបាច់ត្រូវលើកសុភាសិតតែមួយបែបមកតភ្ជាប់ជានិច្ចទៅទេ ត្រង់គោលសំខាន់ដែលតសុភាសិតត្រូវឲ្យសម្ពន្ធស៊ីសេចក្ដីគ្នានឹងពាក្យអធិប្បាយប៉ុណ្ណោះ ដូចសុភាសិតដើមលើកយកសុភាសិតដែលពោលអំពីសំវរៈថា "ចក្ខុនា សំវរោ

www.elibraryofcambodia.org

សាធុ, ការសង្រ្គមបក្ខុល្អ" ដូច្នេះ ក្នុងខាងដើមគប្បីអធិប្បាយពាក្យថាសំវរៈ ហើយមិនចាំបាច់លើកយកសុភាសិតសំវរៈមកអាងទេ ព្រោះអត្ថន័យរបស់សំវរៈ ក៏គឺឥន្រ្ទិយនៅក្នុងអំណាចរបស់សតិ, សតិជាអ្នកទទួលខុសត្រូវ, សុភាសិតនេះនឹងលើកយកសុភាសិតសតិមកតភ្ជាប់ក៏មិនទាស់ដែរ, ចំណែកគោលកំណត់ដែលរើសប៉ុននោះគឺការអាងអាគតដ្ឋាននៃសុភាសិតឲ្យត្រូវត្រង់ពិតប្រាកដកុំឲ្យខុសភ្លាត់បាន; ខនេះដែលនឹងអាចធ្វើឲ្យស្រួលទៅបាន ត្រូវអាស្រ័យការទន្ទេញសុភាសិតឲ្យចាំបានច្រើនព្រមទាំងចាំអាគតដ្ឋាននៃសុភាសិតនោះៗ ឲ្យពិតប្រាកដផង ព្រោះក្នុងខណៈដែលកំពុងអធិប្បាយសេចក្ដី www.elibraryofcambodia.org យើងអាចនឹកដល់សុភាសិតនោះ សុភាសិតនេះបានដោយងាយ មិនត្រូវតែងអធិប្បាយតាមតែនឹកឃើញស្រេចតែប៉ុណ្ណោះទៅនោះទេ ត្រូវឲ្យដាក់ប្រាកដក្នុងចិត្តជាមុន ទើបជាការល្អបំផុត ។

មួយទៀត, ការតភ្ជាប់សុភាសិត ចាត់ថាជាអង្គការសំខាន់បំផុត បើតមិនល្អនឹងធ្វើឲ្យខូចសេចក្ដី ដូចកំពុងនិយាយពីរឿងធ្វើស្រែ ស្រាប់តែទៅចាប់លើកយកអាការធ្វើសួនច្បារមកជាសំអាងវិញ ដូច្នោះនឹងនាំឲ្យឃ្លាងខ្លួសេចក្ដី ព្រោះហេតុនោះ ត្រូវតែងឲ្យជារឿងជាប់ទាក់ទងគ្នា មុននឹងផ្ដើមគប្បីអធិប្បាយសន្សំម ១ បង្អោនដម្រាលទៅរកសុភាសិតថ្មីដែលត្រូវនាំមកអាង កុំប្រញាប់ប្រញាល់ធក់លើកឡើងកណ្ដាលឃ្លា ។

ប្រការ ៦-ការបញ្ចប់សុភាសិត គឺវេលាដែលនឹងបញ្ចប់សុភាសិតនោះ តើត្រូវបញ្ចប់ដោយពាក្យដូចម្ដេច ? អ្នកសិក្សាត្រូវជ្រាបគោលសេចក្ដីខាងដើមជាមុនថា សុភាសិតនេះជាសុភាសិតធម្មាធិដ្ឋាន ឬជាសុភាសិតបុគ្គលាធិដ្ឋាន ។ សុភាសិតធម្មាធិដ្ឋាន គឺសំដៅយកសុភាសិតដែលលើកធម៌ឡើងអាងដោយមិនមានបុគ្គលជាតួយ៉ាង ដូចសុភាសិតថា "បមាទោ មច្ចុនោ បទំ, សេចក្ដីប្រមាទជាផ្លូវនៃសេចក្ដីស្លាប់" ដូច្នេះជាដើម ។ ចំណែកសុភាសិតបុគ្គលាធិដ្ឋាននោះ សំគាល់សេចក្ដីថាដែលលើកបុគ្គលឡើងអាងក្នុងសុភាសិត ដូចសុភាសិតថា "សុវិជានោ ភវំ ហោតិ, អ្នកចំរើនតថាគតឆ្ងាយដឹង" ដូច្នេះជាដើម ។

www.elibraryofcambodia.org

ម្យ៉ាងទៀត, គប្បីជ្រាបនូវគោលនៃសុភាសិតដែលនិយាយអំពីធម៌ខ្មៅនិងធម៌ស, សុភាសិតធម៌ខ្មៅសំគាល់សេចក្ដីថា សុភាសិតដែលពោលដល់ផល ឬហេតុដែលអាក្រក់ ឬសុភាសិតសម្លឹងយកការប្រដៅឲ្យលះអកុសល ដូចសុភាសិតថា" ហីនំ ធម្មំ ន សេវេយ្យ, មិនគប្បីសេពធម៌ថោកទាប" ដូច្នេះជាដើម ហៅថាសុភាសិតប៉ែកខាងធម៌ខ្មៅ ព្រោះជារបស់ថោកទាបអាក្រក់ ជាអកុសល ។ ចំណែកសុភាសិតដែលពោលដល់ផលឬហេតុដែលល្អ ឬប្រដៅឲ្យបំពេញកុសលផ្លូវល្អ ដូចសុភាសិតថា "សុក្កំ ភាវេថ បណ្ឌិតោ, បណ្ឌិតគប្បីចំរើនធម៌ស" ដូច្នេះជាដើម ចាត់ជាសុភាសិតប៉ែកខាងធម៌ស ។

កាលអ្នកសិក្សាចូលចិត្តយល់ច្បាស់នូវសុភាសិតធម្មាធិដ្ឋាន បុគ្គលាធិដ្ឋាន និងសុភាសិតធម៌ទៅ ធម៌សង្ខេបនោះហើយ ត្រូវដឹងតទៅថាជាសុភាសិតដូចម្តេច គឺសុភាសិតដែលមានទាំងហេតុទាំងផល ឬមានតែហេតុមិនមានផល ឬមានតែផលមិនមានហេតុតាមគោលដូចបានអធិប្បាយមកហើយគង់ប្រការ ៤, រួចហើយគប្បីប្រកាន់គោលបញ្ចប់សុភាសិតដូចតទៅនេះ ៖

ក ) សុភាសិតជាធម្មាធិដ្ឋាន, វេលាបញ្ចប់ត្រូវបញ្ចប់ដោយពាក្យដែលទាក់ទងខាងផ្លូវធម៌ សូម្បីគង់ខាងដើមបានលើកយកបុគ្គលឡើងអធិប្បាយ, តែវេលាបញ្ចប់សុភាសិតនឹងបញ្ចប់ដោយបុគ្គលាធិដ្ឋានមិនបាន ត្រូវបែរមកបញ្ចប់សុភាសិត ដោយសំដៅដល់គោលធម៌សុទ្ធ ៗ ។

ខ ) សុភាសិតបុគ្គលាធិដ្ឋាន, វេលាបញ្ចប់សុភាសិត ត្រូវបញ្ចប់ដោយអាការសំដែងដល់បុគ្គល, ទោះគង់ខាងដើមបានលើកយកធម៌ឡើងអធិប្បាយក្តី តែវេលាបញ្ចប់ក៏ត្រូវលើកប្រមូលធម៌នោះមកស្រោបបុគ្គលឲ្យជាសុភាសិតបុគ្គលាធិដ្ឋាន គឺបញ្ចប់ដោយសំដៅដល់បុគ្គល ។

គ ) សុភាសិតដែលសំដែងទាំងហេតុទាំងផល វេលាបញ្ចប់ក៏ត្រូវអធិប្បាយបញ្ចូលហេតុផលឲ្យវេញជុំគ្នា វេលាដែលបញ្ចប់សុភាសិតត្រូវឲ្យទាញយកសុភាសិតដើមមកអាងម្តងទៀត ។

ឃ ) សុភាសិតដែលមានតែហេតុ ក៏ត្រូវបញ្ចប់ដោយពាក្យសំដែង

www.elibraryofcambodia.org

ហេតុរបស់សុភាសិត, នោះបីខានដើមអធិប្បាយដល់ផល វេលាបញ្ចប់ក៏ត្រូវវិលទៅបរិយាយហេតុម្ដងទៀត ទើបជាការត្រឹមត្រូវល្អ ។

ង) សុភាសិតដែលមានតែផលក៏ដូចគ្នា គឺត្រូវបញ្ចប់ដោយពាក្យសំដែងផល, នោះក្នុងខានដើមអធិប្បាយផល់ហេតុ វេលាបញ្ចប់ក៏ត្រូវវិលទៅពោលដល់ផលជាដរាប ។

ការផ្ដើមឡើងនិងការបញ្ចប់សុភាសិតដែលទាក់ទងដោយហេតុផលនោះ ស្រដៀងៗគ្នា ខុសគ្នាខ្លះតែវេលាផ្ដើមសុភាសិត អធិប្បាយហេតុឬផលនោះៗ ហើយអធិប្បាយផ្ទុយគ្នា សូម្បីការបញ្ចប់ក៏ដូចគ្នា ត្រូវបញ្ចប់ឲ្យស៊ីសេចក្ដីគ្នានឹងសុភាសិត [illegible] សេចក្ដីនៃពាក្យដែលបានបរិយាយមកនោះឲ្យខ្លីល្មម ហើយទើបបញ្ចប់សុភាសិត នេះចាត់ជាប្រើការបាន ។

www.elibraryofcambodia.org

គោលលំបាកទាំង ៦ ប្រការនេះ ខ្ញុំបានជ្រើសរើសតាមបែបដែលអ្នកសិក្សាភាគច្រើនបានដឹងថាលំបាកដូច្នេះ, តែខ្ញុំស្មានថាគង់នៅមានអ្នកសិក្សាខ្លះ ដឹងគោលលំបាកវិសេសជាងនេះទៅទៀតពុំខាន ។ គោលលំបាកនោះគឺជាអត្តផុតវិស័យរបស់ខ្ញុំ ព្រោះការចេះដឹងរបស់មនុស្សម្នាក់ៗមានថ្នាក់មិនស្មើគ្នាទេ ; ក្នុងទីនេះ ខ្ញុំបានជ្រើសរើសរកផ្លូវដែលអ្នកសិក្សាដោយច្រើនដឹងថាលំបាក ឬតាមសម្ដែងខាងភាគច្រើនយកមកបរិយាយជាមុន តាមសមគួរដល់សមត្ថភាពរបស់ខ្ញុំ ។

អ្នកសិក្សាបានអានព្រមទាំងពិចារណាតាមដែលបរិយាយមកខាងដើមនោះហើយ ខ្ញុំក៏នៅមិនប្រាកដក្នុងចិត្តថា នឹងតែងបានល្អដោយដាច់ខាតទេ សូម្បីនឹងតែងបាន ក៏គង់អាចមានរបស់ណាមួយខ្វះខាតពុំខាន ដូចពុទ្ធភាសិតថា "ចេះដប់មិនស្មើប្រសប់ ១" នេះជាសេចក្ដីពិត, ត្រូវអាស្រ័យអ្នកសិក្សាយកចិត្តទុកដាក់ ទាញគោលដែលបរិយាយនេះមកប្រើប្រែកបក្នុងរូបសុភាសិតដែលតែង ហើយហាត់តែងញយ ៗ ឬគ្រប់ ៗ ពេលដែលត្រូវណានាំធ្វើឲ្យដឹងឡើង ក្រៅអំពីនេះ អ្នកសិក្សាត្រូវប្រកបដោយអង្គច្រើនប្រការទៀត ទើបនឹងតែងបានល្អ គឺ៖

១- ភាសាអក្សរសាស្ត្រ;

www.elibraryofcambodia.org

២- អានធម៌ ពុទ្ធប្បវត្តិនិងវិន័យឲ្យបានចាំមុតមាំ;

៣- សេចក្ដីដឹងភាយរង (សេចក្ដីដឹងជុំវិញខ្លួន);

៤- និស្ស័យសង្កេត ។

ប្រការ ១- ដែលពោលថា ភាសាអក្សរសាស្ត្រនោះសំគាល់សេចក្ដីថា ប្រើពាក្យក្នុងវេណាតែងសុភាសិត ឲ្យជារបៀបរៀបរយសមគួរតាមគោលវេយ្យាករណ៍ ព្រមទាំងចេះរបៀបពាក្យខ្ពស់-ទាបក្នុងវេណាដែលតែងត្រូវឲ្យដឹងថាអ្នកណានិយាយនឹងអ្នកណា មនុស្សជាន់ខ្ពស់ឬជាន់ទាបជាដើម, ពាក្យនិយាយត្រូវលៃឲ្យត្រូវតាមលក្ខណៈច្បាប់កំណត់ រហូតដល់អាការរបស់មនុស្ស ឬ សត្វ ឬរាជសព្ទ ក្នុងកាលពោលដល់ព្រះពុទ្ធ ឬ

ស្តេចផែនដីជាដើម ហេតុដល់កម្មករនិយាយនឹងចៅហ្វាយនាយ ៗនិយាយនឹងកម្មករ គួរប្រើខុសគ្នាបែបណា ពាក្យរៀបរៀងត្រូវប្រើឲ្យរៀបរយសមគួរ កុំលោតផ្លោះប្រយោគឲ្យរដាក់រដោចខូចសេចក្ដីនឹងកុំប្រើពាក្យផ្គួរផ្គើរដែលនាំឲ្យសាបរលាប រួមសេចក្ដីថា ត្រូវនិយាយឲ្យសមរម្យតាមភាសាអក្សរសាស្ត្រ មិនមែនប្រើដូចយើងនិយាយគ្នាតាមធម្មតាទេ, ១នេះត្រូវអាស្រ័យការចេះដឹងគោលវេយ្យាករណ៍ឲ្យហ្មត់ចត់ ឬធ្លាប់សង្កេតសេចក្ដីរៀបរៀងផ្សេង ៗ ឲ្យច្រើនផង ។

ប្រការ២- អ្នកសិក្សាដែលនឹងតែងសេចក្ដីបានល្អ ព្រមទាំងមានគោលចារិកត្រឹមត្រូវ មិននែននិយាយបាចហាចដូចជាទំលិចពលនោះទេ គប្បីខស្បាហ៍មើលសៀវភៅធម៌អាថ៌ឲ្យបានច្រើន ដែលជាសំនួនទេសន៍ ឬបរិយាយធម៌កថា ហេតុដល់ពុទ្ធប្បវត្តិឬប្រវត្តិសាវ័កផ្សេង ៗ ដែលជាបុគ្គលសំខាន់ក្នុងពុទ្ធសាសនា នឹងវិន័យ ដើម្បីនិយាយតាមគោល ព្រោះ-ការតែងអធិប្បាយសុភាសិត ត្រូវចាប់យកសេចក្ដីសំខាន់របស់សុភាសិតនោះ ៗ មកបរិយាយ ជាឧទាហរណ៍បំផុសគាស់សេចក្ដីដឹងផ្សែកនោះ ៗ ឲ្យចំរើនថ្លៃកឡើង ហើយជាបច្ច័យឧបត្ថម្ភការរៀបរៀងសុភាសិតរបស់ខ្លួនឲ្យមានតម្លៃវិសេសឡើងទៀតផង ។

ប្រការ៣- សេចក្ដីដឹងរាយរងនោះ ជាកិច្ចកំណត់មិនបានដោយដាច់ខាតថា ត្រូវដឹងចំពោះរបស់នោះរបស់នេះទេ គឺជាមុខការមួយដែលអ្នក

www.elibraryofcambodia.org

សិក្សាត្រូវខ្វល់ខ្វាយខ្លួនឯង ដោយបានអាន ឬជួបឃើញសង្កេតទុក; សេចក្ដីដឹងពាយរង គឺសេចក្ដីដឹងជុំវិញខ្លួននោះឯង, ខនេះទើងជាលំបាកក៏សែនលំបាកព្រោះជាវិជ្ជាមិនកំណត់ហើយដែលទើងនិយាយឬសរសេរបានល្អ ក៏ស្រេចតែអ្នកជំនាញផ្លូវណាទីមួយ តាមដែលសាមីខ្លួនបានបេះចាំប្រាកដ ៗ ខនេះអ្នកសិក្សាត្រូវអប់រំបង្ការទុកជាមុនឲ្យហើយ សម្រាប់លើកអ្វីឡើងអធិប្បាយទើងបានជួរចិត្តអំពីការលំបាក ព្រោះការលំបាកនោះកើតមកពីការមិនយកចិត្តទុកដាក់ក្នុងវិជ្ជាការនោះឯង ចូនកាលជួបឃើញហើយតែមិនបានយកចិត្តទុកដាក់ ការដឹងដែលគួរទើងបានក៏ត្រឡប់ជាអាក់ខានវិញ ឬទើងជាងាយក៏បាន [illegible] សេចក្ដីថាអាចកើតបានដោយសារនិស្ស័យអធ្យាស្រ័យដែលលំបាកដឹងលំបាកឃើញនោះឯង ដូចជួបឃើញរបស់ណាមួយ ក៏ព្យាយាមស្រាវជ្រាវរកសេចក្ដីពិត មិនព្រមឲ្យវត្ថុគ្រប់យ៉ាងដែលមានមកហើយនោះកន្លងផុតទៅដោយមិនយកចិត្តទុកដាក់រហូតដល់កាសែតដែលជាកន្លែងកើតនៃសារប្រយោជន៍ជាអនេកប្បការ ក៏គួរតែត្រៀតអានដរាប, តប្បីដឹងថារបស់ណាមានប្រយោជន៍ច្រើន អាចឲ្យទោសច្រើនដូចគ្នា ដូចពាក្យថា "គុណ អនន្ត ទោស មហន្ត" ព្រោះហេតុនោះ វត្ថុទាំងឡាយអាចនាំមកទាំងគុណទាំងទោស ដូចកាសែតដែលយើងយល់ឃើញថាជាទោស ហើយមិនអានសោះក៏មិនបាន សូម្បីព្រះសម្មាសម្ពុទ្ធរបស់យើង ព្រះអង្គទ្រង់ប្រដៅថា "ត្រូវស្ដាប់ទាំង

www.elibraryofcambodia.org

របស់សប្បុរសនឹងអសប្បុរស" ដូច្នេះសឲ្យឃើញថាមិនហាម, តែកុំទៅពេញចិត្តជាប់អារម្មណ៍ក្នុងរបស់ដែលមិនល្អនោះ ព្រោះរបស់មិនល្អច្រើនឲ្យទោស, ដូចរឿងប្រលោមលោកជាដើម មិនគួរនាំមកតែងសេចក្ដីជាសំនួនសុភាសិតទេ, ដើម្បីឲ្យជាក់ច្បាស់ ខ្ញុំសូមណែនាំថា វិជ្ជាការទាំងឡាយអាចកើតឡើងបានដោយសារការស្ដាប់ ការអាន ការសរសេរ ការសិក្សាជាកិច្ចសំខាន់បំផុត ដែលអ្នកសិក្សាគប្បីខ្មៀតបំពេញឲ្យបានគ្រប់គ្រាន់តាមសមត្ថភាពរៀងៗខ្លួន ។

ប្រការ ៤ - និស្ស័យសង្កេតនោះ គឺមាននិស្ស័យកំណត់ចាំដូចបាន

www.elibraryofcambodia.org

អានឬបានស្ដាប់របស់ណាមកក៏ចាំបាន វេលាតែងក៏នឹងអាចយកមកប្រើបានដោយស្រួល ព្រោះវេលាដែលតែងសេចក្ដីយើងត្រូវចងក្រងពាក្យនិយាយគ្រប់ៗពាក្យដែលចេញមកអំពីខួរក្បាល, កាលខួរក្បាលមិនវល់ធ្វើនាទីកំណត់ចាំអ្វីទុកហើយ យើងនឹងស្រាវជ្រាវយកអ្វីចេញមកសំដែងក៏ពុំបាន ព្រោះហេតុនោះ ខ្លួនឯងត្រូវតែអប់រំខានមិនបានចំពោះនិស្ស័យសង្កេតនេះ ដែលចាត់ថាជាអង្គមួយសម្រាប់ជួយការរៀបរៀងសេចក្ដីសុភាសិតឲ្យបានជាក់ច្បាស់ ។

ទាំង ៤ ប្រការនេះ ជាបច្ច័យឧបត្ថម្ភឲ្យសុភាសិតយើងមានតម្លៃវិសេសឡើង មិនតែប៉ុណ្ណោះ ត្រូវហាត់សរសេរអក្សរឲ្យច្បាស់ស្អាតបាតត្រឹមត្រូវនឹងអានបានងាយ ចេះញែកវគ្គ ឃ្លា ល្បះ ដកបន្ទាត់ ឲ្យត្រូវតាម

បំណែកនឹងតួប្រកបការន្ដមិនឲ្យខុសក្បាត់ ។

កាលបានអានដល់ត្រឹមនេះហើយ លោកអ្នកដឹងថាខ្ញុំអធិប្បាយវិធីតែងសេចក្ដីសុភាសិតហើយឬនៅទេ, នេះគ្រាន់តែជាលំនាំដើមដែលខ្ញុំនិយាយព្រាងបំពោះខលំបាកខ្លះ ដែលអ្នកសិក្សាភាគច្រើនតែងត្អូញថាជាការស្មុគស្មាញប៉ុណ្ណោះ ។ ឯវិធីតែងសេចក្ដីសុភាសិតនោះដូចមានតទៅខាងមុខនេះ ។

# វិធីតែងសេចក្ដីសុភាសិត

ការតែងសុភាសិតថ្នាក់ត្រី ឬធម្មសិក្សាថ្នាក់ត្រី កាលចាប់ផ្ដើមមុនដំបូងមិនទាន់ប្រាកដថា ត្រូវមានសុភាសិតដែលលើកយកមកអាងមែបនឹងសុភាសិតកំពុងតែងនោះប៉ុន្មានឡើយ តែតាមប្រកាសរបស់ធម្មាចារ្យសាលាធម្មវិន័យដោយច្រើន លោកឲ្យរកសុភាសិត ១ ព្រមទាំងអាគតដ្ឋានមកអះអាងផង ដើម្បីឲ្យអ្នកសិក្សាមានសេចក្ដីដឹងផ្នែកនេះរឹតតែឆ្ងាយទូលាយឡើង ដូចគ្នានឹងរបៀបតែងសេចក្ដីសុភាសិតថ្នាក់ទោ ថ្នាក់ឯកដែលមានវិធីតែងយ៉ាងនេះមកហើយដែរ ។ តាមធម្មតាអ្នកសិក្សាថ្មី គឺថ្មីបំពោះការឈានឡើងទៅកាន់ការសិក្សាធម្មវិន័យ ហើយសុភាសិតជាអង្គការមួយរបស់អ្នកសិក្សាធម្មវិន័យដែរ អ្នកសិក្សាគង់ដឹងខ្លួនថា បង្អៀតបង្អល់ជាធម្មតា ព្រោះរបស់ណាមិនធ្លាប់ របស់នោះឃើញថាលំបាក តែតាមពិតនឹងលំបាកឬងាយយ៉ាងណានោះ មិនមានអ្នកណាទាយចិត្តគ្នាបាន អ្នកខ្លះឃើញថាលំបាក តែអ្នកខ្លះឃើញថាងាយ អ្នកខ្លះឃើញថាលំបាកយ៉ាងនេះ អ្នកខ្លះឃើញថាលំបាកយ៉ាងនោះ មិនមែនដូចគ្នាទេតាមសេចក្ដីគិតនឹករបស់មនុស្សម្នាក់ ៗ តែទោះយ៉ាងណាក៏ដោយ អ្នកសិក្សាគ្រប់ ៗ គ្នា ត្រូវជ្រាបគោលការរៀបរៀងឬការតែងសេចក្ដី ព្រោះគោលកំណត់ជារបស់ត្រូវតែដឹង បើមិនដូច្នោះទេ នឹងចាប់យកសុភាសិតអ្វីតែងអធិប្បាយឡើងមិនត្រូវទាំងអស់ ។ ខ្ញុំព្យាយាមស្រាវជ្រាវរកគោល

www.elibraryofcambodia.org

កំណត់មកបរិយាយទុកគ្រាន់ជាគោល ។ ដើម្បីជាបច្ច័យឧបត្ថម្ភឲ្យអ្នកសិក្សាដឹងជ្រុងជ្រោយដំណើរផ្លូវវិធីតែងសេចក្ដីសុភាសិត ដែលមានពិតប្រាកដក្នុងលំនាំដើមបានពណ៌នាមកច្រើនហើយតែលំនាំនោះជាបទទូទៅ ឬជាចំណែកប្រែកបមិនមែនចំពោះវិធីតែងសេចក្ដីទាំងស្រុងទេ ។ ចំណែកគោលកំណត់នោះគប្បីធ្វើតាមគោលអធិប្បាយភាសិតដូចតទៅនេះ៖

១ - កន្លែងកើតនៃភាសិត ;

២ - មេបទនៃភាសិត ;

៣ - សេចក្ដីសំគាល់នៃភាសិត ;

៤ - គោលការរៀបរៀងសេចក្ដី ;

www.elibraryofcambodia.org

៥ - គោលកំណត់របស់ភាសិត ;

៦ - ចំណែកប្រែកបផ្សេង ៗ

គោលទាំង ៦ ប្រការនេះជាមេបទ តទៅនឹងបរិយាយជាខ ៗ, សូមឲ្យអ្នកសិក្សាអានយ៉ាងពិនិត្យពិច័យ នឹងកើតប្រយោជន៍ជាអនេកប្បការធ្វើឲ្យវិជ្ជាផ្នែករៀបរៀងសេចក្ដីនេះ របស់អ្នកសិក្សារិតតែទូលាយឡើងដោយលំដាប់ ៗ

ខ ទី ១- ដែលថា "កន្លែងកើតនៃភាសិត" នោះ គឺតាមធម្មតាភាសិតនោះនឹងកើតឡើងបានដោយស្ថានដូចម្ដេច ? កើតអំពីអ្នកណា ? ភាសិតទាំងឡាយមានប្រចាំនៅគ្រប់ជាតិ គ្រប់ភាសា គ្រប់សាសនា តាមសេចក្ដី

និយមនឹងលទ្ធិ , តែទោះយ៉ាងណាក៏ដោយ គង់មិនប្លែកផ្សេងគ្នាប៉ុន្មានទេ មានវត្ថុបំណងដូចគ្នា គឺចង់ក្រងជាភាសិតនីមួយៗនោះសំដៅត្រង់ឲ្យស្រប ទឹកចិត្ត ស្តាប់ងាយ ពីរោះ មានសេចក្តីទូលាយ ជាទីជាប់ចិត្ត , និយាយយ៉ាងងាយគឺជាគោលនៃសេចក្តីប្រព្រឹត្តិល្អ ឲ្យលះសេចក្តីប្រព្រឹត្តិអាក្រក់ ទើបពោលថាភាសិតកើតអំពីអ្នកប្រាជ្ញ ប្រាថ្នាសេចក្តីសុខដល់អ្នកដទៃយ៉ាងក្រៃលែង មិនមែនមានបំណងប្រទូសរ៉ាយឡើយ ព្រោះអ្នកដែលបំណងប្រទូសរ៉ាយរមែងមិនមានសុភាសិត សូម្បីបាលីក៏មានប្រាកដថា "នត្ថិ ទុដ្ឋ សុភាសិតំ, ពាក្យសុភាសិតមិនមានក្នុងមនុស្សប្រទូសរ៉ាយ" ដូច្នេះ សុភាសិតត្រូវមានចំពោះលោកអ្នកមានចិត្តល្អ អ្នកស្វែងរកប្រយោជន៍នឹងសេចក្តីសុខដល់ពួកមនុស្សមិនរើសមុខ ចំពោះក្នុងពុទ្ធសាសនា លោកពោលថាមាន ៤ ស្ថានគឺ ៖

ក) ពុទ្ធភាសិត ពាក្យព្រះពុទ្ធត្រាស់ព្រះអង្គឯង ,

ខ) សាវកភាសិត ពាក្យព្រះសាវកពោល ;

គ) ទេវតាភាសិត ពាក្យទេវតាពោល;

ឃ) ឥសិភាសិត ពាក្យឥសីឬអ្នកបួសក្រៅសាសនាពោលៗ

អ្នកសិក្សាកាលបានដឹងជាក់ច្បាស់ថាជាភាសិតរបស់អ្នកណាហើយ ក៏នឹងបានស្រួលក្នុងពេលដែលបរិយាយ ព្រោះនឹងបានប្រើពាក្យឲ្យត្រូវត្រង់ចំពោះឋានៈរបស់លោកជាម្ចាស់សុភាសិត តែខនេះបើនៅមិនទាន់ដឹង

www.elibraryofcambodia.org

ប្រាកដថាជាភាសិតរបស់អ្នកណាទេ ក៏គួរប្រើពាក្យជាកណ្ដាលៗ តាម ដែលបានបរិយាយមកក្នុងលំនាំដើមនោះ ក្នុងទីនេះត្រូវឲ្យជ្រាបដល់កន្លែង ជាទីកើតនៃភាសិតប៉ុណ្ណោះ មិនចំពោះតែពុទ្ធសាសនាទេ សូម្បីសាសនា ដទៃក៏គង់មានន័យដូចគ្នា ។

២- "មេបទនៃភាសិត" នោះមេបទធំមាន ២ប្រការគឺ:

ក) បុគ្គលាធិដ្ឋាន ពោលយកបុគ្គលជាទីតាំង ;

ខ) ធម្មាធិដ្ឋាន ពោលយកធម៌ជាទីតាំង ។

សុភាសិតបទណា សំដែងអំពីបុគ្គលអ្នកធ្វើ អ្នកប្រព្រឹត្ត អ្នកប្រតិបត្តិ ជាតួយ៉ាង ដូចពោលថា បុគ្គលមានសីលដូច្នោះ មនុស្សមានសីល សមាធិ បញ្ញា ដូច្នោះៗ យ៉ាងនេះជាដើម ហៅថាបុគ្គលាធិដ្ឋាន ។

សុភាសិតបទណាសំដែងអំពីធម៌សុទ្ធៗ ដូចសំដែងថាសីលដូច្នោះ សមាធិ បញ្ញា ដូច្នោះៗ យ៉ាងនេះជាដើមហៅថាធម្មាធិដ្ឋាន ។

ឯវោហារដែលប្រើសម្រាប់សុភាសិតជាបុគ្គលាធិដ្ឋានទាំងធម្មាធិដ្ឋាន នោះ គប្បីជ្រាបតាមសេចក្ដីដែលបានសារ៉ូបហើយក្នុងលំនាំដើមត្រង់ ប្រការ ៦ ។

៣-"សេចក្ដីសំគាល់នៃភាសិត" នោះ សំដៅសេចក្ដីថា សុភាសិត គប់ៗបទ រមែងមានសេចក្ដីសំគាល់ជា ៣ ស្ថានគឺ:

www.elibraryofcambodia.org

ក) ជាពាក្យណែនាំប្រដៅ;

ខ) ជាពាក្យសរសើរ;

គ) ជាពាក្យតិះដៀល ។

សុភាបិតបទណា ប្រើពាក្យថា ចូរ, គប្បី, ត្រូវ, កុំ ។ល។ នាំមុខកិរិយា ដូច "ចូរពិចារណាខ្លួនដោយខ្លួនឯង" "គប្បីប្រព្រឹត្តសុចរិត" ដូច្នេះជាដើម ឬ និយាយជាពាក្យកណ្ដាល ៗ ដូច "ខ្លួនជាទីពឹងរបស់ខ្លួនឯង, សេចក្ដីលក់មិនមានក្នុងលោក" ដូច្នេះជាដើម ជាពាក្យណែនាំប្រដៅ; វេលាដែលរៀបរៀងសុភាសិត ចូរព្យាយាមធ្វើជាទំនងបន្ថែមបញ្ជាក់ សំដែងគុណ ទោស ប្រយោជន៍ និងមិនមែនប្រយោជន៍ ព្រមទាំងលើកឧទាហរណ៍មកប្រៀបធៀបឲ្យឃើញជាក់ច្បាស់ បើជាសេចក្ដីល្អចូរបន្ថែមបញ្ជាក់ឲ្យឧស្សាហ៍បំពេញ, បើជាសេចក្ដីអាក្រក់ចូរបន្ថែមបញ្ជាក់ឲ្យលះ ដូច្នេះជាវិធីរៀបរៀងសេចក្ដីនៃសុភាសិតដែលជាពាក្យណែនាំប្រដៅ ។

www.elibraryofcambodia.org

សុភាសិតបទណា សំដែងសរសើរបុគ្គលដែលល្អ ឬធម៌ដែលល្អដូច "បណ្ឌិតមិនសំដែងអាការខ្ពស់ទាប" ឬ "សេចក្ដីមិនប្រមាទ ជាផ្លូវមិនស្លាប់" ដូច្នេះជាដើម នេះជាពាក្យសរសើរ វេលារៀបរៀងសេចក្ដីក៏ត្រូវព្យាយាមលើកតំកើងពណ៌នាគុណរបស់បុគ្គលឬរបស់ធម៌ឲ្យជាក់ច្បាស់ ដើម្បីជាឧបាយដឹកនាំទាញចិត្តអ្នកដទៃឲ្យកើតសេចក្ដីជ្រះថ្លាយ៉ាងពិតប្រា-

កដ នេះឯងជាវិធីរៀបរៀងសេចក្ដីនៃសុភាសិតដែលជាពាក្យសរសើរ ។

ចំណែកសុភាសិតបទណា សំដែងទោសរបស់បុគ្គលឬរបស់ធម៌ ដូចសំដែងថា "អ្នកមានសេចក្ដីក្រោធកើតហើយ ជាអ្នកវិនាស" ឬ "សេចក្ដីលោភជាអន្តរាយនៃធម៌ទាំងឡាយ" ដូច្នេះជាដើម ជាពាក្យតិះដៀល ព្យាយាមរៀបរៀងពាក្យបរិយាយឲ្យជាការសំដែងទោស យ៉ាងពិតប្រាកដ ដើម្បីឲ្យអ្នកស្ដាប់បានដឹងពិតឃើញពិត នេះឯងជាវិធីរៀប-រៀងសេចក្ដីនៃសុភាសិតដែលជាពាក្យតិះដៀល ។

៤- "គោលការរៀបរៀងសេចក្ដី" នោះ មាន២បែបគឺ:

ក) រៀបរៀងចែកជា ៣សង្កាត់ គឺឧទ្ទេស និទ្ទេស បដិនិទ្ទេស;

www.elibraryofcambodia.org

ខ) រៀបរៀងអធិប្បាយបញ្ចូលគ្នាតទៅ ។

សង្កាត់ដើម: មុនដំបូងគប្បីលើកយកសេចក្ដីសំគាល់របស់ស័ព្ទ ដែលហៅថាបទពិចារណា ឬបរិយាយគោលធម៌ ឬសេចក្ដីសំគាល់របស់ភាសិតនោះត្រឹមខ្លីៗ តែសេចក្ដីទុកជាគោលគ្រោងដែលយើងប្រុងនឹងតែងតទៅ ឬហៅម្យ៉ាងទៀតឲ្យងាយយល់ គឺការតាំងមាតិកាខាងដើមខ្លីៗនោះឯង តែគួរតាំងទុកជាសង្កាត់១ ដើម្បីឲ្យស្រួលក្នុងពេលរៀប-រៀង យ៉ាងនេះហៅថាឧទ្ទេស ឬហៅថាគោលសេចក្ដីខាងដើម ។

សង្កាត់កណ្ដាល: អធិប្បាយសេចក្ដីនៃភាសិតនោះឲ្យពិស្ដារពេញទៅ សំដែងហេតុផលព្រមដោយគុណនិងទោស ដែលគួរនឹងផ្សា

គ្នាឲ្យបានមាំមួន ធ្វើសេចក្ដីឲ្យបានជិតស្និទ្ធទាក់ទងងាយស្ដាប់ ។

មួយទៀតសុភាសិតដែលលើកយកមកសំអាងនោះ គួរនឹងតភ្ជាប់ក្នុងសង្កាត់នេះ ព្រោះជាសង្កាត់មានរឿងដែលត្រូវនិយាយច្រើន នេះហៅថា និទ្ទេសគឺជាសង្កាត់ដែលត្រូវសំដែងពង្រីកសេចក្ដីចេញទៅ ។

សង្កាត់ខាងចុង : ពោលសរុបរួបរួមត្រឡប់ស្រាវសេចក្ដីដែលបរិយាយមកនោះឲ្យច្បាស់ ជាការបញ្ចូលគ្នាទាំង៣សង្កាត់ បញ្ជាក់សេចក្ដីសង្កាត់កណ្ដាលឲ្យច្បាស់ឡើង ហើយអធិប្បាយបង្អោនចូលទៅរកសុភាសិតដើមបញ្ចប់សុភាសិតតែម្ដង យ៉ាងនេះហៅថា បដិនិទ្ទេសគឺពោលត្រឡប់សេចក្ដីខាងដើមឲ្យ[illegible]គាជាប់បង្គោល កុំឲ្យក្បាត់ខុសឃ្លាតពីគោលដើម ។

www.elibraryofcambodia.org

ចំណែកវិធីរៀបរៀងអធិប្បាយបញ្ចូលគ្នាតទៅនោះ មិនមែនតាំងជាឧទ្ទេស និទ្ទេស ឬបដិនិទ្ទេស តាមដែលបានបរិយាយមកហើយនេះទេ គឺរួមសេចក្ដីទាំងអស់តែមួយ អធិប្បាយសម្រួលទៅបន្តិចម្ដងៗ តែកុំឲ្យវង្វេងតាមតែប៉ាកកានាំទៅនោះឡើយ ព្រោះរបៀបនេះប្រើការមិនបាន, ទោះយ៉ាងណាក្ដី យើងត្រូវមានគ្រោងការក្នុងចិត្តរបស់យើងជានិច្ច ហើយគប្បីលៃលករកសុភាសិតផ្សេងៗ ដែលមានសេចក្ដីទាក់ទងគ្នា មកជាសំអាងទើបនឹងតែងបានល្អ ។

៤- "គោលកំណត់របស់ភាសិត" នោះចាត់ជា ៣ ប្រការតាមទំនងធម៌ដែលសំដៅក្នុងសុភាសិត គឺៈ

ក) យ៉ាងទាប ;

ខ) យ៉ាងកណ្ដាល ;

គ) យ៉ាងខ្ពង់ខ្ពស់ ;

ដែលហៅថា: យ៉ាងទាប សំគាល់សេចក្ដីថា សុភាសិតដែលសំដែងសេចក្ដីយ៉ាងរាក់ ចំពោះផ្លូវលោក ដែលអាចសម្លឹងឃើញបានងាយ ៗ ដូចសុភាសិតថា "ទេកាសី លភតេ សុខំ អ្នកស៊ីម្នាក់ឯងមិនបានសុខទេ" ដូច្នេះជាសុភាសិតដែលឃើញផលជិតងាយ ៗ គឺអ្នកស៊ីនោះបើគ្មានអ្នករួមវង់សន្ទនាគ្នា ស៊ីតែម្នាក់ឯង មិនសូវសប្បាយធ្វើឲ្យមានឱជារសតិច, ដែលថាមិនបានសុខ សំគាល់សេចក្ដីថា ខ្វះសេចក្ដីរីករាយក្នុងវេលាកំពុងស៊ី តែកាលបើសម្លឹងដល់ធម៌វិញ បានសេចក្ដីថា ជាមនុស្សមានអធ្យាស្រ័យបង្អៀត មិនបានចែកចាយផ្សាយដល់មិត្តភក្តិក្នុងស្រុកភូមិធ្វើខ្លួនឲ្យជាអ្នកបង្អៀតបង្អល់ដោយគ្មានមិត្តភក្ដិដូច្នេះជាដើម នឹងគួរអធិប្បាយសុភាសិតដូច្នេះឲ្យជួនទៅក្នុងផ្លូវលោកព្រមទាំងមានធម៌លាយឡំផង អធិប្បាយត្រឹមជាន់ទាបក៏ជាការសមនឹងរូបសុភាសិតហើយ ។

www.elibraryofcambodia.org

សុភាសិតដែលពោលដល់ធម៌យ៉ាងកណ្ដាល គឺមិនសំគាល់ដល់លោកុត្តរធម៌ទេ តែខ្ពស់ជាងសុភាសិតដែលបានលើកគួយ៉ាងមកហើយ

ក៏គប្បីបន្ថិតសេចក្តីអធិប្បាយឲ្យខ្ពស់ឡើងបន្តិចទៀត ដូចសុភាសិតថា “អក្កោធេន ជិនេ កោធំ, គប្បីឈ្នះសេចក្តីក្រោធ (របស់គេ) ដោយការមិនក្រោធ (របស់យើង)” ដូច្នេះ គួរអធិប្បាយបរិយាយធម៌ឲ្យខ្ពស់ឡើងបន្តិចទៀត តែមិនដល់លោកុត្តរធម៌ទេ គ្រាន់តែត្រឹមលោកិយក៏បានហើយ, ចំណែកសុភាសិតនឹងសំដែងគុណឬទោសនោះ ស្រេចតែអធិប្បាយតាមសមគួរដល់សេចក្តី លាយឡំលោកនឹងធម៌ព្រមទាំងគូយ៉ាងផង បែបនេះហៅថាយ៉ាងកណ្តាល ។

សុភាសិតដែលពោលដល់ធម៌យ៉ាងខ្ពង់ខ្ពស់ ដូចថា “និព្វានំ បរមំ សុខំ, និព្វានជាសុខយ៉ាងក្រៃលែង” ដូច្នេះ ក៏គួរអធិប្បាយឲ្យខ្ពស់ឡើងតាមឋានៈសុភាសិតឲ្យជួនទៅក្នុងផ្លូវលោកុត្តរ តាមសេចក្តីនិយម, សុភាសិតដូច្នេះ មិនគួរអធិប្បាយផ្លូវលោកលាយឡំទេ ព្រោះជាហេតុធ្វើឲ្យតម្លៃធម៌ថយចុះទៅវិញ ។ តាមពិតការកំណត់របៀបដូច្នេះដូចជាមិនត្រូវ ព្រោះខ្ញុំបានពោលទុកក្នុងលំនាំដើមថា លោកនឹងធម៌ប្រាសចាកគ្នាមិនបាន សូម្បីសុភាសិតដែលជាលោកុត្តរធម៌ សំគាល់សេចក្តីថាធម៌ដែលផុតលោកមិនជាប់នឹងលោកក៏ពិត តែកាលបើមិនអាស្រ័យលោកជាភូមិឋានរ៉ប់រងហើយ ធម៌ក៏ពុំអាចនឹងតាំងនៅបានដែរ, មែនពិត! ធម៌ជាសភាវៈមិនមានរូប មាននៅជានិច្ច តែបើមិនមានលោកទ្រទ្រង់ទុក ធម៌នឹងអំណោយប្រយោជន៍ដូចម្តេច ប្រសិនបើយើងនឹងអធិប្បាយលោកជាគ្រឿងរ៉ប់រង

www.elibraryofcambodia.org

ធម៌លាយឡំនឹងលោកផង ក៏ឃើញថាមិនជាអ្វី តែដើម្បីនឹងលើកតម្លៃធម៌ឲ្យខ្ពស់ផុត ក៏គួរបែរមកអធិប្បាយក្នុងផ្លូវដែលខ្ពស់ បែបនេះហៅ-ថាយ៉ាងខ្ពង់ខ្ពស់ ។

គោលកំណត់នេះ មានកំណត់នៅក្នុងសុភាសិតមិនជារបស់លំបាកប៉ុន្មាន កាលកំណត់បានហើយក៏បរិយាយទៅតាមគោលសេចក្ដី ឲ្យសមនឹងថ្នាក់របស់អ្នករៀបរៀងសេចក្ដីកែសុភាសិត ។

១- “ បំណែកប្រែកបផ្សេង ៗ ” នោះ គឺបេះអធិប្បាយសេចក្ដីនៃសុភាសិតឲ្យជាក់ច្បាស់ ដែលហៅថាបេះរាយសេចក្ដីឲ្យបែក បេះការ

www.elibraryofcambodia.org

ដកបន្ទាត់ សរសេរអក្សរឲ្យស្អាតបាតត្រឹមត្រូវអានបានងាយ បេះប្រើពាក្យពេចន៍ បេះពណ៌នាសេចក្ដីលើកហេតុផលឲ្យអ្នកអានចូលចិត្តពាក្យពេចន៍របស់ខ្លួនបាន រហូតដល់ការប្រើគ្រឿងសំគាល់ផ្សេង ៗ ដែលរួមនៅក្នុងអត្ថបទដែលបានបរិយាយមកក្នុងលំនាំដើមហើយ , របស់អម្បាលនេះជានាទីរបស់ធម្មាចារ្យប្រដៅណែនាំ វេលាដែលយកទៅប្រើការពិតៗនោះ គួរឲ្យបានជារបៀបរៀបរយ ប្រើពាក្យអធិប្បាយល្មមសមគួរ គឺមិនវែងពេកខ្លីពេក (យ៉ាងច្រើន ៤ទំព័រ យ៉ាងតិច ២ទំព័រកន្លះក្រដាសពុម្ព) ។

មួយទៀត, ការតភ្ជាប់សុភាសិតជារបស់សំខាន់ពន់ពេក បើនឹងឲ្យស្អាតជំនាញល្អឡើង ត្រូវត្រឡប់ទៅអានម្ដងទៀត ធ្វើសេចក្ដីចូលចិត្តឲ្យត្រូវត្រង់ ទើបនឹងសម្រេចប្រយោជន៍តាមប្រាថ្នា ។ សេចក្ដីដែលខ្ញុំ

ពោលមកនេះ ជាវិធីការប្ត្រទិស្តី គឺគ្រាន់តែជាពាក្យណែនាំដោយមតិរបស់ខ្ញុំម្នាក់ឯង មិនមែនជាប្រតិបត្តិការទេ ចំណែកការធ្វើពិតៗជានាទីរបស់អ្នកសិក្សាដោយព្រមព្រៀងគ្នានឹងអ្នកណែនាំ ជួនកាលអ្នកប្រដៅណែនាំអាចមានវិធីផ្លាស់ប្តូរល្អវិសេសជាងនេះ ខនោះជាបុញ្ញលាភដ៏ប្រសើររបស់អ្នកសិក្សា, តែទោះយ៉ាងណាក្តី ខ្ញុំបរិយាយតែងសេចក្តីសុភាសិតទុកជាគំរូតួយ៉ាងដោយវិធីច្រើនប្រការនៅខាងមុខតទៅទៀត, អ្នកសិក្សាចូរជ្រើសរើសពិចារណាតាមនោះ អាចកើតឈ្លាសវៃតែងសេចក្តីបានល្អវិសេសជាងដែលខ្ញុំទុកទៅទៀត ។ ខ្ញុំសូមបញ្ចប់ពាក្យណែនាំនេះដោយចេតនាដ៏ល្អក្រៃលែងត្រឹមប៉ុណ្ណោះ ។

www.elibraryofcambodia.org

# នមោ សម្ពុទ្ធស្ស

## ១- អប្បមាទ ( មិនប្រមាទ )

អប្បមាទោ អមតំ បទំ

សេចក្ដីមិនប្រមាទ ជាផ្លូវមិនស្លាប់

ព្រះពុទ្ធភាសិតនេះ ព្រះបរមសាស្ដាទ្រង់សំដែងអំពីគុណតម្លៃរបស់ អប្បមាទ(១)ថាជាផ្លូវមិនស្លាប់ ; អប្បមាទប្រែថាសេចក្ដីមិនធ្វេសប្រហែស បានដល់សេចក្ដីមិនវង្វេងស្រវឹងក្នុងលាភ យស សរសើរ សុខ និងក្នុងវ័យ ក្នុងការមិនមានរោគ ក្នុងជីវិត ឬថាបានដល់ការមិនភ្លេចស្មារតី ការមិនវង្វេងក្នុងទីគ្រប់ស្ថាន ។ អប្បមាទនេះលោកពោលថា ជាផ្លូវមិនស្លាប់ ។

www.elibraryofcambodia.org

ត្រង់ដ៏ជរលោក: បុគ្គលដែលប្រមាទខ្វះស្មារតីក្នុងករណីយកិច្ចដែលខ្លួនធ្វើ រមែងធ្វើឲ្យវិនាសទាំងទ្រព្យសម្បត្តិនិងជីវិត ដូចជាប្រកបពាណិជកិច្ច មិនយកចិត្តទុកដាក់ក្នុងជំនួញ បេះតែធ្វើទៅដោយមិនស្គាល់ កាលៈ ទេសៈ រមែងបានទទួលការខាតបង់ពុំខាន ឬបំណែកខាងរាង

---

១ អប្បមាទដែលគួរលើកយកមកអធិប្បាយគឺ គួរធ្វើសេចក្ដីមិនប្រមាទក្នុងទី ៤ ស្ថាន គឺៈ ១-កាយទុច្ចរិតប្បហាន ក្នុងការលះកាយទុច្ចរិតប្រព្រឹត្តកាយសុចរិត; ២-វចីទុច្ចរិតប្បហាន ក្នុងការលះវចីទុច្ចរិតប្រព្រឹត្តវចីសុចរិត; ៣-មនោទុច្ចរិតប្បហាន ក្នុងការលះមនោទុច្ចរិតប្រព្រឹត្តមនោសុចរិត; ៤-មិច្ឆាទិដ្ឋិប្បហាន ក្នុងការលះសេចក្ដីឃើញខុសធ្វើសេចក្ដីឃើញឲ្យត្រូវ;

មួយទៀតគួរប្រយ័ត្នចិត្តកុំឲ្យវង្វេងក្នុងទី ៤ ស្ថាន គឺៈ ១-រជនីយៈ កុំត្រេកអរក្នុងអារម្មណ៍ដែលនាំឲ្យមានតម្រេក; ២-ទោសនីយៈ កុំខឹងក្នុងអារម្មណ៍ដែលនាំឲ្យខឹង; ៣-មោហនីយៈ កុំវង្វេងក្នុងអារម្មណ៍ដែលនាំឲ្យវង្វេង ; ៤-មទនីយៈ កុំស្រវឹងក្នុងអារម្មណ៍ដែលនាំឲ្យស្រវឹង ។

កាយវិញ បើមិនយកចិត្តទុកដាក់បរិហាររក្សា ចេះតែក្លាហានភ្លើតភ្លើនទៅ ប្រកបហេតុដែលជាផ្លូវនាំឲ្យកើតរោគផ្សេង ៗ នោះរោគដែលនៅមិនទាន់កើតក៏រមែងកើតឡើង ដែលកើតឡើងហើយក៏រឹងរឹតតែកំរើកធ្ងន់ឡើង ដរាបដល់សាបសូន្យជីវិតទៅក្នុងទីបំផុត ៗ ចំណែកអ្នកមិនប្រមាទ ប្រកបកិច្ចដោយប្រុងប្រយ័ត្ន រហូតដល់ចេះបរិហាររក្សារាងកាយមិនបណ្តោយឲ្យរោគភ័យកំរើកទៅ រមែងបានទទួលផលដ៏បរិបូណ៌ សូម្បីជីវិតរបស់ខ្លួនក៏តាំងនៅដរាបដល់កាលអាយុខ័យ ព្រោះសេចក្តីមិនប្រមាទជួយឧបត្ថម្ភមិនឲ្យស្លាប់ក្នុងពាក់កណ្តាលអាយុ, ហេតុនេះ លោកទើបពោលថា "សេចក្តីមិនប្រមាទ ជាផ្លូវមិនស្លាប់" ។

ក្នុងវដ្ដធម៌: ការវិលវល់នៅក្នុងសង្សារវដ្ដមានដរាបណា ការកើតការស្លាប់ក៏មានដរាបនោះ ៗ ធម៌ដែលផុតចាកការកើតការស្លាប់ក៏គឺព្រះនិព្វាន ដែលលោកហៅក្នុងទីនេះថាអមតៈ ឬអម្ឫត ប្រែថាមិនស្លាប់ ជាឈ្មោះរបស់ព្រះនិព្វាន(១) ៗ ឯការដែលបុគ្គលនឹងបានសម្រេចនូវអមតៈនេះ ក៏ត្រូវអាស្រ័យសេចក្តីមិនប្រមាទជាផ្លូវដើរ ដែលអ្នកប្រាជ្ញលះចេញមិនបានដោយដាច់ខាត ព្រោះអប្បមាទមានគុណានិសង្សច្រើនប្រការ សម្តេចព្រះលោកុត្តមាចារ្យក៏បានត្រាស់សរសើរទុកថា "បណ្តា-

---

១និព្វានមាន ២ គឺ ១. សឧបាទិសេសនិព្វានរលត់កិលេសនៅសល់បញ្ចក្ខន្ធ, ២ អនុបាទិសេសនិព្វាន រលត់ទាំងកិលេសទាំងបញ្ចក្ខន្ធ ។



www.elibraryofcambodia.org

ខ្សែគ្នាទៅមិនដាច់ កម្មឯណាដែលយើងធ្វើបានទុកាសមុន កម្មនោះរមែងស្នងផលមុនតាមពេលតាមសម័យ រួមសេចក្ដីថាផលផ្សេងៗ ដែលប្រាកដថាជាផលរបស់កម្មដោយត្រង់ មិនមែនដោយហេតុដទៃទេ ដូចបុគ្គលម្នាក់កើតមក ជាអ្នកមានអាយុវែង ស្តុកស្តម្ភដោយទ្រព្យសម្បត្តិ មានភរិយាបុត្តធីតាក៏នៅក្នុងឱវាទ មិនប្រព្រឹត្តល្មើស មានមនុស្សរាប់អានមានកិត្តិស័ព្ទក្រអូបខ្ចរខ្ចាយទៅក្នុងទិសានុទិស មានសតិបញ្ញារឹងប៉ឹងដូច្នេះក៏ជាផលរបស់កុសលកម្មដែលខ្លួនបានធ្វើមក ៗ ចំណែកបុគ្គលម្នាក់ទៀតមានអាយុតិច កម្លាំងរាងកាយមិនសម្បូររោគាព្យាធិបៀតបៀន មិនបានទទួលសេចក្ដីសុខ· ទ្រព្យសម្បត្តិក៏ស្ដួចស្ដើង ជាមនុស្សលំបាកទ័លក្រ មានភរិយាបុត្តធីតាក៏មិននៅក្នុងឱវាទ ប្រព្រឹត្តខ្លួនជាអ្នកបំផ្លិចបំផ្លាញធ្វើឲ្យវង្សត្រកូលវិនាសសាបសូន្យ សូម្បីខ្លួនឯងក៏គ្មានសេចក្ដីជឿទុកចិត្តរបស់មនុស្សទូទៅ ត្រូវគេមើលងាយមិនមានសតិបញ្ញា ជាអ្នកល្ងង់ខ្លៅនេះឯងក៏ជាផលរបស់អកុសលកម្ម ដែលខ្លួនបានធ្វើមកដូចគ្នា ៗ

សរុបសេចក្ដីថា សត្វលោកគ្រប់ពួកសុទ្ធតែប្រែប្រួលប្រព្រឹត្តទៅតាមអំណាចកម្ម, កម្មជាអ្នកការពារ កម្មជាគ្រឿងចង្អុលបង្ហាញពន្លឺឬសេចក្ដីងងឹតនៃជីវិត ដូចកញ្ចក់សម្រាប់មើលរូបរាងលក្ខណៈដូច្នោះឯង ព្រោះហេតុនោះ លោកទើបពោលថា "កម្មុនា វត្តតី លោកោ,

www.elibraryofcambodia.org

សត្វលោក តែងប្រព្រឹត្តទៅតាមកម្ម” ដូច្នេះឯង ។

## ៣. ចិត្ត

គោលបត្តំ យថា បរិហារេយ្យ

ឯវំ សចិត្តមនុរក្ខេ សតិយា

បុគ្គលគប្បីរក្សាចិត្តរបស់ខ្លួនដោយសតិ ដូចជាគេរក្សាភាជន៍ដែលពេញដោយប្រេង ។

ចិត្តជានាមធម៌មួយយ៉ាង ដែលមិនមានខ្លួនប្រាណ នឹងសណ្ឋានទ្រង់ទ្រាយយ៉ាងដូចម្តេច តែមានសេចក្តីដឹងក្នុងអារម្មណ៍ផ្សេងៗ ដែលកើតមកអំពីអាយតនៈខាងក្រៅ [illegible] របស់ចិត្ត គឺសម្រាប់គិតនឹកក្នុងកិច្ចការទាំងពួង ។ ឯចិត្តនេះរមែងជាធំជាងអ្វីទាំងអស់ក្នុងរាងកាយរបស់បុគ្គលនីមួយៗអវយវៈដទៃៗមានដៃជើងជាដើម រមែងនៅក្នុងអំណាចរបស់ចិត្តទាំងអស់ សូម្បីនឹងប្រែប្រួលផ្លាស់ប្តូរឥរិយាបថទៅត្រឹមណា ក៏បង្ហាញឲ្យឃើញថាជាអាការរបស់ចិត្តត្រឹមនោះ, ចិត្តជាអ្នកបង្គាប់ការឲ្យធ្វើ ហើយការធ្វើនោះអាចកើតទាំងល្អនឹងអាក្រក់ ចិត្តដូចមនុស្សអ្នកទាញ កាយដូចភាពយន្ត, ភាពយន្តនឹងលោតកំល្អយ៉ាងដូចម្តេច ក៏ស្រេចតែអំពីអ្នកទាញ ចិត្តក៏ដូចគ្នា អាការកាយវាចាដែលល្អ ក៏បង្ហាញឲ្យឃើញថាមានទឹកចិត្តល្អដូច្នោះដែរ ។

តាមធម្មតា ចិត្តជាធម្មជាតផូរផង់មិនកករល្អក់ លុះមានឧបក្កិលេស

www.elibraryofcambodia.org

គឺគ្រឿងសៅហ្មងចូលទៅប៉ះពាល់ហើយ ក៏រមែងសៅហ្មងទៅបាន ដូចពណ៌ផ្សេងៗ មានពណ៌ខៀវជាដើម ឬផង់ធូលីចូលទៅប៉ះពាល់សំពត់ដែលស្អាតហើយ រមែងធ្វើឲ្យសំពត់ជាមន្ទិលទៅបានដូច្នោះ ។ លុះកាលមន្ទិលចូលទៅជាប់ដួងចិត្តហើយ ចិត្តក៏បង្គាប់ឲ្យកាយវាចាធ្វើនឹងនិយាយជាដើម គង់ផ្ទុយទៅវិញមានការប្រព្រឹត្តខុសផ្លូវកាយនឹងវាចា ធ្វើឲ្យមនុស្សបានទទួលសេចក្ដីវិនាសនឹងរាប់ប្រមាណមិនបាន ។ ព្រោះដូច្នោះ អ្នកប្រាជ្ញទាំងឡាយមានព្រះសម្មាសម្ពុទ្ធជាដើម ទើបទ្រង់ប្រដៅឲ្យទូន្មានចិត្ត ធ្វើចិត្តឲ្យប្រាសចាកគ្រឿងសៅហ្មង ឲ្យផូរផង់គ្រប់កាលសម័យសម្រាប់នឹងបានបង្គ [illegible] ស់ដែលល្អ មិនវិនាស www.elibraryofcambodia.org ដើម្បីឲ្យបានទទួលសេចក្ដីសុខជាផលរបស់សេចក្ដីល្អ ដែលកើតអំពីការទូន្មានចិត្ត ព្រោះចិត្តដែលទូន្មានល្អហើយរមែងនាំសុខមកឲ្យ សមតាមទេសនាន័យដែលមានមកក្នុងធម្មបទខុទ្ទកនិកាយថា “ចិត្តំ ទន្តំ សុខាវហំ, ចិត្តដែលទូន្មានហើយ នាំសុខមកឲ្យ” ដូច្នេះ ។ តែការដែលទូន្មានចិត្តគ្រប់គ្រងចិត្តជាការក្រៃពន់ពេក ព្រោះចិត្តជាធម្មជាតដែលប្រែះនរៀលត្រឡប់ត្រឡិនយ៉ាងរហ័ស បុគ្គលរក្សាបានដោយកម្រ លំបាកនឹងហាមឃាត់បាន អាការរបស់ចិត្តនោះលោកប្រៀបដូចពានរ តាមធម្មតារបស់ពានរជាសត្វរពឹស មិនមានសេចក្ដីស្ងប់នឹងនួនសូម្បីបន្តិចបន្តួចសោះដូចម្ដេចមិញ ចិត្តក៏ដូច្នោះដែរ ។

ក្នុងវេលាចិត្តរព្វេក ក៏ត្រូវមានឧបាយលួងលោមឲ្យរីករាយជានិច្ច ឬចិត្តរីករាយហួសពេកទៅក៏ត្រូវរកឧបាយបង្ក្រាប មិនឲ្យរាយមាយហួសហេតុ ខណៈណាចិត្តនឹងនួនស្ងប់រម្ងាប់ ត្រូវរក្សាគ្រប់គ្រងដោយប្រើសតិជាកីលៀង គឺត្រូវប្រើសតិត្រួតត្រាពិនិត្យពិច័យគ្រប់អាការរបស់ចិត្ត មិនបណ្តោយឲ្យខូចទៅបាន ដូចជាគេរក្សាភាជន៍ដែលពេញព្រៀបដោយប្រេងដូច្នោះ ព្រោះប្រេងដែលពេញក្នុងភាជន៍ វេលានឹងលើកភាជន៍ត្រូវប្រយ័ត្នជាពិសេស ដើម្បីការពារកុំឲ្យកំពប់ពត់រាយ ឬធ្លាក់ប្រឡាក់វត្ថុដទៃ ចិត្តក៏ដូចគ្នា បើមិនមានការប្រុងប្រយ័ត្នទេ តែងត្រាច់ទៅរកអារម្មណ៍ ដែលជាទីតាំងនៃលោភៈខ្លះ កោធៈខ្លះ មោហៈខ្លះ កាលអារម្មណ៍អម្បាលនេះមកចោមរោមហើយ ផលអាក្រក់នឹងកើតឡើងជាច្រើន ព្រោះដូច្នោះក្នុងសុភាសិតនេះ លោកបើបប្រដៅឲ្យរក្សាចិត្តរបស់ខ្លួនដោយសតិ ដើម្បីឲ្យប្រព្រឹត្តនៅក្នុងផ្លូវដែលល្អ ដូចរថដែលមាននាយសារថីបរដូច្នោះ ។

www.elibraryofcambodia.org

បំណែកផលដែលកើតអំពីការរក្សាចិត្តគ្រប់គ្រងចិត្តនោះ រមែងប្រព្រឹត្តទៅដើម្បីសេចក្តីសុខដោយបំណែក ១ ។ ប្រៀបយ៉ាងងាយៗ សតិដូចមាតាបិតា ឬកីលៀងអ្នកមានអធ្យាស្រ័យល្អ ស្គាល់ខុសនឹងត្រូវ តែងបង្គាប់បុត្រធីតាឬក្មេងដែលខ្លួនចិញ្ចឹមឲ្យប្រព្រឹត្តផ្លូវល្អមិនវិនាស ក្មេងដែលមិនទាន់ដឹងក្តី កាលអ្នកពិភក្តិរក្សាមានអធ្យាស្រ័យល្អអាក្រក់យ៉ាងណា និស្ស័យនោះក៏ចាប់ចិត្តឲ្យធ្វើតាម ដូចវល្លិ៍នៅជិតដើមឈើណាក៏រុំព័ទ្ធ

ឈើនោះ ដើមឈើមានលក្ខណៈសណ្ឋានយ៉ាងណា វល្លិ៍ក៏មានលក្ខណៈ សណ្ឋានយ៉ាងនោះដែរ សូម្បីកាយនឹងវាចាក៏ដូចគ្នា ស្រេចតែចិត្តនឹងបង្គាប់ឲ្យប្រព្រឹត្តទៅ ៗ ព្រោះដូច្នោះកាលបើចិត្តនៅក្នុងអំណាចការត្រួតត្រារបស់សតិដោយម៉ឺងម៉ាត់ហើយ កិច្ចការដែលធ្វើ ពាក្យដែលនិយាយប្រព្រឹត្តទៅក្នុងផ្លូវដែលល្អមិនវិនាសរមែងនាំសុខមកឲ្យជាច្រើន អារម្មណ៍ក៏តាំងនៅជាប្រក្រតីមិនទាបៗ ខ្ពស់ៗ មិនរញ្ជួក រីករាយជានិច្ច ព្រោះស្គាល់ឧបាយរក្សាចិត្តដោយសតិ, សតិជាអ្នកត្រួតត្រាមិនឲ្យអាការរបស់ចិត្តប្រែផុតចាកការត្រួតត្រារបស់ខ្លួនបាន ទើបមានផលដ៏បរិបូណ៌ដោយសេចក្ដីសុខ [illegible] កើតនៃសុខគ្រប់ប្រការ, ព្រោះការរក្សាចិត្តមានគុណតម្លៃដ៏ទូលាយដូច្នេះ ទើបមានភាសិតប្រាកដថា "តេលបត្តំ យថា បរិហរេយ្យ ឯវំ សចិត្តមនុរក្ខេ សតិយា, បុគ្គលគប្បីរក្សាចិត្តរបស់ខ្លួនដោយសតិ ដូចជាគេរក្សាភាជន៍ដែលពេញដោយប្រេង" ដូច្នេះឯង ។

## ៤. ក្រោធ

កោធជាតោ បរាភវោ

អ្នកមានសេចក្ដីក្រោធកើតហើយ ជាអ្នកវិនាស

ក្នុងធម្មភាសិតនេះ សំដែងផលអាក្រក់ដែលកើតឡើង ព្រោះមនុស្សក្រោធ លុះត្រាតែដុតបំផ្លាញបុគ្គលអ្នកក្រោធឲ្យវិនាសខ្លួន រួម

www.elibraryofcambodia.org

សេចក្ដីថា សេចក្ដីវិនាសទាំងឡាយរបស់បុគ្គលកើតឡើងអំពីហេតុ គឺ-បុគ្គលនោះកើតក្រោធឡើងហើយ ។

មែនពិត ! បុគ្គលដែលត្រូវសេចក្ដីក្រោធគ្របសង្កត់ធ្វើឲ្យចិត្តកករល្អក់ អន្ទះសា គ្នាន់ខ្នាញ់ គិតទឹងធ្វើទឹងនិយាយ ដោយអាការដ៏អាស្រូវកាស ចិត្តមិនល្អ គិតអាឃាតព្យាបាទប្រទូសរ៉ាយបំផ្លាញអ្នកដទៃ ដែលជាហេតុធ្វើខ្លួនឲ្យវិនាសទាំងអស់ ក្រោធកើតឡើងហើយយ៉ាងខ្លាំងក្លា ផុតសេចក្ដីអធ្យាស្រ័យអត់អាចនៃការរំងាប់របស់សតិដែលឲ្យធ្វើអ្វីៗបានតាមសេចក្ដីពេញចិត្ត ដូចនិយាយអាស្រូវកាស ជេរពោលអ្នកដទៃបង្កសេចក្ដីវិវាទប្រទូសរ៉ាយអ្នកដទៃ ពាល់តែបានបំ[illegible]សេចក្ដីអាក្រក់ដ៏-ថោកទាបណាស់សន្មតថាផុតកំដៅ ឬបំផ្លាញគេបានសមតាមសេចក្ដីក្រោធរបស់ខ្លួន, ផលនៃសេចក្ដីអាក្រក់នោះនឹងទៅឯណា? នឹងត្រូវតាមដុតកំដៅខ្លួនក្នុងកាលជាខាងក្រោយ សមដូចភាសិតដែលមានមកក្នុងធម្មបទខុទ្ទកនិកាយថា "បច្ឆា តបតិ ទុក្កដំ, សេចក្ដីអាក្រក់តែងដុតកំដៅក្នុងកាលជាខាងក្រោយ" នេះឯងជាការសំដែងដល់លក្ខណៈរបស់បុគ្គលដែលកើតក្រោធឡើងហើយ រមែងមានអាការដូច្នេះ បុគ្គលមានសេចក្ដីក្រោធកើតហើយ នឹងជាអ្នកវិនាសបានយ៉ាងដូចម្ដេច ?

មនុស្សដែលមានសេចក្ដីក្រោធកើតឡើងហើយនោះ នឹងជាអ្នកវិនាសពិតៗ ដូចបរិយាយតទៅ គឺរូបពណ៌សម្បុររបស់បុគ្គល មុនដែលមិន

ទាន់មានសេចក្ដីក្រោធ រមែងផូរផង់ញញឹមញញែមស្រស់បស់ ជាទីស្រ-
ឡាញ់របស់អ្នកដែលបានជួបឃើញ លុះសេចក្ដីក្រោធកើតហើយ ធ្វើឲ្យ
អាការល្អនោះ ៗ វិនាសបាត់ទៅអស់ គឺត្រឡប់មានអាការក្រេវក្រោធ
មុខក្រហមសំដែងមុខយក្ស មុខមារ ស្ទើរតែនឹងហែកសាច់ហែកស្បែក
របស់មនុស្សដែលខ្លួនក្រោធ នេះឯងសំដែងយ៉ាងទាបដែលធ្វើឲ្យវិនាស
បាន គឺពណ៌សម្បុរមុខដែលធ្លាប់តែញញឹមញញែមស្រស់បស់ ត្រឡប់
ជាក្រញេវក្រញូវមិនជាទីស្រឡាញ់, ហួសនោះទៅទៀតផុតសេចក្ដីរាំងរា
របស់សតិ បណ្ដោយឲ្យគ្របសង្កត់ទាល់តែដល់កំរិតអាចប្រទូសរ៉ាយអ្នក
ដទៃ ដោយកាប់ចាក់ឬបាញ់ឲ្យស្លាប់ជាដើម តទៅរមែងឃើញសេចក្ដី
www.elibraryofcambodia.org
វិនាសរត់ចូលមកជិតខ្លួនគ្រប់ខណៈ ខដើមនឹងត្រូវឃុំឃាំង ត្រូវគេប្ដឹង
ខ្លួនក៏ត្រូវរកមេធាវី ( ស្មាក្ដី ) ជួយកែសម្រួលរឿងផ្សេងៗ ត្រូវបង់ប្រាក់
តម្លៃមេធាវីនឹងប្រដាប់ក្ដីដទៃទៀតជាច្រើន , ហួសនោះទៅទៀតកូនប្រពន្ធ
ញាតិមិត្របងប្អូនមើលមុខគ្នាលែងត្រង់ ឬលក់បញ្ចាំផ្ទះ-ដី-គ្រឿងអលង្ការ
របស់ដែលមានយកប្រាក់មកចាយវាយ ការជួញក្ដីមិនមានផ្លូវដែលល្អ
សោះឡើយ មានតែផ្លូវបង់ខាតម្យ៉ាង ដូចបុរាណភាសិតថា “ ធ្ងន់នៅថ្ម
ក្រនៅក្ដី គឺថា របស់ធ្ងន់គ្មានអ្វីជាងថ្ម ហេតុនាំឲ្យក្រគ្មានអ្វីជាងក្ដី ”
នេះមានសេចក្ដីពិតជាច្រើន យ៉ាងនេះជាអាការវិនាស បើខ្លួនធ្វើគេមែនៗ
មានបន្ទាល់ពរ័ក្ខបានយ៉ាងគ្រប់គ្រាន់ នឹងគេចវាងអំពីច្បាប់បានដូចម្ដេច

សោត គង់នឹងត្រូវស្លាប់ទៅតាមគ្នា នេះជាសេចក្តីវិនាសទាំងខ្លួនឯង នឹងមនុស្សដែលជាប់ទាក់ទងមិនមានថ្ងៃដែលនឹងរើខ្លួនឡើងបាន គង់បណ្តាយឲ្យអ្នកដែលជាប់សាច់ឈាមក្តៅក្រហាយផង វិនាសទាំងទ្រព្យសម្បត្តិ វិនាសទាំងខ្លួនឯង គឺត្រូវប្រហារជីវិត នេះជាផលរបស់មនុស្សដែលក្រោធហើយ រមែងវិនាសដូច្នេះ ហេតុនោះទើបសមនឹងសុភាសិតខាងដើមថា" ក្រោធជាគោ បពកពៅ, អ្នកមានសេចក្តីក្រោធកើតហើយ ជាអ្នកវិនាស" ដូច្នេះឯង ។

## ៥. ភរិយា

ភត្តុ មនាបញ្ចរតិ

www.elibraryofcambodia.org

ភរិយាល្អ តែងប្រព្រឹត្តជាទីពេញចិត្តរបស់ភស្តា

កងសុភាសិតនេះ សំដែងថាភរិយាល្អនោះ ត្រូវប្រព្រឹត្តឲ្យជាទីពេញចិត្តថ្លើមរបស់ភស្តាគឺស្វាមី ។

ភរិយា ប្រែតាមព្យញ្ជនៈថា ស្ត្រីដែលបុរសគប្បីចិញ្ចឹម,តាមអត្ថបានដល់ស្ត្រីដែលជាភរិយារបស់បុរសដោយឋានៈណាៗក្តី ត្រូវតែជាមនុស្សល្អ ប្រព្រឹត្តខ្លួនឲ្យល្អ គឺឲ្យជាទីពេញចិត្តរបស់ស្វាមី, ខនេះធ្វើបានដោយលំបាកដូចពាក្យថា "សត្វខ្វះបួលចិត្តសៅដោយវៀកពីគ្នា" ស្វាមីភរិយានឹងដឹងការយកចិត្តយកថ្លើមចំពោះគ្នានោះ ត្រូវអាស្រ័យនៅរួមគ្នាអស់កាលយូរ គំណត់សំគាល់និស្ស័យអធ្យាស្រ័យរបស់គ្នានឹងគ្នា ហើយអនុលោមចូលទៅរកគ្នា ជានាទីយ៉ាងក្រៃលែងរបស់ភរិយា ដែលត្រូវ

ស្គាល់និស្ស័យអធ្យាស្រ័យរបស់ស្វាមីយ៉ាងពិតប្រាកដ ខ្លួននឹងបានប្រតិបត្តិដោយយកចិត្តឲ្យបានត្រូវតែ "អណ្ដាតនឹងធ្មេញត្រូវប៉ះទង្គិចគ្នាជានិច្ច" ស្វាមីភរិយាក៏ដូចគ្នាដែរ ត្រូវអាស្រ័យអនុលោមបដិលោម ទើបនឹងបន្ធូរបន្ថយទម្ងន់ឲ្យស្រាលបាន នៅជាមួយគ្នាជាសុខ ក្នុងសិង្គាលោ-វាទសូត្រ ព្រះសាស្ដាទ្រង់សំដែងលក្ខណៈរបស់ភរិយាល្អទុក ៥ ប្រការ គឺចាត់ចែងការងារដោយល្អ១, សង្គ្រោះញាតិខាងស្វាមីដោយល្អ ១, មិនប្រព្រឹត្តកន្លងចិត្តស្វាមី គឺមិនក្បត់ចិត្តប្ដី ១, រក្សាទ្រព្យដែលស្វាមីរកបានមក១, ឧស្សាហ៍មិនខ្ជិលក្នុងកិច្ចការទាំងពួង១, នេះជានាទីដែលភរិយាត្រូវប្រតិបត្តិស្វាមី ។ ចំណែកស្វាមីក៏ត្រូវទំនុកបំរុងភរិយាដោយស្ថាន ៥ យ៉ាងដូចគ្នាដែរ គឺរាប់អានលើកមុខថាជាភរិយា១, មិនប្រព្រឹត្តកន្លងចិត្ត គឺមិនក្បត់ចិត្តភរិយា១, ប្រគល់ភារៈជាធំក្នុងផ្ទះឲ្យ១, ឲ្យគ្រឿងតែងខ្លួន១ ។ ក្នុងសុភាសិតនេះ ប្រាប់ថាសំដែងលក្ខណៈភរិយាដែលល្អ តអំពីនេះនឹងបរិយាយនាទីភរិយាត្រឹមខ្លីៗ គឺបានតំណែងជាមេផ្ទះហើយត្រូវតែមើលកិច្ចការគ្រប់យ៉ាងជំនួសស្វាមី ព្រោះស្វាមីរមែងមានការងារក្រៅផ្ទះជាច្រើន មិនសូវមានពេលយកចិត្តទុកដាក់ចំពោះការងារខាងផ្ទះទេ ការងារខាងផ្ទះធ្លាក់ទៅជានាទីរបស់ភរិយា ព្រោះដូច្នោះ ភរិយាទើបត្រូវចាត់ចែងការងារឲ្យរៀបរយ ហើយកាលស្វាមីធ្វើការងារក្រៅផ្ទះ ត្រូវមានអ្នកជួយធ្វើកិច្ចការ ទើបនឹងសម្រេចទៅបាន ត្រូវមានមនុស្សដែលជឿទុកចិត្តជាអ្នកជួយ ភរិយា

www.elibraryofcambodia.org

ត្រូវយកចិត្តទុកដាក់នឹងមនុស្សដូច្នោះផង តែកុំយកចិត្តទុកដាក់ហួសពេកគឺ កុំធ្វើឲ្យដល់ទៅជាទីរង្កៀសសង្ស័យរបស់ស្វាមីថាខ្លួនប្រព្រឹត្តកន្លងចិត្តគេ ព្រោះការប្រព្រឹត្តកន្លងចិត្តស្វាមី ជាខដែលវិនាសរបស់ស្ត្រីយ៉ាងក្រៃលែង គេនាំគ្នាលើកទោសថាជាមនុស្សបោកទាបអាក្រក់ មិនមានអ្វីអាក្រក់ជាងឡើយ ព្រោះដូច្នោះ ខនេះភរិយាដែលល្អមិនត្រូវធ្វើនឹងប្រយ័ត្នឲ្យណាស់កង្វៀងនេះ ហើយវត្ថុឯណាដែលស្វាមីរកបានមកត្រូវសន្សំរក្សាទុកឲ្យល្អ មិនឲ្យកើតអន្តរាយ សាបសូន្យវិនាសទៅដោយផ្លូវដទៃ ដូចយ៉ាងគេហៅថា "កញ្ជើធ្លុះ" គប្បីខំស្វាហាប់ខ្មីឃ្មាតធ្វើការងារដោយមិនប្រាថ្នាតែត្រឹមអាស្រ័យប្ដីបរិភោគទេ ត្រូវធ្វើដោយជួយគាំទ្រគ្នា២នាក់ កិច្ចការក៏នឹងចំរើនរុងរឿងឡើងបាន ព្រោះអាស្រ័យសាមគ្គីរវាងស្វាមី ភរិយា មានសេចក្ដីខំស្វាហាប់ខ្មីឃ្មាតរឹងប៉ឹងមិនរួញរា រមែងកើបគោយយកទ្រព្យសម្បត្តិជារបស់ខ្លួនបាន សមតាមទេសនាន័យដែលមកក្នុងសគាថវគ្គសំយុត្តនិកាយថា "ឧដ្ឋាតា វិន្ទតេ ធនំ, មនុស្សខំស្វាហាប់ រមែងរកទ្រព្យបាន" ។

តាមដែលបរិយាយមកនេះ ជាលក្ខណៈរបស់ភរិយាល្អ រមែងមានសេចក្ដីប្រព្រឹត្តនឹងរស់នៅយ៉ាងនេះ; នេះនិយាយជាពាក្យកណ្ដាល ៗ តាមគោល នឹងឲ្យត្រូវចិត្តមនុស្សគ្រប់គ្នាមិនបានឡើយ, មនុស្សខ្លះអាចត្រូវការវិចិត្រពិស្ដារជាងនេះ តែទោះយ៉ាងណាក៏ដោយ ក៏មិនផុតអំពីគោលទាំង៥ប្រការនោះ កាលភរិយាមានលក្ខណៈដូច្នោះនឹងប្រព្រឹត្តតាមដូចបាន

www.elibraryofcambodia.org

បរិយាយមក តែងជាទីពេញចិត្តរបស់គស្តាហើយ ព្រោះដូច្នោះ ទើបសម នឹងភាសិតដែលលើកទុកខាងដើមថា: "គត្តុ មនាបញ្ញតិ, ករិយាល្អ តែងប្រព្រឹត្តជាទីពេញចិត្តរបស់គស្តា" ដូច្នេះឯង ។

## ៦.បញ្ញា

### បញ្ញាយតំ វិបស្សតិ

បុគ្គលឃើញច្បាស់នូវសេចក្ដី (របស់ធម៌) ដោយបញ្ញា ;

កង្ធម្មភាសិតនេះសរសើរបញ្ញា ថាជាវិធីតាសម្រាប់ចុះបំភ្លឺនូវសេចក្ដី របស់ធម៌ គឺរសនៃធម៌ដែលនឹងនាំប្រយោជន៍សុខមកឲ្យរាំងផ្លូវលោកនឹងផ្លូវធម៌ៗ ខាងដើមត្រូវបុគ្គលស្គាល់បញ្ញាជាមុនថា បញ្ញាមានលក្ខណៈដូចម្ដេច ទើប មានគុណវិសេសឲ្យឃើញច្បាស់នូវសេចក្ដីរបស់ធម៌បាន ៗ

បញ្ញា បានដល់ធម្មជាតិមួយយ៉ាង ជាគ្រឿងដឹងច្បាស់នូវហេតុនឹង ផលរបស់វត្ថុផ្សេងៗ មាន២ប្រភេទ គឺ លោកិយបញ្ញា, បញ្ញាផ្លូវលោកប្រ- ការ១ លោកុត្តរបញ្ញា, បញ្ញាផ្លូវលោកុត្តរប្រការ១ បញ្ញាទាំង២ប្រការនេះ មានគុណវិសេសម្នាក់ម្នាក់ ផ្លូវលោករមែងអំណោយផលផ្លូវលោក ផ្លូវ លោកុត្តរ រមែងអំណោយផលផ្លូវផុតលោក គឺផុតចាកលោកជាផ្លូវនៃ ព្រះនិព្វាន, នៅព្រៃឈើយៗ បញ្ញានឹងចំរើនលូតលាស់មិនបាន ត្រូវអា- ស្រ័យការប្រកបផ្សំ ឬអប់រំបញ្ញាទើបនឹងចំរើនបាន ឧបាយដែលធ្វើឲ្យ បញ្ញាកើតឡើងនោះមាន ៣ ប្រការគឺ សុតាមយបញ្ញា , បញ្ញាកើត

www.elibraryofcambodia.org

អំពីការស្តាប់ គឺការស្តាប់សម្លេងទាំងឡាយដែលមកប៉ះផ្លូវសោតទ្វារនោះ ៗ បើតាំងចិត្តស្តាប់ឲ្យល្អដោយយកចិត្តទុកដាក់ រមែងកើតបញ្ញា សមនឹងភាសិតក្នុងសគាថវគ្គ សំយុត្តនិកាយថា "សុស្សូសំ លភតេ បញ្ញំ, អ្នកស្តាប់ល្អ រមែងបានបញ្ញា" នេះប្រការ ១. ចិន្តាមយបញ្ញា, បញ្ញាកើតអំពីការត្រិះរិះរកហេតុផលប្រការ ១, ភាវនាមយបញ្ញា, បញ្ញាកើតអំពីការអប់រំដោយការសៀវភៅ ឬ សិក្សាក្នុងវិជ្ជាការនោះ ៗ ប្រការ ១ ៗ បញ្ញាកើតជាកខបាយ ទាំង ៣ ប្រការនេះ យ៉ាងទាប ៗ ក៏ជាត់ជាលោកិយ យ៉ាងខ្ពស់ជាត់ជាលោកុត្តរៈ ។ កាលស្គាល់លក្ខណៈរបស់បញ្ញាហើយ ត្រូវដឹងសេចក្តីរបស់ធម៌តទៅ ៖

www.elibraryofcambodia.org

ក្នុងសុភាសិតនេះ លោកជាបុគ្គលនឹងឃើញច្បាស់នូវសេចក្តីរបស់ធម៌នោះ ត្រូវអាស្រ័យបញ្ញាតែម្យ៉ាង មិនមែនដោយហេតុដទៃទេ ធម្មតាសេចក្តីរបស់ធម៌ជារបស់ល្អិតសុខុមជ្រាលជ្រៅ ត្រូវអាស្រ័យបញ្ញាគិតស្រាវជ្រាវត្រួតពិនិត្យឲ្យពិតប្រាកដទើបនឹងដឹងច្បាស់បាន សេចក្តីរបស់ធម៌នោះដូចម្តេច ? សេចក្តីរបស់ធម៌នោះ គឺផលរបស់ធម៌នោះឯង ធម៌ជាហេតុ អត្ថ (សេចក្តី) ជាផល, តាមធម្មតាផលរមែងកើតឡើងអំពីហេតុ តែដូនកាលបានទទួលផលរបស់ហេតុហើយ ពិចារណារកហេតុមិនឃើញ នោះត្រូវអាស្រ័យបញ្ញាជាពិតប្រាកដ សូម្បីហេតុដែលស្មាត់កំបាំងប្រការណា ក៏មិនអាចផុតវិស័យរបស់បញ្ញាបានឡើយ, ព្រោះសម្មាសម្ពុទ្ធ

កាលគ្រាមិនទាន់បានស្ដេចចេញសាងមហាភិនិក្រមនៅឡើយ ព្រះអង្គទ្រង់ជួបឃើញមនុស្សចាស់ មនុស្សឈឺ មនុស្សស្លាប់ ជាដើម ព្រះអង្គទ្រង់ស្រាវជ្រាវរកហេតុនៃរបស់អម្បាលនោះ ផលទីបំផុតព្រះអង្គត្រូវស្ដេចចេញឲ្យផុតចាកគេហស្ថានបំពេញព្រះបញ្ញាឲ្យចាស់ក្លា ព្រះអង្គក៏ជ្រាបអត្ថរសដោយព្រះប្រាជ្ញាញាណដ៏សុខុម ទ្រង់ជ្រាបច្បាស់នូវកងទុក្ខ, ហេតុប្រជុំឲ្យកើតទុក្ខ, សេចក្ដីរលត់ទុក្ខនិងមគ្គដែលជាផ្លូវតំណើរឲ្យដល់ទីរលត់ទុក្ខ ទ្រង់ជ្រាបអត្ថដ៏ជ្រាលជ្រៅរបស់ធម៌កាត់កិលេសជាសមុច្ឆេទប្បហាន បានទទួលបរមសុខចំណែកព្រះអង្គ ហើយទ្រង់ចែកចាយផ្សាយដល់អ្នកដទៃឲ្យបានទទួលផលតាមសេចក្ដីប្រតិបត្តិ នេះជាផលបញ្ញាជាន់ខ្ពស់របស់ព្រះអង្គ សូម្បីត្រឹមតែជាន់ទាបៗក៏អាចអំណោយប្រយោជន៍ជាអនេកប្បការ អាចឃើញច្បាស់ហេតុផលដោយពិតប្រាកដ មិនបានវង្វេងវិលវល់ឡើយ ហេតុដូច្នោះ ក្នុងសុភាសិតនេះទើបលោកពោលទុកថា " បញ្ញាយត្ថំ វិបស្សតិ, បុគ្គលឃើញច្បាស់នូវសេចក្ដី (របស់ធម៌) ដោយបញ្ញា "ដូច្នេះឯង ។

## ៣. ប្រមាទ

បមាទោ មច្ចុនោ បទំ

សេចក្ដីប្រមាទ ជាផ្លូវនៃសេចក្ដីស្លាប់

សេចក្ដីប្រមាទបានដល់ការប្រាសចាកសតិ មិនមានសតិគ្រប់គ្រង

www.elibraryofcambodia.org

រក្សាចិត្ត បណ្ដោយឲ្យចិត្តស្រវឹងក្នុងលាភ យស សរសើរ សុខមិន
ប្រកបឧបាយរក្សារាងកាយជាដើម បណ្ដោយឲ្យវិលវល់នៅក្នុងផ្លូវវិនាស
លោកពោលថាជាផ្លូវនៃមរណៈដោយពិត ៗ

មែនពិត ! អ្នកដែលធ្លាក់នៅក្នុងសេចក្ដីប្រមាទ ស្រវឹងក្នុងលោកធម៌មានលាភយសជាដើម រមែងធ្លាក់ខ្លួននៅក្នុងលោក រើខ្លួនឡើងមិនរួច ធ្វើខ្លួនឲ្យវិនាសទាំងផ្លូវលោកនិងផ្លូវធម៌; ក្នុងផ្លូវលោកគប្បីឃើញបាន ដូចបុគ្គលប្រមាទធ្វេសប្រហែស មិនយកចិត្តទុកដាក់ក្នុងការរក្សារាងកាយ សូម្បីខ្លួនមានកំពូលសំណាង ដោយបុញ្ញកម្ម ជួយគាំទ្រឲ្យជាអ្នកមានអាយុវែងក៏ដោយ មិនយូរប៉ុន្មានក៏នឹងត្រូវ[illegible]ដោយមរណៈកម្មជាអកាលសម័យពុំខាន គឺថាបើប្រមាទហើយក៏ផុតផ្លូវកែខៃបាន ដូចអ្នកដែលស្លាប់ទៅហើយ សមនឹងភាសិតក្នុងធម្មបទខុទ្ទកនិកាយថា "យេ បមត្តា យថា មតា, ពួកជនណាប្រមាទ ពួកជននោះទុកដូចជាស្លាប់" ដូច្នេះ នេះជាចំណែកផ្លូវលោក, សូម្បីក្នុងផ្លូវធម៌ក៏ដូចគ្នា ការត្រាច់រង្គាត់នៅក្នុងសង្សារវដ្ដដរាបណា ក៏ឈ្មោះថានៅតែត្រូវស្លាប់ដរាបនោះ អ្នកដែលប្រមាទហើយ មិនព្យាយាមធ្វើខ្លួនឲ្យផុតចាកទុក្ខ គឺការវិលកើតវិលស្លាប់នេះ បេះតែវង្វេងវកវាយនៅក្នុងលោក រើខ្លួនឡើងមិនរួច ក៏ជាឱកាសឲ្យមរណៈតាមញាំញី ឈ្មោះថាជាផ្លូវនៃម្រឹត្យូវ; ៗ

១ ទៀត, សូម្បីអ្នកដែលសមគួរនឹងបានគុណសេចក្ដីល្អតទៅមុខទៀត

បើនៅតែប្រមាទមិនខ្វល់ខ្វាយលះបង់ចេញ ដោយអំណាចទិដ្ឋិមានះ ក៏ឈ្មោះថាលះបង់ផ្លូវប្រសើររបស់ខ្លួនចោល ត្រូវតែធ្លាក់នៅក្នុងផ្លូវនៃមរណៈជានិច្ច ដូចព្រះនាងមាគន្ទិយាជាតួយ៉ាង សូម្បីនាងបានជួបព្រះបរមសាស្ដា ហើយតែនាងបែរជាទៅយកចិត្តទុកដាក់ក្នុងផ្លូវរសតណ្ហាវិញ កាលព្រះអង្គមិនត្រេកអរជាមួយផងត្រឡប់ជាចងអាឃាត, កាលខ្លួនបានជួបរតនៈដ៏ប្រសើរហើយ គួរណាស់តែនឹងយកជាសរណៈទីពឹង មិនដូច្នោះត្រឡប់ជាយល់ឃើញវិបរិតស្ទុងទៅក្នុងផ្លូវប្រមាទ ចងអាឃាតចំពោះឧបដ្ឋាយិកា គឺព្រះនាងសាមាវតីបង្គាប់ឲ្យព្រាហ្មណ៍ជាមា យកភ្លើងដុតព្រះនាងសាមាវតីនឹងស្រីស្នំកំណាន់ស្លាប់អស់ ផលទីបំផុតខ្លួនក៏ត្រូវគេដុតទាំងរស់ដូចគ្នាវិញ នេះជាផលរបស់សេចក្ដីប្រមាទ កាត់ផ្ដាច់គុណសេចក្ដីល្អដែលខ្លួនគប្បីបានទទួល សូម្បីជីវិតក៏ត្រូវវិនាសព្រោះទោសដ៏អាក្រក់គឺប្រមាទ ហេតុនោះ សុភាសិតខាងដើមទើបបានពោលទុកថា "បមាទោ មច្ចុនោ បទំ, សេចក្ដីប្រមាទជាផ្លូវនៃសេចក្ដីស្លាប់" ដូច្នេះឯង ។

## ៨. យាចនា (ការសូម)

ទេស្សោ ច ហោតិ អតិយាចនាយ

មនុស្សដែលគេស្អប់ ព្រោះតែការសូមហួសប្រមាណ

ការស្អប់ខ្ពើមកើតមានឡើងដោយហេតុច្រើនប្រការ ដូចការឆ្មើងឆ្មៃ

www.elibraryofcambodia.org

ក្រអឺតក្រទមនឹងអ្វីៗទៀតច្រើនយ៉ាង តែការនោះប្រព្រឹត្តទៅតាមអាការរបស់អ្នកមិនចេះធ្វើខ្លួន នាំឲ្យអ្នកដទៃស្អប់ខ្ពើម ក្នុងសុភាសិតនេះសំដែងថា សូម្បីការសូម ហួសពេក គឺសូមញឹកញាយមិនរើសថាគួរ ឬមិនគួរយ៉ាងណាទេ ចេះតែសូមទៅ នេះក៏ជាហេតុឲ្យគេស្អប់ខ្ពើមដូចគ្នាដែរ ។

ការសូមត្រូវតែមានរវាងគ្នានឹងគ្នាជាធម្មតា គឺរវាងអ្នកធំនឹងអ្នកតូច រវាងមិត្រនឹងមិត្រ, រវាងមនុស្សស្និទ្ធស្នាលនឹងមនុស្សស្និទ្ធស្នាល តែអាការដែលខ្លួននឹងសូមគេនោះ ត្រូវឲ្យស្គាល់ប្រមាណខ្លួននឹងប្រមាណរបស់ដែលខ្លួនប្រុងសូម ឃើញថាគួរសូមគេឬទេ បើស្គាល់ប្រមាណហើយ ចេះធ្វើខ្លួនឲ្យសមគួរតាមកាលសម័យ [illegible] ចម្រើនប្រយោជន៍ www.elibraryofcambodia.org សមតាមន័យភាសិតរបស់សម្តេចព្រះមហាសមណៈថា “មត្តញ្ញុតា សទា សាធុ, ការស្គាល់ប្រមាណ ញុំាងប្រយោជន៍ឲ្យសម្រេចសព្វកាល ” ឯការស្គាល់ប្រមាណមិនមែនជាការនាំឲ្យវិនាសខ្លួនទេ បើសូមមិនស្គាល់ប្រមាណ គឺសូមហួសពេក សូមវត្ថុនេះបានហើយសូមវត្ថុនោះទៀត ស្រេចតែខ្លួនចូលចិត្តក៏ចេះតែសូមទៅ យូរៗទៅសូម្បីចិត្តមិនស្រឡាញ់ក៏ចេះតែសូមដែរ អាការសូមដូច្នេះ រមែងមិនជាទីគាប់ចិត្តរបស់អ្នកឲ្យទេ សូម្បីខ្លួនឯងដែលមានគេមកសូមដូច្នោះដែរ ក៏មិនពេញចិត្តនឹងសូមនោះដូចគ្នា ព្រោះអ្នកសូមមិនជាទីគាប់ចិត្តរបស់អ្នកឲ្យ បំណែកអ្នកឲ្យកាលបើមិនបានឲ្យគេទេ ក៏មិនជាទីគាប់ចិត្តរបស់អ្នកសូមដែរ ព្រោះដូច្នោះ

អ្នកសូមទើបត្រូវតែដឹងប្រមាណខ្លួន គិតមើលឲ្យល្មមសមគួរ កុំឲ្យញឹក-ញយពេកដែលជាហេតុនាំឲ្យគេធុញទ្រាន់នឿយណាយ ហើយជាហេតុបង្កឲ្យគេកើតចិត្តស្អប់ខ្ពើមដល់ខ្លួនឯងផង, អ្នកឲ្យទានអ្នកសូមត្រូវតែដឹងខ្លួនដូចគ្នា ព្រោះហេតុនោះ ព្រះសម្មាសម្ពុទ្ធទើបទ្រង់បញ្ញត្តសិក្ខាបទ ដែលជាប់ទាក់ទងដោយអាការសូមជាច្រើនសិក្ខាបទ ដូចក្នុងចីវរវគ្គនៃនិស្សគ្គិ-យកណ្ឌ តាំងអំពីសិក្ខាបទទី ៦ រហូតដល់សិក្ខាបទទី ១០, សុទ្ធតែទ្រង់ហាមមិនឲ្យសូមគេ សូម្បីទ្រង់អនុញ្ញាតឲ្យសូមគេបានខ្លះនោះ ក៏នៅតែឲ្យប្រព្រឹត្តទៅតាមល្មមប្រមាណដែរ ។

ព្រោះដូច្នោះ ការសូមញឹកញាប់ជាហេតុក័យដឹពន្ទឹកអាចធ្វើឲ្យគេស្អប់ខ្ពើមចំពោះអ្នកសូម, ទោះបីភិក្ខុសាមណេរក៏ព្រះសម្មាសម្ពុទ្ធទ្រង់ហាមប្រាមថាឲ្យសូមគេតែល្មមសមគួរ មិនឲ្យសូមហួសពេកទេ ព្រោះជាហេតុធ្វើសទ្ធាទេយ្យរបស់ទាយកឲ្យថយចុះទៅ ជាទីមើលងាយស្អប់ខ្ពើមរបស់មនុស្សទាំងឡាយផង ទើបសមតាមសុភាសិតដែលតាំងទុកខាងដើមថា "ទេស្សោ ច ហោតិ អតិយាចនាយ, មនុស្សដែលគេស្អប់ ព្រោះតែការសូមហួសប្រមាណ" ដូច្នេះឯង ។

www.elibraryofcambodia.org

## ៩. វាចា

មោក្ខោ កល្យាណិយា សាធុ

ការបញ្ចេញវាចាល្អ ញុំាងប្រយោជន៍ឲ្យសម្រេច.

ចាលីសុភាសិតនេះ ត្រូវនឹងបុរាណសុភាសិតខ្មែរថា "សំដីជាឯក" គឺនិយាយសំដីល្អពីរោះផ្អែមល្ហែម ជាហេតុឲ្យកើតមេត្រីចិត្តស្និទ្ធស្នាល ជាគ្រឿងទាញចិត្តអ្នកដទៃឲ្យចូលសមាគមគប់រក អាចញុំាងប្រយោជន៍ឲ្យសម្រេចបាន ។

មែនពិត! វាចាពីរោះផ្អែមល្ហែម រមែងជាទីគាប់ចិត្តរបស់មនុស្សគ្រប់ជាន់រហូតដល់សត្វតិរច្ឆាន ឪពុកម្ដាយនិយាយទីកូនដោយសំដីទន់ផ្អែម ហៅតាមនាម មេនាមជាដើម ពាក្យដូច្នេះរមែងជ្រួតជ្រាបចាប់ចិត្តរបស់កូនយ៉ាងក្រៃលែង ជាហេតុធ្វើឲ្យកូនកើតសេចក្ដីស្រឡាញ់គោរពកោតខ្លាច សូម្បីកូនចេះនិយាយសំដីទន់ផ្អែមមានបាទបាសជាដើម មាតាបិតារមែងមានសេចក្ដីស្រឡាញ់អាណិតអាសូរកូនវិញដូចគ្នាដែរ , បុគ្គលនឹងប្រើប្រាស់គេឬនឹងពឹងពាក់រកអ្នកគេ បើចេះនិយាយសំដីទន់ផ្អែមមានបាទបាសជាដើម គេក៏ត្រេកអរជួយធ្វើដោយសេចក្ដីពេញចិត្ត ពុំនោះសោត បេះនិយាយសំដីទន់ផ្អែមទៅមករកគ្នាទាំងសងខាង គង់ពេលដែលត្រូវពឹងពាក់រកគ្នានោះ ក៏រឹតតែជាការប្រពៃណាស់ទៅទៀត ។ លោកអ្នកធំចូលចិត្តការនិយាយបដិសណ្ឋារៈ ពោលពាក្យទាក់ប្រស្រ័យប្រោសប្រាណដល់អ្នកតូចមិនរើសមុខ អាចធ្វើខ្លួនលោកឲ្យជាទីស្រឡាញ់រាប់អានរបស់អ្នកតូចទាំងឡាយ , អ្នកធំត្រូវតែឈ្លាសវៃក្នុងការប្រើអ្នកតូចដោយពាក្យដឹកនាំឲ្យអ្នកតូចមានគំនិតចូលចិត្តចង់ធ្វើកិច្ចការ ដោយសេចក្ដី

www.elibraryofcambodia.org

ក៏ក្តី សូម្បីបាលីក្នុងសគាថវគ្គសំយុត្តនិកាយក៏ទទួលអះអាងថា "វាចំ មុញ្ចេយ្យ កល្យាណឹ, បុគ្គលគួរថ្លែងវាចាល្អ" ; វាចាល្អនោះ ប្រៀបដូចទឹកទំពាំងដែលប្រស់ព្រំចិត្តមនុស្សឲ្យស្រស់បស់ ឲ្យគេខ្មីឃ្មាតខំធ្វើកិច្ចការមិនរួញរា បើនិយាយមិនទន់ផ្អែមត្រែគោះបោះបោកវាយស្លូនដល់ត្រចៀកគេហើយតែងធ្វើឲ្យខូចផលប្រយោជន៍ជាច្រើន ពាក្យដូច្នោះសូម្បីតែសត្វតិរច្ឆានក៏អន់ចិត្តដែរ មិនបាច់តែចិត្តមនុស្សទេ ដូចមានរឿងមួយថា ព្រាហ្មណ៍ម្នាក់តាំងភ្នាល់នឹងសេដ្ឋី អួតថាគោខ្លួនមានកម្លាំងខ្លាំងណាស់ អាចអូសរទេះដែលផ្ទុករបស់ធ្ងន់សណ្តាំគ្នា ១០០ ឲ្យលឿនទៅបាន ។ ព្រាហ្មណ៍បានពោលពាក្យអាក្រក់គំរោះគំរើយថា អើយ! អាគោកៀចឯងចូរអូសរទេះនេះទៅ គោបានទទួលផរុសវាចាដូច្នោះ ក៏អស់កម្លាំងលែងអូសរទេះនេះទៅរួច ។ ព្រាហ្មណ៍ចាញ់គេបង់ខាតប្រាក់ ១០០០ កហាបណៈឲ្យសេដ្ឋី នេះជាទោសរបស់វាចាដែលអាក្រក់ អាស្រូវគាសមិនទន់ផ្អែម ។ តមកខាងក្រោយព្រាហ្មណ៍នឹងសេដ្ឋីតាំងភ្នាល់គ្នាជាថ្មីម្តងទៀត ព្រាហ្មណ៍ពោលពាក្យលួងលោមយកចិត្តគោនន្ទិវិសាលនោះថា ម្នាលបុ.មហាចំរើន បាចូរអូសទៅ, បាមហាចំរើន បាចូរអូសទៅ ។ គោនន្ទិវិសាលក៏រីករាយដោយសំដីដ៏ពីរោះទន់ផ្អែមនោះ ខំប្រឹងប្រែងអូសរទេះទាល់តែរួច ។ ព្រាហ្មណ៍ត្រឡប់ឈ្នះការភ្នាល់បានប្រាក់ ២.០០០ កហាបណៈវិញ ។ សូម្បីសត្វតិរច្ឆានគង់តែត្រូវការសំដីទន់

www.elibraryofcambodia.org

ផ្អែមមានសភាពដូច្នេះដែរ ចំណាង់បើមនុស្សយើងម្ដេចក៏មិនចូលចិត្ត? មនុស្សដែលវិសេសជាងនេះទៅទៀត បើនឹងប្រើឲ្យគេធ្វើការងារធ្ងន់លំបាកនិយាយចរចាសំដីអាក្រក់គំរោះគំរើយមិនគួរស្ដាប់ គេមុខជាលែងធ្វើឲ្យដោយដាច់ខាត បើនឹងធ្វើឲ្យក៏ធ្វើសោះតែខាន ធ្វើឲ្យខូចខាតផលប្រយោជន៍, ឥស្សរជនអ្នកឈ្លាសវៃចេះល្បួងលោមមនុស្សដោយសំដីល្អ សូម្បីនឹងប្រើគេឲ្យធ្វើការងារធ្ងន់លំបាកដូចម្ដេចក្ដី បើចេះនិយាយឲ្យគេកើតចិត្តរីករាយតាមសំដីរបស់ខ្លួនបានហើយ អាចនឹងញុំាងអំពើនោះឲ្យសម្រេចបានដោយស្រួល ទើបសមនឹងភាសិតខាងដើមថា "មោក្ខកល្យាណិយា សាធុ, ការបញ្ចេញវាចាល្អ ញុំាងប្រយោជន៍ឲ្យសម្រេច" ដូច្នេះឯង ។

www.elibraryofcambodia.org

## ១០- វិរិយៈ (សេចក្ដីព្យាយាម)

វាយាមេថេវ បុរិសោ យាវ អត្ថស្ស និប្បទា

កូនប្រុសគប្បីព្យាយាម ទាល់តែបានសម្រេចប្រយោជន៍ ។

សុភាសិតនេះសំដៅចំពោះតែប្រុស គឺបណ្ដុះបណ្ដាលឲ្យតែប្រុសខំព្យាយាមទៅ ចុះចំណែកស្រីមិនគួរព្យាយាមទេឬ? គួរព្យាយាមដូចគ្នា ស្រីឬប្រុសសុទ្ធតែមានវត្ថុបំណងក្នុងជីវភាពដូចគ្នា ត្រូវតែមានសេចក្ដីព្យាយាមដូចគ្នា តែដែលពោលចំពោះប្រុសនោះ ព្រោះសម័យមុនគេនិយមកប់អានថា ប្រុសត្រូវជាអ្នកប្រកបការងារធ្ងន់ៗ នឹងត្រូវជាមេ

ថារបស់ត្រកូល រាប់អានស្រីថាជាអ្នកទន់ភ្លន់មិនសូវមានសមត្ថភាពនឹងធ្វើការអ្វីបានឡើយ តែសម័យនេះស្រីមានសេរីភាពដែលនឹងធ្វើការអ្វីៗបានដូចប្រុសដែរ សុភាសិតនេះប្រដៅចំពោះតែប្រុសដូចម្តេច ស្រីក៏គប្បីសិក្សាប្រដៅខ្លួនតាមប្រុសដូច្នោះដែរ ដើម្បីបំពេញករណីយកិច្ចរបស់ខ្លួនឲ្យបានសម្រេចដូចវត្ថុបំណង ។

សេចក្តីព្យាយាមនោះ គឺអាការដែលមិនរួញរាញញាប់ញ័រចំពោះសេចក្តីលំបាក ត្រូវព្យាយាមទៅតាមវត្ថុបំណងដែលតាំងចិត្តសំដៅទៅកន្លែងខាងមុខ. បើមិនបានសម្រេចតាមវត្ថុបំណងទេ សូម្បីមានឧបសគ្គមកជំទាស់រាំងរាដូចម្តេចក៏ ក៏ខំព្យាយាមតែពុះពារឲ្យទាល់តែបានសម្រេចផល ទុកជាជីវិតរាងកាយនឹងរលត់ក៏មិនគិត ត្រូវប្រកាន់សេចក្តីសម្រេចផលជាសំខាន់ យ៉ាងនេះចាត់ជាសេចក្តីព្យាយាម តែវិរិយៈគឺសេចក្តីព្យាយាមនេះអាចយកទៅប្រើក្នុងផ្លូវដែលនាំឲ្យកើតទោសក៏បាន ដូចព្យាយាមតែខាងលួចគេ ព្យាយាមតែខាងបំផ្លិចបំផ្លាញគេជាដើម សូម្បីមានអន្តរាយចាំស្ទាក់នៅខាងមុខជុំវិញក៏មិនទម្លាក់ព្យាយាមចោលចេះតែខំធ្វើទៅដរាបដល់ផលរបស់ខ្លួនសម្រេច តែផលសម្រេចយ៉ាងនេះមិនល្អឡើយ ដ្បិតថានាំឲ្យកើតទុក្ខនឹងទោសតែម្យ៉ាង បណ្ឌិតមិនសរសើរទេ ព្រោះដូច្នោះប្រុសស្រីទើបគួរព្យាយាមទៅក្នុងផ្លូវដែលត្រូវល្អ ក្នុងផ្លូវដែលជាធម៌ ។ មនុស្សយើងកើតមកត្រូវតែមានការងារធ្វើគ្រប់គ្នារៀងខ្លួន ផ្សេងតែអ្នកខ្លះ

www.elibraryofcambodia.org

ជាអ្នកស្រែ អ្នកចម្ការ កម្មករ អ្នករាជការ ទើបត្រូវមានសេចក្តីព្យាយាម ធ្វើកិច្ចរបស់ខ្លួនឲ្យបានសម្រេចតាមវត្ថុបំណងរាល់រូប តែបណ្តាកិច្ចការទាំងឡាយដែលត្រូវធ្វើនោះរមែងប្រកបដោយឧបសគ្គ និងសេចក្តីលំបាកគ្រប់យ៉ាង ប្លែកគ្នាតែច្រើនឬតិចប៉ុណ្ណោះ ការងារដែលថ្លៃថ្លាក៏ត្រូវមានឧបសគ្គច្រើនធ្វើបានដោយកម្រ ការងារថោកទាបឧបសគ្គនិងសេចក្តីលំបាកក៏ថយចុះបន្តិចទៅ ៗ បើបុគ្គលណារួញរាដោយខ្លាចឧបសគ្គនិងសេចក្តីលំបាកតែម្យ៉ាង បុគ្គលនោះរមែងលិចនៅក្នុងអន្លង់នៃឧបសគ្គនោះឯង លើកខ្លួនឲ្យមានឋានៈខ្ពស់ឡើងមិនបានទេ ត្រូវតែមានទុក្ខជានិច្ច ៗ ចំណែកអ្នកណាមានសេចក្តីព្យាយាមប្រកបដោយចិត្តក្លាហាន ខំអត់ធ្មត់អង់អាចកំចាត់ឧបសគ្គនោះចេញ ដោយសេចក្តីព្យាយាម ទំលាយទុក្ខលំបាកដែលកើតអំពីឧបសគ្គការទទាក់ទទាមនោះ ឲ្យរលាយបាត់សូន្យទៅ អ្នកនោះបានសម្រេចផលដូចវត្ថុបំណងនៃខ្លួនជាប្រាកដ សមតាមទេសនាន័យក្នុងសគាថវគ្គសំយុត្តនិកាយថា "វិរិយេន ទុក្ខមច្ចេតិ, បុគ្គលកន្លងទុក្ខបាន ព្រោះសេចក្តីព្យាយាម" ដូច្នេះ ៗ ,

www.elibraryofcambodia.org

ហេតុនោះ បុគ្គលកាលបានដឹងផលរបស់សេចក្តីខ្ជិលច្រអូសនិងផលរបស់សេចក្តីឧស្សាហ៍ដំណើមគ្នាមួយផ្លូវម្តងយ៉ាងនេះហើយ យើងត្រូវតែយកខាងផលល្អ, ផលដែលល្អយើងនឹងធ្វើដូចម្តេចទើបបាន? យើងត្រូវព្យាយាមធ្វើចិត្តឲ្យក្លាហានមិនរួញរាកាលបើមានសេចក្តីព្យាយាមយ៉ាងមុត

មាំហើយ គ្មានអំពើណាដែលយើងធ្វើមិនកើតឡើយ ហេតុនោះទើបសុភាសិតខាងដើមលោកដស់តឿនឲ្យក្លាហានថា: "វាយាមេថេវ បុរិសោ យាវ អត្ថស្ស និប្ផទា, កូនប្រុសគប្បីព្យាយាមទាល់តែបានសម្រេចប្រយោជន៍" ដូច្នេះឯង ។

## ១១. សទ្ធា (សេចក្ដីជឿ)

សទ្ធា សាធុ បតិដ្ឋិតា

សទ្ធាតាំងមាំហើយ ញុំាងប្រយោជន៍ឲ្យសម្រេចបាន

សទ្ធា ប្រែថា សេចក្ដីជឿក្នុងរបស់ដែលគួរជឿ, ជឿដោយមានហេតុមានផល មិនមែនជឿ [illegible] ជាអធិមោក្ខទេ ចាត់តាមប្រភេទជា ៤ គឺ: កម្មសទ្ធា ជឿកម្ម១ វិបាកសទ្ធា ជឿផលរបស់កម្ម១ កម្មស្សកតាសទ្ធា ជឿថាសត្វមានកម្មជារបស់ខ្លួន១ តថាគតពោធិសទ្ធា ជឿបញ្ញាត្រាស់ដឹងរបស់ព្រះតថាគត១ ។ សទ្ធានេះតាំងមាំនៅក្នុងចិត្តរបស់បុគ្គលណាហើយ អាចញុំាងប្រយោជន៍គ្រប់យ៉ាងឲ្យសម្រេចដល់បុគ្គលនោះបានតាមប្រាថ្នា ។

www.elibraryofcambodia.org

ការជឿចំពោះកុសលកម្ម គឺកម្មល្អ បានយល់ឃើញថាជាហេតុឲ្យបានផលជាសុខទៅខាងមុខ ជាទីប្រាថ្នាពេញចិត្តដល់អ្នកធ្វើ និងការជឿចំពោះអកុសលកម្ម គឺកម្មអាក្រក់ថាជាហេតុឲ្យផលជាទុក្ខទៅខាងមុខ នាំឲ្យអ្នកធ្វើកើតក្ដៅក្រហាយ កើតទុក្ខទោសដល់អ្នកធ្វើហើយ អនុ-

វត្តន៍ទៅតាមមូលហេតុនោះ ៗ ដោយតាំងចិត្តជឿមូលហេតុនោះ ៗ ស៊ប់ ដូចគ្រូពេទ្យស្គាល់សមុដ្ឋានរោគជាមុនថានឹងឲ្យកើតសេចក្ដីសុខសប្បាយ ឬនឹងឲ្យកើតទោសដល់រាងកាយ ហើយប្រកបឧបាយណែនាំឬបំបាត់ចេញមុនរោគដែលនឹងកើតឡើង នេះហៅថាកម្មសទ្ធា ជឿកម្ម ៗ ការដឹងវិបាកគឺដឹងផលជាសុខជាទុក្ខថាកើតមកតែអំពីកម្មល្អអាក្រក់ ស្រាវជ្រាវដេញដោលរកដើមហេតុទៅឃើញថាមានដើមចមមកអំពីកម្មយ៉ាងនោះៗ ដូចគ្រូពេទ្យឃើញរោគ ហើយស្រាវជ្រាវពិនិត្យរកសមុដ្ឋានរបស់រោគនោះៗ នេះហៅថាវិបាកសទ្ធា ជឿផលរបស់កម្ម ៗ ការដឹងថាពួកសត្វអ្នកមានកិលេស ធ្វើកម្មឯណាហើយ ដោយកាយវាចាចិត្ត ក៏រមែង

www.elibraryofcambodia.org

បានសោយផលរបស់កម្មនោះ ធ្វើល្អក៏បានសោយផលល្អ ធ្វើអាក្រក់ក៏បានសោយផលអាក្រក់ កម្មរមែងបែងចែកសត្វអ្នកធ្វើឲ្យជាមនុស្សថ្លៃថ្លានឹងថោកទាបផ្សេងៗគ្នា ដូចការសិតដែលមានមកក្នុងឧបរិបណ្ណាសកមជ្ឈិមនិកាយថា "កម្មំ សត្តេ វិភជតិ យទិទំ ហីនប្បណីតតាយ, កម្មតែងបែកសត្វទាំងឡាយ ឲ្យថោកទាបនឹងថ្លៃថ្លា" នេះហៅថាកម្មស្សកតាសទ្ធា ជឿថាសត្វមានកម្មជារបស់ខ្លួន ៗ ការយល់ឃើញគុណនៃព្រះធម៌នឹងព្រះសង្ឃ ហើយជឿស៊ប់ដោយន័យថា "អរហំ សម្មាសម្ពុទ្ធោ ព្រះដ៏មានព្រះភាគជាព្រះអរហន្ត ត្រាស់ដឹងនូវធម៌ដែលពិតដោយព្រះអង្គឯង, ស្វាក្ខាតោ ភគវតា ធម្មោ, ធម៌ដែលព្រះអង្គទ្រង់សំដែងប្រដៅ

វេនេយ្យសត្វ ឈ្មោះថាត្រាស់ប្រែពៃហើយ, សុបដិបន្នោ ភគវតោ សាវកសង្ឃោ, ព្រះសង្ឃសាវ័ករបស់ព្រះដ៏មានព្រះភាគ លោកប្រតិបត្តិប្រពៃហើយ ប៉ុណ្ណោះជាដើម នេះហៅថា តថាគតពោធិសទ្ធា ជឿបញ្ញាត្រាស់ដឹងរបស់ព្រះតថាគត ។

សទ្ធានេះ ជាកុសលធម៌ចំណែកចេតសិក កាលកើតមានឡើងក្នុងចិត្តរបស់អ្នកណាហើយ ក៏ធ្វើឲ្យអ្នកនោះតាំងចិត្តមាំក្នុងកិច្ចដែលគប្បីធ្វើ កំចាត់សេចក្តីមិនជឿដែលជាសត្រូវដល់ខ្លួនចេញបាន ប្រាថ្នាផលប្រ-យោជន៍ជាទីតាំង កំចាត់សេចក្តីសង្ស័យ ដែលជាហេតុមិនឲ្យក្លាហានចេញបាន ធ្វើចិត្តឲ្យ[illegible]ប្រយោជន៍ឲ្យសម្រេចតាមប្រាថ្នាបាន អំពើណាបើខ្វះខាតសទ្ធាហើយ រមែងមិនឲ្យផលល្អដល់អ្នកធ្វើឡើយ ព្រោះសទ្ធាជាមិត្រសំឡាញ់ចាំដាស់តឿនចិត្តរបស់បុគ្គលឲ្យក្លាហាន ឲ្យតាំងមាំនៅជានិច្ច ឲ្យព្យាយាមឈានកន្លងទៅមុខរកសេចក្តីល្អ ដូចកាលព្រះបញ្ចវគ្គិយមិនជឿព្រះដ៏មានព្រះភាគ ហើយចេញចោលព្រះអង្គទៅនៅព្រៃឥសិបតនមិគទាយវ័នជិតដែនរាជគ្រឹះ ក្នុងវេលាដែលព្រះអង្គកំពុងបំពេញព្យាយាម កាលព្រះអង្គបានត្រាស់ដឹងហើយ មានព្រះមហាករុណាទិគុណយ៉ាងលើសលុប ទ្រង់នឹងផ្សាយផលធម៌ឲ្យព្រះបញ្ចវគ្គិយបានដឹងផង ក៏ស្ដេចយាងមករកព្រះបញ្ចវគ្គិយ តែព្រោះព្រះបញ្ចវ-គ្គិយមិនជឿព្រះអង្គទើបនិយាយប្រើស័ព្ទដោយពាក្យសាមញ្ញ រហូតដល់

www.elibraryofcambodia.org

ទៅមើលងាយព្រះអង្គ លុះដល់ព្រះអង្គទ្រង់បន្ទុលបង្ហាញឲ្យរឭកដល់ពាក្យខាងដើមថា ពាក្យយ៉ាងនេះតថាគតធ្លាប់បានត្រាស់ដែរឬ? ព្រះបញ្ចវគ្គិយទើបបានរឭកនឹកឃើញហើយបង្អោនចិត្តជឿយ៉ាងមាំមួន តាំងសោតប្បសាទស្តាប់ព្រះធម្មចក្កប្បវត្តនសុត្តទេសនា ក៏បានសម្រេចប្រយោជន៍ដល់ខ្លួនយ៉ាងខ្ពង់ខ្ពស់ នេះក៏ព្រោះអាស្រ័យគុណគឺសទ្ធាដែលតាំងមាំតែម្យ៉ាង រមែងឲ្យផលដូច្នេះ ៗ ហេតុនោះ ទើបសមនឹងភាសិតខាងដើមថា "សទ្ធា សាធុ បតិដ្ឋិតា, សទ្ធាតាំងមាំហើយ ញុំាងប្រយោជន៍ឲ្យសម្រេចបាន" ដូច្នេះឯង ៗ

## ១៣ សីល

www.elibraryofcambodia.org

### សីលំ លោកេ អនុត្តរំ

### សីលជាគុណជាតដ៏ក្រៃលែងក្នុងលោក.

សុភាសិតនេះ សរសើរសីលថាជាគុណជាតដ៏ក្រៃលែង មិនមានអ្វីធៀបក្នុងលោក ចុះរបស់អ្វីហៅថាសីល? សីលនោះបានដល់ការរក្សាកាយវាចាឲ្យរៀបរយ ឲ្យស្អាតហ្មត់ចត់បរិសុទ្ធ ផុតចាកការវិនាសដែលគប្បីកើតឡើងដោយផ្លូវកាយនឹងវាចា ឬប្រព្រឹត្តខុសហាមក្នុងសិក្ខាបទមួយ ៗ ដែលលោកបញ្ញត្តិហាមយ៉ាងណាហើយមិនហ៊ានប្រព្រឹត្តល្មើស ដូចក្នុងបញ្ចវេរគឺ បញ្ញត្តិហាមមិនឲ្យធ្វើបាណាតិបាតជាដើម ក៏ប្រតិបត្តិតាមបាន ហើយនេះហៅថាសីល ៗ ឯសីលនេះជាគ្រឿងបោសសំអាតប្តុំ-

ចាត់ចេញនូវសេចក្ដីអាក្រក់ ដែលកើតឡើងដោយផ្លូវកាយនិងវាចា ជាធម្មជាតទទួលទ្រទ្រង់នូវកុសលធម៌ គឺគុណសេចក្ដីល្អផ្សេង ៗ ធ្វើឲ្យកុសលធម៌ដទៃទៀតកើតចំរើនឡើងតាមបាន ដូចជណ្ដើរកាំជំបូងដែលនឹងឲ្យជាន់ឡើងទៅកាំជាន់ខ្ពស់ដូច្នោះ បើខ្វះខាតសីលហើយគុណធម៌ដទៃទៀតក៏កើតឡើងមិនបាន ព្រោះដូច្នោះ សីលទើបចាត់ថាជាគុណ-ជាតក្រៃលែង ។

សីលនេះតាមប្រភេទចែកចេញជា ២ គឺសីលរបស់គ្រហស្ថ ១ សីលរបស់បព្វជិត ១ ។ សីល ៥ សីល ៨ ចាត់ជាសីលរបស់គ្រហស្ថ, សីល ១០ សីល ២២៧ ឬបាតិមោក្ខសំវរសីល គឺការសង្រួមក្នុងបាតិមោក្ខ ចាត់ជាសីលរបស់បព្វជិត ។ សីលជាគុណជាតយ៉ាងក្រៃលែង ដែលត្រូវតែមានខ្វះមិនបាននោះ ដើម្បីនឹងបានជាគ្រឿងកាត់ចិត្ត មិនឲ្យប្រកបទៅដោយចេតនាដ៏លាមក មានលោភៈ ទោសៈ និងមោហៈ ជាបុសគល់ ។ បុគ្គលដែលមានលោភៈ ទោសៈ មោហៈ គ្របសង្កត់ហើយ រមែងធ្វើអ្វីៗសុទ្ធតែលុះទៅដោយអំណាចកិលេសទាំងអស់ ដូចដណ្ដើមកម្មសិទ្ធិទ្រព្យសម្បត្តិរបស់អ្នកដទៃប្រទូសរ៉ាយគេ ឬវង្វេងវិលវល់ បំផ្លាញជីវិតនិងទ្រព្យសម្បត្តិរបស់អ្នកដទៃឲ្យវិនាស នេះជាផលរបស់ការប្រាសចាកសីល បើមានសីលហើយ របស់អម្បាលនេះក៏អន្តរធានបាត់សូន្យទៅ ធ្វើការរកស៊ីចិញ្ចឹមជីវិតក៏មានរបៀបរៀបរយល្អ ប្រាសចាកការប្រណែនឈ្នានីស

www.elibraryofcambodia.org

តាំងចិត្តធ្វើតាមកម្លាំងគំនិត និយាយចរចាក៏រៀបរយ ជាហេតុដឹកនាំឲ្យអ្នកដទៃចូលមកសមាគមគប់រកផង ជាទីចំរើននៃភោគសម្បត្តិ សមតាមភាសិតថា " សីលេន ភោគសម្បទា , ជនទាំងឡាយទឹងដល់ព្រមដោយទ្រព្យសម្បត្តិ ក៏ព្រោះសីល " ទឹងជាបច្ច័យនាំឲ្យទៅកាន់សុគតិសួគ៌ ដរាបដល់ព្រះនិព្វានជាទីបំផុតក្នុងរវាងដែលត្រាច់រង្គាត់នៅក្នុងសង្សារវដ្ត រមែងមានកិត្តិស័ព្ទក្រអូបខ្ចរខ្ចាយទៅក្នុងទិសានុទិស ជាក្លិនក្រអូបនាំឲ្យគេចង់គប់រក បក់ត្រឡប់ទៅទាំងបណ្ដាយខ្យល់ទឹងច្រាស់ខ្យល់ ។ ចំណែករបស់ក្រអូបដទៃមានក្រស្នាទឹងក្លាំពាក់ជាដើម សូម្បីមនុស្សនិយមថាជារបស់ក្រអូបប្រសើរបំផុតក្នុងលោកកពិតហើយ តែអាចបក់ក្លិនទៅបានតែបណ្ដាយខ្យល់ប៉ុណ្ណោះ, ចំណែកក្លិនគឺសីលនោះក្រអូបខ្ចរខ្ចាយទៅបានទាំងបណ្ដាយខ្យល់ទឹងច្រាសខ្យល់ ជាជណ្ដើរថ្នាក់ខាងដើមឲ្យឈានឡើងទៅកាន់គុណសេចក្ដីសុខថ្នាក់ខ្ពស់ដោយលំដាប់ មិនមានជណ្ដើរឯណាអាចទឹងជាទីរងទទួលឲ្យឈានឡើងទៅកាន់ថ្នាក់ខ្ពស់បានទេ ហេតុនេះ ក្នុង លោកនេះ មិនមានគុណជាតអ្វីក្រៃលែងជាងសីលឡើយ , សីលមានគុណវិសេសដូចពណ៌នាមកហើយនេះ ហេតុនោះទើបសមទឹងសុភាសិតខាងវើយថា " សីលំ លោកេ អនុត្តរំ, សីលជាគុណជាតក្រៃលែងក្នុងលោក " ដូច្នេះឯង ។

www.elibraryofcambodia.org

តាំងចិត្តធ្វើតាមកម្លាំងគំនិត និយាយចរចាក៏រៀបរយ ជាហេតុដឹកនាំឲ្យអ្នកដទៃចូលមកសមាគមគប់រកផង ជាទីចំរើននៃភោគសម្បត្តិ សមតាមភាសិតថា " សីលេន ភោគសម្បទា , ជនទាំងឡាយទឹងដល់ព្រមដោយទ្រព្យសម្បត្តិ ក៏ព្រោះសីល " ទឹងជាបច្ច័យនាំឲ្យទៅកាន់សុគតិសួគ៌ ដរាបដល់ព្រះនិព្វានជាទីបំផុតក្នុងវេលាដែលត្រាច់រង្គាត់នៅក្នុងសង្សារវដ្ត រមែងមានកិត្តិស័ព្ទក្រអូបខ្ចរខ្ចាយទៅក្នុងទិសានុទិស ជាក្លិនក្រអូបនាំឲ្យគេចង់គប់រក បក់ត្រឡប់ទៅតាំងបណ្តាយខ្យល់ទឹងច្រាស់ខ្យល់ ។ ចំណែករបស់ក្រអូបដទៃមានក្រស្នាទឹងក្លាំពាក់ជាដើម សូម្បីមនុស្សនិយមថាជារបស់ក្រអូបប្រសើរបំផុតក្នុងលោកក៏ពិតហើយ តែអាចបក់ក្លិនទៅបានតែបណ្តាយខ្យល់ប៉ុណ្ណោះ , ចំណែកក្លិនគឺសីលនោះក្រអូបខ្ចរខ្ចាយទៅបានតាំងបណ្តាយខ្យល់ទឹងច្រាសខ្យល់ ជាដំណើរថ្នាក់ខាងដើមឲ្យឈានឡើងទៅកាន់គុណសេចក្តីល្អថ្នាក់ខ្ពស់ដោយលំដាប់ មិនមានដំណើរឯណាអាចនឹងជាទីរងទទួលឲ្យឈានឡើងទៅកាន់ថ្នាក់ខ្ពស់បានទេ ហេតុនេះ ក្នុងលោកនេះ មិនមានគុណជាតិអ្វីក្រៃលែងជាងសីលឡើយ , សីលមានគុណវិសេសដូចពណ៌នាមកហើយនេះ ហេតុនោះទើបសមនឹងសុភាសិតខាងដើមថា " សីលំ លោកេ អនុត្តរំ , សីលជាគុណជាតក្រៃលែងក្នុងលោក " ដូច្នេះឯង ។

www.elibraryofcambodia.org

# ១៣. ពាក្យសត្យ

## សច្ចមនុរក្ខេយ្យ

### គប្បីរក្សារឿយ ៗ នូវពាក្យសត្យ

ក្នុងសុភាសិតនេះ លោកណែនាំបបួលឲ្យរក្សាពាក្យសត្យ គឺសេចក្ដីស្មោះត្រង់ ពាក្យសត្យនោះល្អយ៉ាងណា បានជាលោកណែនាំបបួលឲ្យមនុស្សរក្សា បើរក្សាហើយនឹងបានទទួលផលដូចម្ដេច? ។

ពាក្យសត្យ ប្រែតាមព្យញ្ជនៈថាសេចក្ដីពិត ដោយអត្ថបានដល់សេចក្ដីស្មោះត្រង់ គឺអាការកាយនិងចិត្តត្រង់រកគ្នា វាចានិងចិត្តត្រង់រកគ្នា គិតយ៉ាងណាធ្វើយ៉ាងនោះ គិតយ៉ាងណានិយាយយ៉ាងនោះ បានប្ដេជ្ញាឬទទួលពាក្យនឹងធ្វើយ៉ាងណាក៏ធ្វើយ៉ាងនោះ ស្មោះត្រង់ទៅស្មោះត្រង់មក មិនកុហកខ្លួនឯង និងមិនបោកបញ្ឆោតអ្នកដទៃ មិនមានមាយាសាឋេយ្យៈ នេះជាលក្ខណៈយ៉ាងខ្លី ៗ របស់ពាក្យសត្យ, តែពាក្យសត្យនេះ ត្រូវប្រព្រឹត្តទៅតាមទំនងគន្លងធម៌ដែលមានប្រយោជន៍ដល់ខ្លួននិងអ្នកដទៃ ទើបជាផ្លូវប្រតិបត្តិរបស់បណ្ឌិត សមនឹងភាសិតក្នុងសគាថវគ្គសំយុត្តនិកាយថា "សច្ចេ អត្ថេ ច ធម្មេ ច អហុ សន្តោ បតិដ្ឋិតា, សប្បុរសទាំងឡាយ (បណ្ឌិត) បានតាំងមាំក្នុងពាក្យសត្យដែលជាអត្ថនិងធម៌" នេះបន្អុលបង្ហាញឲ្យឃើញថាពាក្យសត្យជាវិធីមួយដែលសប្បុរសតែងរក្សាគ្រប់គ្នា ។ បើពាក្យសត្យប្រព្រឹត្តៈទៅក្នុងផ្លូវប្រាសចាកធម៌

www.elibraryofcambodia.org

នឹងមិនមានប្រយោជន៍ហើយ  សូម្បីជាពាក្យសត្យមែនៗ ក៏ប្រើការមិនបាន  មិនត្រូវរក្សាក៏ឃើញថាមិនជាការអ្វី  ដូចមានបុរសម្នាក់បានណាត់សន្យានឹងយើងឲ្យទៅជួបនាកន្លែងមួយ  ដើម្បីនាំគ្នាទៅប្លន់ទ្រព្យសម្បត្តិឬលួចរបស់គេ ហើយយើងបានទទួលពាក្យគេ ព្រោះខ្លាចគេប្រទូសរ៉ាយខ្លួនឬមិនបានពិចារណាឲ្យឃើញទោសក្នុងការលួច  លុះសន្យារួចហើយត្រឡប់នឹកឃើញចំពោះអាការដែលធ្វើដូច្នោះថាមិនល្អ  ជាផ្លូវទុច្ចរិតនាំទុក្ខទោសមកឲ្យ  ឬដោយបានទទួលពាក្យសន្យាអំពីអ្នកណាម្នាក់ឲ្យប្រព្រឹត្តទុច្ចរិតហើយលះវៀរបានទាំងអស់ តាំងចិត្តថាមិនទៅហើយក៏មិនទៅពិតៗដូច្នេះឈ្មោះថា  មិនរក្សាពាក្យសត្យមែនតែមិនឲ្យមានទោសទេ  ព្រោះពាក្យសត្យដូច្នេះមិនជាអត្ថជាធម៌ ។ ចំណែកពាក្យសត្យដែលជាអត្ថជាធម៌ជារបស់ខានរក្សាមិនបានត្រូវតែរក្សាទុក  ដូចយើងបានតាំងចិត្តបំពេញវត្តមួយ គឺមិនក្រោធខឹងអស់វេលា ៣ខែ  ហើយក្នុងចន្លោះនោះក៏តាំងព្យាយាមសង្កត់ចិត្តមិនឲ្យក្រោធកើតឡើងបាន  រក្សាបានពិតៗដូច្នេះចាត់ថាជាអត្ថជាធម៌ ឈ្មោះថាយើងបានឈ្នះខ្លួនឯង  ហើយគ្មានហេតុដែលទើសទាស់អំពីអ្នកដទៃ,  អ្នកសម្លាប់សេចក្ដីក្រោធបានរាប់ថាជាសុខ,  សូម្បីវេលានេះតិចត្រឹមតែ ៣ខែប៉ុណ្ណោះ ក៏រាប់ថាជាបច្ច័យឲ្យបំពេញបានច្រើនឡើងទៅក្នុងកាលជាអនាគត ។ យើងក៏តាំងចិត្តថាតទៅយើងគង់ធ្វើបានល្អវិសេសជាងនេះដោយពិតប្រាកដ  ព្រោះសេចក្ដីជឿមាំក្នុងចិត្តយើងភ្ជាប់

www.elibraryofcambodia.org

មានមកហើយ រមែងជាគុណដ៏ខ្ពង់ខ្ពស់ យើងនឹងទំលាយពាក្យសត្យ យ៉ាងនេះមិនបានឡើយ ។ បើយើងទំលាយហើយ ក៏ឈ្មោះថាយើងមិនស្មោះត្រង់ចំពោះខ្លួនយើង មិនឈ្មោះថារក្សាពាក្យសត្យ ឬដែលមានកិច្ចជាប់ទាក់ទងនឹងបុគ្គលដទៃ យើងក៏ត្រូវតែព្យាយាមរក្សាទុកកុំឲ្យឃ្លៀងឃ្លាត នឹងជាហេតុធ្វើខ្លួនយើងឲ្យជាទីរាប់អាន បានទទួលកិត្តិយសជាមនុស្សពិតត្រង់ព្រោះពាក្យសត្យ ហើយពាក្យសត្យជារបស់ដែលមិនចេះស្លាប់ អាចតាំងនៅប្រាកដដរាបដល់លោករលាយ លោកនឹងត្រូវកត់ត្រាចារឹកឈ្មោះទុកជានិច្ច ។

ពាក្យសត្យមានគុណានិសង្សដូចបរិយាយមកដោយសង្ខេប ៗ នេះ លោកទើបប្រៀនប្រដៅឲ្យរក្សា ដូចភាសិតថា "ស៊ូក្ស័យជីវិត មិនឲ្យបង់ពាក្យសត្យ" សំគាល់សេចក្ដីថា យើងបានប្ដេជ្ញាដោយកាយវាចាឬចិត្តយ៉ាងដូចម្ដេចហើយ យើងត្រូវតែព្យាយាមធ្វើឲ្យបានពិតប្រាកដដូច្នោះដែរ ស៊ូម្បីជីវិតនឹងដាច់រលត់ទៅក៏មិនហ៊ានលះបង់ពាក្យសត្យចោលឡើយ ។ អត្ថបទនេះមានព្រះសម្មាសម្ពុទ្ធជាគំរូយ៉ាង ព្រះអង្គរក្សានូវពាក្យសត្យយ៉ាងពិតប្រាកដ ធ្វើសេចក្ដីព្យាយាមមិនលះបង់ ផលទីបំផុតព្រះអង្គបានជាព្រះបរមសាស្ដាឯកគង់លោក ឥតអ្នកណាស្មើ ព្រោះដូច្នោះលោកទើបប្រដៅថា "សច្ចំ ឧបនិក្ខេយ្យ, គប្បីរក្សាឲ្យ ៗ នូវពាក្យសត្យ" ដូច្នេះឯង ។

www.elibraryofcambodia.org

# ១៤. សន្តោស

## យំ លទ្ធំ តេន តុដ្ឋព្វំ

បានរបស់ណា គប្បីត្រេកអរដោយរបស់នោះ

សន្តោស ប្រែថា សេចក្ដីពេញចិត្តតាមមានតាមបាន គឺមានយ៉ាងណាត្រេកអរយ៉ាងនោះ អាចកាត់សេចក្ដីអន្ទះអន្ទែងចង់មានចង់បានហួសហេតុចេញ ហើយកំណត់សេចក្ដីពេញចិត្តឲ្យតាំងនៅតែក្នុងខេត្តនៃរបស់ដែលមានដែលបានប៉ុណ្ណោះ ។

មែនពិត! បុគ្គលបើមិនមានធម៌ឯណាពំងពចិត្តខ្លះទេ សេចក្ដីចង់មានចង់បានហួសហេតុក៏កើតតែមានច្រើនឡើង គឺមានរបស់នេះហើយចង់បានរបស់នោះទៀត មានរបស់នោះហើយចង់បានរបស់ឯនោះមកទៀត មិនចេះឈប់គ្រប់គ្រាន់សោះ ធ្វើចិត្តឲ្យពាយមាយនឹងធ្វើឲ្យប្រាកដប្រជាមិនបាន ក្លាយទៅជាមនុស្សចាប់នេះចាប់នោះមិនចំពោះត្រង់ណា ហើយជាមនុស្សល្មោភណាស់ផង អាចកើតភយន្តរាយដែលធ្វើខ្លួនឲ្យសាបសូន្យចាករបស់ដែលគប្បីបានព្រោះការគិតដល់វត្ថុគ្រប់យ៉ាងច្រើនពេក នាំឲ្យចាប់អ្វីមិនប្រាកដ, ផលទីបំផុតក៏ទទេឥតបានការអ្វី ដូចក្រសែទឹកដែលហូរទៅច្រើនផ្លូវ មិនមានកម្លាំងដូចទឹកដែលហូរទៅតែមួយផ្លូវទេ នេះឯងជាទោសរបស់ការមិនមានសន្តោស បើមានសន្តោសហើយ ចិត្តក៏ស្ងប់មិនមានការរវូរបុះឡើយ ។

តែការមានសន្តោសមិនបានសំដៅសេចក្តីថា ឲ្យមនុស្សងាស់ដៃងាស់ជើង មិនបង់ធ្វើអ្វីសោះ ហើយចាំឲ្យវត្ថុផ្សេង ៗ ហូរចូលមកឯង យ៉ាងនេះមិនមែនជាលក្ខណៈសន្តោស គឺជាលក្ខណៈរបស់កោសជ្ជៈសេចក្តីខ្ជិលច្រអូសទៅវិញ, សេចក្តីខ្ជិលច្រអូសជាសត្រូវយ៉ាងខ្លាំងក្លាចំពោះអាជីវកម្មរបស់មនុស្ស ហើយទំងជាសត្រូវរបស់ការប្រព្រឹត្តធម៌ធ្វើចិត្តឲ្យរុញ្ញាព, អ្នកមានសន្តោសនោះត្រូវធ្វើយ៉ាងឃ្មាតខ្មី លទ្ធផលដែលគប្បីកើតបានចាកការងារនេះប៉ុន្មានក៏ត្រេកអរប៉ុណ្ណោះ មិនអន្ទះអន្ទែងចង់បានទៅក្នុងផ្លូវទុច្ចរិតស៊ីតែប្រកបកិច្ចធ្វើឲ្យលទ្ធផលនោះ លូតលាស់ល្អបរិបូណ៌ ដោយលំដាប់ដូចសម័យនេះយើងធ្វើស្រែ លទ្ធផលក៏បានទទួលតាមការងារដែលយើងធ្វើ គឺល្មមចាយវាយមិនខ្វះខាត តាំងចិត្តធ្វើយ៉ាងពិតប្រាកដ ប្រកបការងារហើយទំងមិនលេងល្បែងស៊ីសងមិនចាយវាយខ្ជះខ្ជាយពេក, ឋានៈរបស់យើងក៏ល្មមទំងតាំងខ្លួនបាន មិនបាច់ទៅរករបរដទៃទៀតដែលជាការផុតវិស័យ ដូចចង់ធ្វើភ្នាក់ងាររាជការមានបៀវត្សរ៍ជាដើមឬចង់ធ្វើជាភ្នាក់ងាររាជការថ្នាក់នោះថ្នាក់នេះខំខ្វល់ខ្វាយឲ្យវិសេសឡើងទៅទៀត ដោយប្រចុះប្រចែងអែបអបបុគ្គលនោះ បុគ្គលនេះផ្តេសផ្តាសឥតគោលចារឹក, ផលដែលបានទទួលច្រើនមិនល្មមទំងផលដែលបង់ខាតទៅវិញ ។ មែនពិត ! ការដែលអន្ទះអន្ទែងចង់បាននោះ ក៏ជាបច្ច័យមួយអាចឲ្យឈានឡើងទៅកាន់ទីណាថ្នាក់ខ្ពស់បានដែរ តែត្រង់ទីនេះសំគាល់ថាការអន្ទះអន្ទែង

www.elibraryofcambodia.org

ចង់បានហួសឋានៈដែលខ្លួនត្រូវបាន ក៏ជាហេតុមួយឲ្យកើតផលអាក្រក់នោះឯង, ឯផ្លូវល្អយើងមាននាទីយ៉ាងណា ក៏ព្យាយាមធ្វើនាទីនោះយ៉ាងម៉ឺងម៉ាត់ ឲ្យការងារតំណើរទៅដោយល្អ រក្សាឲ្យរៀបរយ មិនត្រូវប្រចុប ប្រចែងអែបអបឲ្យខូចវេលា, លោកអ្នកមានឋានៈខ្ពស់ៗជាងយើង លោកឃើញសេចក្ដីល្អនិងសមត្ថភាពរបស់ខ្លួនយើងហើយ លោកក៏រំកិលឲ្យយើងឡើងថ្នាក់ទៅឯង ៗ យើងក៏មិនត្រូវក្ដៅក្រហាយ សូម្បីមិត្តភក្ដិបានល្អក៏មិនឫស្យា យើងបានត្រឹមណាក៏ត្រេកអរត្រឹមណោះ មិនឲ្យកើតសេច-ក្ដីក្ដៅក្រហាយ រាប់ថាមានកំណប់ទ្រព្យដ៏ប្រសើរក្នុងដៃនៃយើង ព្រោះ

www.elibraryofcambodia.org

សេចក្ដីត្រូវការរបស់យើងល្មមសមគួរតាមដែលយើងគួរបាន ចាត់ថាជាទ្រព្យយ៉ាងប្រសើរក្រៃលែង សមនឹងភាសិតក្នុងធម្មបទខុទ្ទកនិកាយថា "សន្តុដ្ឋី បរមំ ធនំ, សេចក្ដីសន្ដោសជាទ្រព្យដ៏ក្រៃលែង" នេះបញ្ជាក់ឲ្យឃើញថាសន្ដោសអាចកាត់សេចក្ដីក្រវល់ក្រវាយឲ្យដាច់ចេញបាន, បើ-មានយ៉ាងណា ប្រើប្រាស់យ៉ាងនោះ, បើបានយ៉ាងណា ត្រេកអរយ៉ាងនោះ ចិត្តក៏ជាសុខ មិនអន្ទះអន្ទែងក្ដៅក្រហាយឡើយ ។

ព្រោះហេតុនោះ លោកទើបណែនាំឲ្យត្រេកអរចំពោះតែរបស់ដែលបាន មិនឲ្យអន្ទះសាចង់បានហួសហេតុ ទើបចិត្តជាសុខ មិនបានត្រាច់ទៅផ្ដេសផ្ដាសក្នុងផ្លូវទុច្ចរិតឡើយ ហេតុនោះភាសិតខាងដើម

ទើបលោកប្រៈដៅថា "យំ លទ្ធំ តេន តុដ្ឋព្វំ, បានរបស់ណា គប្បីត្រេកអរដោយរបស់នោះ" ដូច្នេះឯង ។

## ១៥. សាមគ្គី

សព្វេសំ សង្ឃភូតានំ សាមគ្គី វុឌ្ឍិសាធិកា

សេចក្ដីព្រមព្រៀងរបស់ជនទាំងពួងជាពួក ញុំាងសេចក្ដីចំរើនឲ្យសម្រេច ។

សាមគ្គី គឺសេចក្ដីព្រមព្រៀងស្រុះស្រួលគ្នា ដោយកម្លាំងកាយជួយ

www.elibraryofcambodia.org

ធ្វើការងារមិនទទឹងទាស់ មានចិត្តជាឯកច្ឆន្ទរួមគំនិតគ្នា មិនយូរប៉ុន្មានក៏ជាប់បានដល់សេចក្ដីចំរើន ។

ជនទាំងឡាយនឹងនៅតែម្នាក់ឯងមិនបាន ត្រូវអាស្រ័យរួមគ្នាជាពួក ដោយរួមត្រកូលខ្លះ រួមការងារខ្លះ រួមការចិញ្ចឹមជីវិតខ្លះ ប្រព្រឹត្តធម៌រួមគ្នាខ្លះ ត្រូវអាស្រ័យរក្សាទឹកចិត្តរបស់គ្នានឹងគ្នា ឲ្យមានសេចក្ដីស្រុះស្រួលរួមគំនិតគ្នា ទើបនឹងកើតសុខ, សេចក្ដីព្រមព្រៀងស្រុះស្រួលគ្នានោះ ហៅថាសាមគ្គីៗ នេះចែកចេញជា ២ ប្រភេទគឺ កាយសាមគ្គី សេចក្ដីព្រមព្រៀងគ្នាធ្វើការងារដោយកម្លាំងកាយ ១ ចិត្តសាមគ្គី សេចក្ដីព្រមព្រៀងដោយមានចិត្តជាឯកច្ឆន្ទរួមគ្នា ១, ឯសាមគ្គីនឹងចំរើនដុះដាល

លូតលាស់ល្អបាន ត្រូវអាស្រ័យសង្គហវត្ថុ[1]ធម៌ជួយទំនុកបំរុងផង ។

មែនពិត! រាងកាយនេះ គឺ អវយវៈទាំងឡាយសឹងមាននាទីដែរ រក្សារាងកាយដូចគ្នាគ្រប់ៗ បំណែក ដូចដៃជើងមាននាទីសម្រាប់រត់ទៅរកអាហារមកបំពេញពោះ ធ្មេញមាននាទីដែលទំពាអាហារឲ្យល្អិត, បំពង់កមាននាទីលេបអាហារចូលទៅធ្វើឲ្យរលួយ សម្រាប់ចិញ្ចឹមរាងកាយ បើអវយវៈអម្បាលនេះបំណែកណាមួយពិការ ឬមិនព្រមព្រៀងគ្នាធ្វើតាមនាទីរបស់ខ្លួនទេ រាងកាយនឹងទ្រុឌទ្រោមទៅៗ បចេញមកខាងក្រៅជារោគភ័យផ្សេងៗ ។ រាងកាយត្រូវតែអាស្រ័យអវយវៈផ្សេងៗ ដែលមានសាមគ្គីព្រមព្រៀងគ្នាដូចម្ដេច សម្រាប់ពួកមនុស្សក៏ត្រូវមានសាមគ្គីដូច្នោះដែរ ។ មនុស្សទាំងឡាយរួមគ្នាជាពួក ត្រូវតែអាស្រ័យកម្លាំងរបស់គ្នានឹងគ្នា ជួយធ្វើកិច្ចការគ្នាឲ្យសម្រេចបាន តែត្រឹមកម្លាំងកាយប៉ុណ្ណោះនៅមិនទាន់ល្មមទេ ត្រូវអាស្រ័យកម្លាំងចិត្តរួមគ្នាផង ព្រោះថាជួនកាលយើងរួមកម្លាំងកាយគ្នាធ្វើកិច្ចការផ្សេងៗ ដោយសារតែគេបង្ខិតបង្ខំឬក៏ខានមិនបាន កិច្ចការដែលធ្វើនោះក៏នៅតែមិនបានសម្រេចដោយល្អ លុះតែអាស្រ័យសាមគ្គីធម៌ចិត្តរួមគ្នាជាឯកច្ឆន្ទផង ទើបនឹងសម្រេចបានយ៉ាងបរិបូណ៌ ។

---

១ សង្គហវត្ថុ៤ គឺ: ១- ទាន: បែងចែកវត្ថុរបស់ខ្លួនឲ្យដល់មនុស្សដែលគួរឲ្យ; ២- បិយ-វាចា ពោលវាចាពីរោះជាទីស្រឡាញ់; ៣- អត្ថចរិយា ប្រព្រឹត្តក្នុងការជាប្រយោជន៍ដល់អ្នកដទៃ; ៤- សមានត្តតា ជាអ្នកតាំងខ្លួនស្មើ គឺមិនប្រកាន់ខ្លួន ។

www.elibraryofcambodia.org

សរុបសេចក្ដីថា កិច្ចការគ្រប់យ៉ាងទាំងផ្លូវលោកនិងផ្លូវធម៌ ត្រូវអាស្រ័យសាមគ្គីជាគោលទាំងអស់ ៗ ពួកគណៈដែលនឹងបានសេចក្ដីសុខ-ចំរើនដោយឆាប់រហ័ស មិនមានថ្ងៃណាសាបសូន្យនោះ ដូចសាមគ្គីក្នុងផ្លូវធម៌ អ្នកប្រព្រឹត្តធម៌រួមគ្នា សឹងមានកាយសាមគ្គីព្រមព្រៀងគ្នាលើកលែងធ្វើ នឹងព្រមព្រៀងគ្នាធ្វើកិច្ចរបស់ពួកគណៈ ទើបប្រាថ្នាសេចក្ដីសុខ-ចំរើនបានដោយពិតប្រាកដ មិនមានសេចក្ដីសាបសូន្យឡើយ សមនឹងភាសិតក្នុងធម្មបទ ខុទ្ទកនិកាយថា "សុខា សង្ឃស្ស សាមគ្គី, សេចក្ដីព្រមព្រៀងរបស់ពួកនាំឲ្យកើតសុខ" ដូច្នេះ ជាគ្រឿងបញ្ជាក់ថា

www.elibraryofcambodia.org

សេចក្ដីសុខ- ចំរើនទាំងឡាយត្រូវតែមានសាមគ្គីនឹងខានមិនបានយ៉ាងដាច់ខាត, មនុស្សត្រូវតែរក្សាសាមគ្គីឲ្យគង់ជាវរៈមាននៅគ្រប់ពួកគ្រប់គណៈ តែធ្វើដូចម្ដេចទើបនឹងរក្សាសាមគ្គីបាន, ខនេះត្រូវអាស្រ័យសង្គហវត្ថុធម៌ ជាគ្រឿងទាញទឹកចិត្តរបស់ពួកគណៈ គឺចែកបាយវត្ថុតាមឋានៈដែលអាចធ្វើបាន ចរចាប្រស្រ័យដោយពាក្យដ៏ពីរោះដល់ត្រចៀក បំពេញប្រយោជន៍តាមសម័យ មិនមានអាការប្រកាន់ខ្លួនប្រាណ ប្រកាន់យសស័ក្ដិ អម្បាលនេះជាគ្រឿងរក្សាសាមគ្គីឲ្យគង់ទ្រង់នៅបានមាំមួន ៗ

កាលបើរក្សាសាមគ្គីឲ្យមាននៅក្នុងពួកគណៈហើយនឹងប្រាថ្នាអ្វីតទៅទៀតក៏ចេះតែបាន, រាងកាយរបស់យើងអាស្រ័យអវយវៈគ្រប់ផ្នែកព្រម

ព្រៀងគ្នា ធ្វើឲ្យរាងកាយបានសុខបរិបូណ៌ ជាហេតុឲ្យប្រកបកិច្ចការ សេចក្ដីចំរើនបានពេញទី សូម្បីរាងកាយតែមួយរបស់មនុស្សម្នាក់ៗអាច អំណោយប្រយោជន៍មានសភាពប៉ុណ្ណេះទៅហើយ ចុះបើប្រសិនជាមាន កាយច្រើន ចិត្តច្រើនរួមកម្លាំងគ្នា តើនឹងមានគុណត្រឹមណាទៅទៀត មិនចាំបាច់ពោលឲ្យវែងឆ្ងាយទេ ព្រោះគ្រប់ពួកគ្រប់គណៈត្រូវការសេចក្ដី សុខសេចក្ដីចំរើនទាំងអស់ មិនយូរប៉ុន្មានក៏សម្រេចបានផលប៉ៗ ដោយ អាស្រ័យគោលនៃសាមគ្គី ទើបសមតាមបាលីខាងដើមថា "សព្វេសំ សង្ឃភូតានំ សាមគ្គី វុឌ្ឍិសាធិកា, សេចក្ដីព្រមព្រៀងរបស់ជនទាំងពួង ជាពួក ញុំាងសេចក្ដីចំរើនឲ្យសម្រេច" ដូច្នេះឯង ។

www.elibraryofcambodia.org

## ១៦. បកិណ្ណក (ធម៌ពយរង)

រូបំ ជីរតិ មច្ចានំ នាមគោត្តំ ន ជីរតិ

រូបរបស់សត្វទាំងឡាយតែងគ្រាំគ្រា ឯនាមនឹងគោត្រមិនចេះគ្រាំ គ្រាឡើយ ។

សត្វទាំងឡាយដែលកើតមកក្នុងលោក រាងកាយគឺគ្រោងឆ្អឹងមាន សាច់រុំព័ទ្ធនេះ ជារបស់ត្រូវទំលាយទៅក្នុងកាលជីវិតរលត់, តែនាមនឹង គោត្រគឺវង្សត្រកូល (នាមត្រកូល) មិនឃ្លាតបាត់អំពីការចងចាំរបស់ លោកនឹងត្រូវជាប់ជាគោលចារិកនៅក្នុងលោកជានិច្ច ទាំងគោត្រ នាមខាងល្អ ទាំងគោត្រនាមខាងអាក្រក់ ។

របស់ដែលមើលឃើញបានហៅថារូប តែក្នុងទីនេះសំដៅយកអត្តភាព គឺខ្លួនប្រាណរបស់មនុស្សសត្វទៅ រាងកាយនៃមនុស្សសត្វនេះ ជារបស់ដែលតាំងនៅបានដោយអាស្រ័យធម្មជាតិមួយយ៉ាង ធម្មជាតិនេះ ហៅថាជីវិត ។ ក្នុងវេលាដែលមនុស្សសត្វមានជីវិតនោះ រាងកាយក៏ស្រស់បំព្រងនៅបាន ដោយអាស្រ័យគ្រឿងចិញ្ចឹមរក្សាឲ្យរស់នៅ បើជីវិតរលត់ហើយ រាងកាយក៏អស់គ្រឿងចិញ្ចឹមរក្សាដែរ ព្រោះថាគ្រឿងចិញ្ចឹមរក្សានោះបានដល់ធាតុ ៤ ក្នុងខ្លួនមនុស្សសត្វ គឺធាតុដែលមានលក្ខណៈរឹង ហៅថាបឋវីធាតុ, ធាតុដែលមានលក្ខណៈរាវ ជ្រួតជ្រាប ហៅថាអាបោធាតុ, ធាតុដែលមានលក្ខណៈបក់ទៅមក ហៅថាវាយោធាតុ, ធាតុដែលមានលក្ខណៈក្តៅ ហៅថាតេជោធាតុ ; បើធាតុទាំង ៤ នេះរលាយចេញពីគ្នាទៅហើយ ជីវិតក៏តាំងនៅមិនបាន ត្រូវតែផុតរលត់ទៅដែរ ព្រោះសង្ខាររូបរាងកាយទាំងឡាយជារបស់ដែលធាតុប្រជុំគ្នាតាក់តែងឡើង បាត់ជាជារបស់មិនទៀង សេចក្តីទៀងទាត់មិនមានក្នុងសង្ខារទេ ទើបសមនឹងភាសិតក្នុងធម្មបទខុទ្ទកនិកាយថា “សង្ខារា សស្សតា នត្ថិ, សង្ខារទាំងឡាយឥតទៀងទាត់ទេ” ដូច្នេះ ។ សរុបសេចក្តីថា វត្ថុទាំងឡាយក្នុងលោកនេះជារបស់ដែលត្រូវតែបែកធ្លាយរលត់រលាយទាំងអស់ មិនមានរបស់ណាគង់ទ្រង់នៅបានឡើយ, មានតែសេចក្តីល្អ សេចក្តីអាក្រក់ប៉ុណ្ណោះទេ ដែលជារបស់អាចតាំងនៅបានប្រា-

www.elibraryofcambodia.org

កដដរាបមកដល់សព្វថ្ងៃនេះ ។

ប៉ុន្តែមនុស្សសត្វទាំងឡាយដែលកើតមកនោះ បើនិយាយចំពោះតែពួកមនុស្ស ត្រូវមានពាក្យប្រើជំនួសឈ្មោះសម្រាប់ហៅរកគ្នា ដូចគេសន្មតថា ឈ្មោះនោះ ឈ្មោះនេះមាននាយ ៣៣ នាយ ១ ជាដើម ដើម្បីកុំឲ្យភាន់ច្រឡំឈ្មោះរបស់មនុស្សផងគ្នា ក្នុងកាលវង្សត្រកូលកើតកាន់តែច្រើនៗឡើង, ចំពោះវង្សញាតិជាមួយគ្នា ក៏មានពាក្យសន្មតជំនួសពួកនោះទៀតថា គោត្រ (នាមត្រកូល) ជាគ្រឿងសំគាល់ពូជអម្បូរ (ពប់ខាងបិតា), នាមនិងគោត្រទាំង ២ ប្រការនេះ ជារបស់ដែលមិនចេះសាបសូន្យលេចផុតពីលោកទេ ព្រោះជារបស់សន្មតបានចំពោះពួកមនុស្សទូទៅ, ប៉ុន្តែគ្នាតែនាមនិងគោត្រប្រាកដនៅក្នុងផ្លូវល្អ ឬអាក្រក់ប៉ុណ្ណោះ បើប្រព្រឹត្តទៅក្នុងផ្លូវល្អ នាមនោះក៏ចារឹកនៅក្នុងបវត្តិការណ៍ខាងល្អ បានទទួលការសរសើរលើកតំកើង ធ្វើឲ្យនាមនិងគោត្រត្រកូលរបស់ខ្លួន ។ នោះក្រអូបឈ្ងុយឈ្ងប់អាចឲ្យអ្នកដទៃធ្វើតាម ថាបើប្រព្រឹត្តទៅក្នុងផ្លូវអាក្រក់វិញ ក៏ធ្វើឲ្យនាមនិងគោត្រនេះសៅហ្មងសូម្បីទីងតាំងនៅប្រាកដបាន ក៏ជារបស់ដែលគេមើលទៅឃើញថាមិនល្អទាំងអស់ ហាក់ដូចជាត្រកូលដែលចាញ់សម្បថរួចទៅហើយ ។

ព្រោះហេតុនោះ មនុស្សទាំងឡាយទើបគួរព្យាយាមធ្វើសេចក្តីល្អទុក ដើម្បីឲ្យនាមនិងគោត្រត្រកូលរបស់ខ្លួនតាំងនៅប្រាកដដរាបដល់

លោករលាយរលត់, ឯសេចក្ដីអាក្រក់គួរតែព្យាយាមលះចេញកុំធ្វើ ។

ព្រះសម្មាសម្ពុទ្ធរបស់យើងទាំងអស់ ឬអ្នកប្រាជ្ញទាំងឡាយដែលបានល្អប្រសើរក្នុងផ្លូវកិត្តិគុណនោះ ព្រោះតែលោកបានធ្វើប្រយោជន៍ទុកដល់លោកជាអនេកប្បការ សូម្បីសង្ខាររូបរាងកាយនឹងត្រូវបែកធ្លាយរលត់ទៅព្រោះជារបស់ធម្មតាក៏ដោយ ក៏កិត្តិនាមរបស់លោកតាំងនៅប្រាកដដរាបមកដល់សព្វថ្ងៃនេះបាន, ហេតុនោះ ទើបសមនឹងភាសិតខាងដើមថា "រូបំ ជីរតិ មច្ចានំ នាមគោត្តំ ន ជីរតិ, រូបរបស់សត្វទាំងឡាយតែងគ្រាំគ្រា ឯនាមនឹងគោត្រមិនចេះគ្រាំគ្រាឡើយ" ដូច្នេះឯង ។

## ១៧ កតញ្ញូកតវេទី

www.elibraryofcambodia.org

### ឆមិត្តំ សាធុរូបានំ កតញ្ញូកតវេទិតា

ភាពជាអ្នកកតញ្ញូកតវេទី ជាគ្រឿងសំគាល់របស់មនុស្សល្អ.

បុគ្គលណាបានទទួលសេចក្ដីទំនុកបំរុង ដែលបុគ្គលដទៃធ្វើដល់ខ្លួន ហើយដឹងគុណគេមិនភ្លេច តែងនឹករឭកឃើញជារឿយ ៗ បុគ្គលនោះឈ្មោះថាកតញ្ញូ ។ អ្នកដែលដឹងគុណគេហើយបានធ្វើតបស្នងសងគុណវិញមិនធ្វើព្រងើយកន្តើយ ហៅថាកតវេទី ។ កតញ្ញូកតវេទីនេះជាគ្រឿងសំគាល់របស់មនុស្សល្អ សេចក្ដីថា បុគ្គលដែលបានឈ្មោះថាជាអ្នកល្អនោះ ត្រូវមានធម៌ ២ ប្រការនេះជានិមិត្តគ្រឿងសំគាល់ ។

បើនិយាយដោយសាធារណៈ បុគ្គលណាក៏ដោយ ត្រូវតែមានការជាប់ទាក់ទងនឹងបុគ្គលដទៃជាធម្មតា ប៉ុន្តែបើនិយាយតាមលំអានដែលតែងតែមានមកនោះគឺ មាតាបិតានឹងបុត្តធីតា ១ ព្រះសម្ពុទ្ធនឹងពុទ្ធសាសនិកជន ១ គ្រូបាអាចារ្យនឹងសិស្ស ១ ព្រះមហាក្សត្រនឹងប្រជាជន ១ ៗ បុគ្គលទាំង ៤ ពួកនេះតែងមានឧបការបដិការដល់គ្នានឹងគ្នាយ៉ាងពិតប្រាកដ គឺមាតាបិតាតែងមានឧបការគុណដល់បុត្តធីតាយ៉ាងលើសលុប នឹងប្រមាណមិនបាន, លោកខំស្វាហាប់ថ្នាក់ថ្នមកូនមកតាំងពីតូចដរាបដល់ធំ រហូតដល់ការរៀបចំកូនឲ្យមានផ្ទះសម្បែង បែងចែកទុនទ្រព្យឲ្យប្រកបការចិញ្ចឹមជីវិតជាដើម, កាលបុត្តធីតាបានទទួលឧបការគុណដូច្នេះហើយ តែងនឹករឭកឃើញជារឿយៗ គឺមិនភ្លេចគុណដ៏ខ្ពង់ខ្ពស់នោះសោះ, សូម្បីលោកមានឱវាទដាស់តឿនដោយប្រការយ៉ាងណា ក៏ប្រតិបត្តិតាមដោយប្រការយ៉ាងនោះ ការដែលលោកណែនាំដូច្នោះក៏ដោយមានសេចក្តីអាណិតអាសូរ ការដែលកូនធ្វើតាមពាក្យរបស់លោកអ្នកអាណិតអាសូរ ហើយមិនមានសេចក្តីវិនាសឡើយ ព្រោះលោកណែនាំតែគន្លងផ្លូវដែលល្អ ស្រមដូចបាលី ក្នុងទសកនិបាតជាតកថា "ករេយ្យ វាក្យំ អនុកម្បកានំ, ត្រូវធ្វើតាមពាក្យរបស់អ្នកអាណិតអាសូរ" ដូច្នេះជាដើម ចាត់ថាកតញ្ញូ ៗ កាលបើភ្ញា រឭកការគុណទាំងធ្វើតបស្នងសងគុណលោកវិញ ក៏ធ្វើតបគុណលោកហើយមិនព្រងើយកន្តើយ, សូម្បីមាតាបិតាធ្វើមរណកាលទៅ

www.elibraryofcambodia.org

ហើយបានលើកសពសក្ការដោយគោរពយ៉ាងថ្លិតថ្លង់ ធ្វើទក្ខិណានុប្បទាន ឧទ្ទិសផលបុញ្ញទៅលោកហើយ ។ ដូច្នេះហៅថាកតវេទី ។

**ព្រះសម្ពុទ្ធ នឹងពុទ្ធសាសនិកជនៈ** ព្រះសម្មាសម្ពុទ្ធជាអច្ឆរិយមនុស្ស ឬមនុស្សអស្ចារ្យ ព្រះអង្គជាគ្រូរបស់យើងទ្រង់មានព្រះហឫទ័យពេញពោរដោយសេចក្ដីអាណិតអាសូរ ទ្រង់បង់ឲ្យសត្វលោករួចរដោះចាកទុក្ខទាំងពួង, កាលព្រះអង្គជិតចូលព្រះបរមនិព្វាន ទ្រង់ចំផ្លៀតប្រទានឱវាទផ្ដាំថា "អ្នកទាំងឡាយ ចូរញុំាងសេចក្ដីមិនប្រមាទឲ្យដល់ព្រម" ដូច្នេះជាដើម ដោយហេតុនេះ យើងជាពុទ្ធសាសនិកជន គួរប្រតិបត្តិកាន់តាមលំអានធម្មវិន័យពុទ្ធសាសនាដែលជាផ្លូវនាំយើង ឲ្យបានចួបប្រទះសេចក្ដីសុខព្រមទាំងសេចក្ដីចំរើនរុងរឿង យើងទើបបានឈ្មោះជាកតញ្ញូកតវេទីចំពោះព្រះអង្គ ។

www.elibraryofcambodia.org

**គ្រូបាអាចារ្យនឹងសិស្សៈ** គ្រូបាអាចារ្យដែលបង្ហាត់ បង្រៀន ប្រដៅចំណេះវិជ្ជា ឬប្រៀនប្រដៅចំពោះធម៌ទំនៀមទម្លាប់ត្រឹមត្រូវដល់កូនសិស្សយ៉ាងពិតប្រាកដ ដែលជាពាក្យមានប្រយោជន៍ គួររៀនគួរស្ដាប់ យើងបានស្ដាប់ពាក្យនោះចាំបានហើយយកមកត្រិះរិះប្រតិបត្តិតាមទៅកើតសេចក្ដីសុខចំរើន យើងត្រូវដឹងគុណលោក ហើយតបគុណលោកកុំភ្លេចឲ្យសោះ យើងទើបបានឈ្មោះជាកតញ្ញូកតវេទី ។

ព្រះមហាក្សត្រនឹងប្រជាជនៈ ព្រះមហាក្សត្រដែលគ្រប់គ្រងប្រជារាស្ត្រ ឬគ្រប់គ្រងប្រទេសនីមួយ ៗ ដោយព្រះគុណដ៏ប្រសើរ ឲ្យបានទទួលសេចក្ដីត្រជាក់ត្រជុំជាសុខស្ថាពរ, ប្រជាជនទាំងឡាយដែលបានសេចក្ដីសុខដោយសារការគ្រប់គ្រងរបស់ព្រះរាជាដូច្នេះហើយ ក៏ត្រូវនឹករឭកដល់ព្រះគុណរបស់ព្រះអង្គ ហើយតាំងចិត្តស្មោះត្រង់ស្វាមីភក្ដិចំពោះព្រះរាជាដោយស្មោះស្ម័គ្រ លះសួយសារអាករជាពលីឧទ្ទិសថ្វាយឲ្យជាកម្លាំងក្នុងការគ្រប់គ្រងប្រទេសជាតិ យ៉ាងនេះហៅថាកតញ្ញូកតវេទី ។

កតញ្ញូនឹងកតវេទីនេះ បើមានក្នុងសន្ដានរបស់អ្នកណាហើយ ជាគ្រឿងកំណត់សំគាល់ថាwww.elibraryofcambodia.orgក្នុងសន្ដានបុគ្គលណា បុគ្គលនោះក៏ឈ្មោះថាជាមនុស្សល្អ, បើបុគ្គលណាមិនមានធម៌ទាំង ២ ប្រការនេះទេ នឹងចាត់បុគ្គលនោះថាជាមនុស្សល្អមិនបាន គឺត្រឡប់ជាមនុស្សអាក្រក់ទៅវិញ ។

ឯទៀត កតញ្ញូកតវេទីជានិមិត្តគ្រឿងសំគាល់របស់សប្បុរសគឺមនុស្សល្អ ដូចលោកសំដែងទុកក្នុងសប្បុរិសបញ្ញត្តិដែលជាប់ទាក់ទងនឹងមាតាឧបដ្ឋាន ការប្រតិបត្តិមាតាបិតាតាមគន្លងធម៌ដូច្នេះ ដើម្បីបញ្ជាក់ឲ្យឃើញនូវគុណធម៌ ២ ប្រការនេះជាគន្លងប្រាប់ឲ្យដឹងថាមនុស្សល្អ នឹងមនុស្សអាក្រក់ ។ បើបុគ្គលណាមិនមានកតញ្ញូកតវេទីនេះ បុគ្គលនោះក៏បាត់

ថាជាមនុស្សអាក្រក់ដោយពិតប្រាកដ ដូចជាបុត្តធីតាដែលមិនមានធម៌ទាំង២ប្រការនេះ ក៏បានឈ្មោះថាជាបុត្តធីតាដ៏អាក្រក់ថោកទាបពន់ពេក, សូម្បីបុគ្គល ៣ ពួកទៀតគឺ ពុទ្ធសាសនិកជន, កូនសិស្សនឹងប្រជាជនក៏ដូចគ្នាដែរ បើមានព្រមក្នុងសន្តានអ្នកណាហើយ ក៏ជាគ្រឿងសំគាល់ថាអ្នកនោះជាមនុស្សល្អ ទើបសមនឹងបាលីខាងដើមថា “ និមិត្តំ សាធុ-រូបានំ កតញ្ញូកតវេទិតា, ភាពជាអ្នកកតញ្ញូកតវេទី ជាគ្រឿងសំគាល់របស់មនុស្សល្អ ” ដូច្នេះឯង ។

## ១៨. កាម

www.elibraryofcambodia.org

ន កហាបណវស្សេន តិត្តិ កាមេសុ វិជ្ជតិ

សេចក្ដីឆ្អែតក្នុងកាមទាំងឡាយ ដោយភ្លៀងគឺកហាបណៈមិនមានឡើយ ។

បុគ្គលដែលសម្បូរដោយទ្រព្យសម្បត្តិ វង្វេងនៅក្នុងកាមគុណ មិនចេះនឿយណាយ មិនមានវេលាល្មមសោះឡើយ, សូម្បីនឹងមានឫទ្ធិអំ-ណាចអាចទះដៃឲ្យភ្លៀងកែវ៧ប្រការធ្លាក់ចុះមកអំពីអាកាសដូចជាទឹកភ្លៀងហើយបានសោយរមណីយសម្បត្តិដ៏ឧឡារិក ក៏នៅតែមិនចេះធុញទ្រាន់នឿយណាយឆ្អែតស្កប់ស្កល់ដែរ ។

កាមគុណគឺ រូប, សម្លេង, ក្លិន, រស, ផោដ្ឋព្វៈ ទាំងនេះជាគ្រឿងជន្ទេញជន្ទូចចិត្តនាំឲ្យបុគ្គលវង្វេងក្នុងកាលមិនមានសតិទប់ទាញ មិន

ចេះឆ្អែតស្កប់ស្កល់ល្មមសោះឡើយ ដូចបានរូបដែលល្អស្រស់បស់មក ហើយ នៅប្រាថ្នាសម្លេងដែលពីរោះដល់ត្រចៀកទៀត លុះបានដូច្នោះ ហើយ ក៏នៅតែមិនស្កប់ចិត្តដែរ រឹតតែប្រាថ្នាឲ្យវិសេសជាងនោះឡើងទៅទៀត, ព្រោះរបស់ទាំងនេះជាទីប្រាថ្នាស្រឡាញ់ពេញចិត្ត ។ បុគ្គលណានៅច្របូកច្របល់ដោយកាមគុណ បុគ្គលនោះកម្រដែលនឹងរើខ្លួនចេញឲ្យរួច រឹតតែកំរើក ខ្វះខាត ស្វែងរក មិនមានវេលាឆ្អែតស្កប់ស្កល់ ព្រោះកាមគុណជាគ្រឿងជន្លួនចិត្តឲ្យកើតតណ្ហា ឲ្យអន្ទះអន្ទែងចង់បានមិនចេះឆ្អែតមិនចេះពេញ ។ សូម្បីទន្លេទាំងឡាយមានវេលាគន្ទះក្នុងកាលទឹកស្រក មានវេលាពេញពកក្នុងកាលទឹកឡើងប្រៀបប្រាំង, ចំណែក

www.elibraryofcambodia.org

ខេត្តដែនរបស់តណ្ហានោះមិនមានទណ្ឌកំរិតទេ នឹងយកទន្លេមកប្រៀបនឹងតណ្ហារបស់មនុស្សមិនបានឡើយ ព្រោះតណ្ហាមិនមានវេលាពេញ ព្រោះហេតុនោះ សមដូចសុភាសិតក្នុងធម្មបទ ខុទ្ទកនិកាយថា " នត្ថិ តណ្ហាសមា នទី, នទីស្មើដោយតណ្ហាមិនមាន" ដូច្នេះឯង, កុំថាតែមនុស្សសាមញ្ញឡើយ សូម្បីលោកអ្នកមានបុណ្យអំណាចអាចនឹងបណ្ដាលឲ្យភ្លៀង គឺកែវ ៧ ប្រការធ្លាក់ចុះមកអំពីអាកាសបានដោយការទះដៃតែម្ដង ក៏នៅតែមិនចេះល្មមដែរ ចំពោះរឿងនេះមានព្រះបាទមន្ធាតុរាជជាឧទាហរណ៍ ព្រះអង្គសោយរាជសម្បត្តិ ជាក្សត្រទ្រង់មហិទ្ធិឫទ្ធិ អាចនិមិត្តទះព្រះហស្តតែម្ដងឲ្យភ្លៀង គឺកែវ ៧ ប្រការធ្លាក់ចុះទៅពេញពសុធាត្រឹម

ដង្គង់ ហើយទ្រង់ជាម្ចាស់នៃសម្បត្តិមានសភាពដូច្នោះ ៗ វត្ថុដែលខ្លួន ប្រាថ្នាទាំងឡាយជាសាធារណៈ សុទ្ធតែនឹងជ្រើសរើសយកតាមសេចក្តីពេញចិត្តបានទាំងអស់ នៅតែមានសេចក្តីប្រាថ្នាបង់ដំរិសេសជាងនេះទៅទៀត ផលទីបំផុតក៏ត្រូវស្លាប់ព្រោះតណ្ហា ។

កាមគុណជាគ្រឿងជន្លចិត្តបុគ្គលឲ្យវង្វេង មិនត្រឹមតែមនុស្សសាមញ្ញទេ សូម្បីលោកអ្នកមានឥទ្ធិឫទ្ធិរហូតដល់ទេវតា បើនៅស្រវឹងវង្វេងសេពកាមតាលតែភ្លេចសោយអាហារ ក៏ជាហេតុឲ្យច្យុតចាកស្ថានសួគ៌បាន ហៅថាអាហារក្ខយៈ ច្យុតព្រោះភ្លេចសោយអាហារ ៗ តែតាមពិត! កាមគុណក៏មានគុណខ្លះដែរ ព្រោះជាបច្ច័យឲ្យមនុស្សទាំងឡាយរហូតដល់ទេវតា មារ ព្រហ្មយមយក្សកំពូលពង្សបាន ដើម្បីការពារលោកកុំឲ្យស្ងាត់ស្រងេះស្រងោចពេក ជាកន្លែងកើតនៃមនុស្សសត្វទៅ ត្រូវតែមានកាមតណ្ហាគ្រប់គ្នាទាំងអស់ ប្លែកគ្នាតែច្រើនតិចប៉ុណ្ណោះ បើមានច្រើនពេកទៅក៏ជាហេតុឲ្យទោស តែទោះយ៉ាងណាក៏ដោយ បុគ្គលត្រូវតែមានសតិទប់ទាញកុំបណ្តោយឲ្យតណ្ហាគ្របសង្កត់ញាំញីពេក ព្រោះកាលបើមានតណ្ហាច្រើនឡើងហើយ លោកប្រៀបថាតណ្ហាក្តៅណាស់ សូម្បីភ្លើងក៏ក្តៅមិនដល់ ដោយការមិនមានវេលាឆ្អែតស្កប់ស្កល់ នៅតែខ្វះកន្ទះជានិច្ច សូម្បីអ្នកណានឹងកើបកោយយកមកឲ្យប៉ុន្មានក៏ដោយ ក៏នៅតែស្រេកឃ្លានចង់បានមិនចេះស្កាងសោះ ទើបសមនឹងសុភាសិតខាង

ដើមថា "ន កហាបណវស្សេន តិត្តិ កាមេសុ វិជ្ជតិ, សេចក្តីឆ្អែតក្នុងកាមទាំងឡាយដោយគ្រឿងគឺកហាបណៈមិនមានឡើយ" ដូច្នេះឯង ។

### ១៩. មលៈ (មន្ទិល)

អសជ្ឈាយមលា មន្តា

មន្តទាំងឡាយ មានការមិនស្វាធ្យាយជាមន្ទិល

មន្តក្នុងសុភាសិតនេះ គឺវិជ្ជាគ្រប់យ៉ាងដែលជាប់ទាក់ទងនឹងការស្វាធ្យាយទន្ទេញឲ្យចាំមាត់, បើអ្នករៀនសូត្រមិនស្វាធ្យាយបណ្តោយលះបង់ចោលការទន្ទេញហើយក៏កើតទៅជាមន្ទិល គឺស្រពេចស្រពិលមិនស្ទាត់ជំនាញទាំងអស់ ។

www.elibraryofcambodia.org

មន្តតាមដែលធ្លាប់ចូលចិត្តមក គឺពាក្យបាលី ដូចយ៉ាងទ្វាទសបរិត្តសត្តបរិត្តជាដើម ដែលភិក្ខុសាមណេរស្វាធ្យាយរាល់ថ្ងៃ តែតាមការពិតមិនមែនតែត្រឹមប៉ុណ្ណោះទេ សូម្បីវិជ្ជាការទាំងឡាយដែលជាប់ទាក់ទងនឹងរៀនត្រូវចាំទាំងផ្លូវលោកិយ ផ្លូវធម៌ ចាត់ថាជាមន្តទាំងអស់ ។ មន្តនេះ កាលបើអ្នកសិក្សាឧស្សាហ៍ស្វាធ្យាយជានិច្ច ឬហ្វឹកហាត់មើលជានិច្ចហើយ មន្តវិជ្ជាការនោះៗ ក៏ស្ទាត់ជំនាញឡើងមិនបេះគ្រុបសោះ អាចធ្វើឲ្យទៅជាអ្នកប្រាជ្ញប្រពៃគង់បាន ។ មន្តនេះបើអ្នកណាមិនយកចិត្តទុកដាក់លះបង់ការស្វាធ្យាយទន្ទេញចោលចេញហើយ គឺមិនមានព្យាយាមដែលនឹងស្វាធ្យាយទន្ទេញទេ មន្តនោះក៏ត្រូវឡប់ទៅជាមន្ទិល គឺមាន

អាការក្ងួចក្ងាំងមិនស្អាតជំនាញ ហើយមិនជាកន្ទួងកើតនៃបញ្ញាផង
ព្រោះបញ្ញាសេចក្ដីឈ្លាសវៃនឹងកើតចំរើនឡើងបាននោះ ត្រូវអាស្រ័យ
ការប្រកបព្យាយាមឲ្យត្រូវផ្លូវ ដូចបាលីក្នុងធម្មបទខុទ្ទកនិកាយថា "យោគា
វេ ជាយតេ ភូរិ, បញ្ញាវមែងកើតឡើងបាន ព្រោះសេចក្ដីព្យា-
យាម", កាលបើបណ្ដោយឲ្យមន្ទដែលគួរស្អាតឆ្ងាយក្ងួចក្ងាំងហើយបញ្ញា
ក៏មិនមានផ្លូវចំរើនលូតលាស់ឡើងបាន ទឹងធ្វើការអ្វីទៅក៏មិនជាការ
ប្រាកដប្រជាឡើយ ដូចយ៉ាងព្រះលោឡុទាយីជាតួយ៉ាង លោកជាអ្នក
អួតចេះដឹង អួតឈ្លាសវៃ រាយប៉ុកខ្លួនស្មើនឹងព្រះអគ្គសាវកទាំងពីរព្រះ
អង្គ ឃើញមនុស្សសរសើរលើកតំកើងលោកទាំងពីរ ក៏ចង់បានទទួលការ

www.elibraryofcambodia.org

សរសើរដូច្នោះដែរ ទើបបាននិយាយអួតអាងថា "កាលពួកលោកបាន
ស្ដាប់ព្រះអគ្គសាវកទេសនាក៏សរសើរម្ល៉េះទៅហើយ ប្រសិនបើខ្ញុំនឹងទេស-
នាវិញ ពួកលោកមុខជានឹងពេញចិត្តសរសើរខ្លាំងណាស់ទៅទៀត",
តែតាមការពិត លោកចេះដឹងតិចទេ ហើយប្រកបដោយសេចក្ដីខ្ជិលច្រ-
អូសផង និយាយដោយអាការក្រមាច់ ដើម្បីនឹងអួតអាងលើកតំកើងខ្លួន
ឯង ៗ សាសនិជនទាំងឡាយបានស្ដាប់ដូច្នោះហើយ ក៏ចូលចិត្តថាលោក
លោឡុទាយីនេះជាធម្មកថិកមួយយ៉ាងឯក ទើបបាននាំគ្នានិមន្តលោកឲ្យ
សំដែងធម្មទេសនាក្នុងវេលារសៀល លុះដល់វេលានោះហើយក៏ត្រឡប់
សូមផ្លាស់ម្ដូរពេលថាព្រលប់ៗសិនចាំទេសនា លុះដល់វេលានោះទៀតក៏

ត្រឡប់ផ្លាស់ប្តូរថាចាំយប់ជ្រៅបន្តិចសិន, ចាំជិតភ្លឺសិន, ចេះតែបណ្តោះ
បណ្តោយពេលវេលាដូច្នេះហើយ; ផលទីបំផុតត្រូវគេតៀនតន្ទើនឡើងៗ ក៏
ចាប់ផ្តិតឡើងអង្គុយលើគ្រែធម្មាសន៍ ផ្ទិតញ័រទទាក់ហាមាត់សំដែងជាអ្វីក៏
មិនកើត; ពួកអ្នកស្តាប់ទាំងឡាយ កាលបានឃើញដូច្នោះហើយក៏ស្អប់មុខ
ណាស់ នាំគ្នាគន្ទ្រាក់ជម្រុងដេញវាយស្ទើរតែចុះអំពីគ្រែធម្មាសន៍មិនទាន់
តែទៅធ្លាក់ក្នុងរណ្តៅភាបម៍ នេះឯងជាផលរបស់មនុស្សដែលអួតអាង
ហួសសមត្ថភាពរបស់ខ្លួន ហើយថែមទាំងមន្តក៏មានតិចតួចទៀតផង ។

ព្រោះហេតុនោះ មន្តទាំងឡាយក្នុងផ្លូវលោកក្តី ផ្លូវធម៌ក្តី ត្រូវអា-
ស្រ័យការស្វាធ្យាយទន្ទេញជានិច្ច ទើបនឹងចំរើនលូតលាស់ឡើងបាន,
បើមិនមានការស្វាធ្យាយទន្ទេញទេ ក៏ត្រឡប់ទៅជាមន្ទិលទោស អាច
ធ្វើឲ្យភ្លេចភ្លាំងមិនប្រាកដប្រជាជាក់លាក់ឡើយ មិនជាទីតាំងនៃប្រយោជន៍
គ្រប់យ៉ាង, ហេតុនោះ សុភាសិតនេះលោកទើបប្រដៅថា "អសជ្ឈា-
យមលា មន្តា, មន្តទាំងឡាយមានការមិនស្វាធ្យាយជាមន្ទិល" ដូច្នេះ
ឯង ។

## ២០. សន្តិ (សេចក្តីស្ងប់)

នត្ថិ សន្តិបរំ សុខំ

សេចក្តីសុខដទៃ ក្រៅពីសេចក្តីស្ងប់មិនមានឡើយ, ។

សុខគឺសេចក្តីសប្បាយកាយ សប្បាយចិត្ត, ចែកចេញជា២ ប្រការគឺ

www.elibraryofcambodia.org

អាមិសសុខ សុខប្រឡំដោយទុក្ខ ១ និរាមិសសុខ សុខប្រាសចាកទុក្ខ ១ ។ បណ្ដាសុខទាំងពីរប្រការនេះ សុខដែលជានិរាមិស លោកពោលថា កើតមកអំពីសន្តិសេចក្ដីស្ងប់ ជាសុខយ៉ាងឯកមិនមានសុខដទៃប្រៀបផ្ទឹមបាន ។

បណ្ដាសុខទាំង ២ ប្រការនេះ អាមិសសុខក៏ជាសុខដូចគ្នាដែរ តែនៅប្រឡំដោយទុក្ខ បានសេចក្ដីថា គ្រាដែលបានសុខក៏ជាសុខយ៉ាងលើសលុប តែដល់គ្រាអស់សុខហើយក៏ដល់ទុក្ខភ្លាមជាគ្នា ដូចបុគ្គលអ្នកស្ដុកស្ដម្ភដោយទ្រព្យសម្បត្តិ តែកាលបើមិនមានសេចក្ដីស្ងប់ស្ងាប់នឹងបានឈ្មោះថាជាអ្នកមានសុខយ៉ាងសម្បូរឬទេ ? មនុស្សដែលមានគ្រឿងបរិភោគតែល្មមគ្រប់គ្រាន់ប៉ុណ្ណោះ តែកាលបើមានសេចក្ដីស្ងប់ស្ងាប់នឹងបានឈ្មោះថាជាអ្នកមានទុក្ខឬទេ? អ្នកប្រាជ្ញទាំងឡាយបានពិចារណាឃើញដោយពិតប្រាកដហើយថា ការមានលាភយ៉ាងក្រៃលែងអាចធ្វើឲ្យមនុស្សមានសេចក្ដីសុខតែម្យ៉ាងមិនបានទេ ការមិនមានលាភទៀតនឹងធ្វើមនុស្សអ្នកស្គាល់ខុសត្រូវ មានចិត្តស្មោះត្រង់ឲ្យសុទ្ធតែបានទុក្ខដោយប្រការទាំងពួងក៏ទេដែរ; កាលបើពិចារណាមើលបានដឹងដូច្នេះហើយ បុគ្គលមានសេចក្ដីសុខ គឺសុខដែលប្រឡំដោយទុក្ខ មិនមែនមានចិត្តស្ងប់ស្ងាប់ហើយ កេរ្តិ៍ឈ្មោះក្ដី ទ្រព្យសម្បត្តិក្ដី ដែលត្រូវការនោះ ទោះបីនឹងមានយ៉ាងខ្ពង់ខ្ពស់ ជាកន្លែងកើតនៃសេចក្ដីសុខពិតៗ ក៏ដោយ

www.elibraryofcambodia.org

ក៏មិនអាចនឹងការពារទុក្ខភ័យដែលកើតឡើងក្នុងចិត្តនោះបាន, ហើយទាំងក្នុងវេលាដែលមានសេចក្ដីសុខនោះទៀត គេត្រូវធ្វើការងាររបស់លោកដែលមានការលំបាកច្រើនខ្វះតិចខ្វះទៅផងជាធម្មតា តែអំណាចវាសនាជាធំដែលមានអ្នកប្រាថ្នាទូទៅគ្រប់គ្នា ព្រោះអំណាចនឹងបណ្ដាលឲ្យទៅជាយ៉ាងណាៗ ក៏បានតាមប្រាថ្នា ដ្បិតថាអំណាចជាធំក្នុងលោក ដូចភាសិតក្នុងសគាថវគ្គសំយុត្តនិកាយថា "វសោ ឥស្សរិយំ លោកេ, អំណាចជាធំក្នុងលោក" ដូច្នេះ ៗ ទោះយ៉ាងណាក៏ដោយ អំណាច(១)ជាធំនោះ អាចបណ្ដាលឲ្យកើតសេចក្ដីសុខបានជាអនេកប្បការដោយអាការដូចគ្នា តែក្នុងមានវេលាដែល[illegible] បើវិនាសសាបសូន្យហើយ សេចក្ដីសុខក៏ត្រូវក្លាយជាទុក្ខវិញ ៗ តែទាំងឡាយក្នុងលោកជាអនិច្ចំ មានការប្រែប្រួលទៅតាមសភាពរបស់លោក ព្រោះលោកមិនមានសន្តិសេចក្ដីស្ងប់ លោកត្រូវនៅឃ្លាតឆ្ងាយពីនិរាមិសសុខ ជាសុខប្រាសចាកទុយប្រាសចាកទុក្ខ ជាសុខយ៉ាងហ្មត់ចត់ ដែលហៅថាសន្តិសេចក្ដីស្ងប់ជាកំពូលនៃសេចក្ដីសុខដទៃៗ យ៉ាងក្រៃលែង ៗ

www.elibraryofcambodia.org

សន្តិជាកន្លែងកើតនៃសេចក្ដីសុខយ៉ាងត្រជាក់ត្រជំ, បុគ្គលមានទ្រព្យ

---

១ ពាក្យថា "អំណាច" ជាពាក្យកណ្ដាល ៗ បែកចេញដោយខ្លួនមាន ២ ប្រការគឺ អំណាចពាល ១ អំណាចបណ្ឌិត ១ ឬអំណាចកិលេស ១ អំណាចបរិសុទ្ធិ ១ ។ អំណាចពាលឬអំណាចកិលេសមិនចាត់ចូលក្នុងសុភាសិតនេះទេ, អំណាចបណ្ឌិតឬអំណាចបរិសុទ្ធិ ទើបចាត់ចូលក្នុងសុភាសិតនេះបាន ។

សម្បត្តិ មានអំណាចវាសនាបរិបូណ៌ហើយ ក៏នៅតែមិនបានសេចក្ដីសុខដោយពិតប្រាកដ, អ្នកមានសេចក្ដីស្ងប់កាយខ្លះ ស្ងប់ចិត្តខ្លះ ក៏ឈ្មោះថាបានទទួលអាមិសសុខ គឺសុខដែលប្រឡំដោយទុក្ខប៉ុណ្ណោះ, ចំណែកសន្តិសុខ ជាសុខដែលកើតអំពីសេចក្ដីស្ងប់ផ្លូវចិត្ត គឺចិត្តប្រាសចាកកិលេសដែលនឹងធ្វើចិត្តឲ្យសៅហ្មង ចិត្តបរិសុទ្ធផូរផង់ ប្រាសចាកកិលេសទាំងពួង ហៅថានិព្វានសុខ, សន្តិសុខក្នុងទីនេះបានដល់និព្វានសុខនោះឯង ។ សន្តិសុខជាសុខដែលមិនមានថ្ងៃប្រែប្រួលផ្លាស់ប្ដូរ មិនមានការជាប់ជំពាក់នឹងលោក ត្រូវមានកាយនឹងចិត្តគេចចេញឲ្យផុតចាកការឆាររបស់លោក ស្ងប់នឹងនួនមិនប្រែប្រួល ៗ ព្រោះហេតុនោះ ទើបលោកពោលថាសេចក្ដីសុខដទៃក្រៅពីសន្តិសុខមិនមាន ហេតុនោះ ទើបសមនឹងសុភាសិតខាងដើមថា "នត្ថិ សន្តិបរំ សុខំ, សេចក្ដីសុខដទៃក្រៅពីសេចក្ដីស្ងប់មិនមានឡើយ" ដូច្នេះឯង ។

www.elibraryofcambodia.org

## ២១. មិត្ត

មាតា មិត្តំ សកេ ឃរេ

មាតា ជាមិត្រ ក្នុងផ្ទះរបស់ខ្លួន

ពាក្យថា មាតា បើមិនអធិប្បាយ ក៏គង់ដឹងបានទូទៅគ្រប់គ្នា, សេចក្ដីថាអ្នកណាដែលមាតាបង្កើតមក អ្នកនោះទុកមាតាថាជាមិត្រយ៉ាងជិតស្និទ្ធរបស់ខ្លួន គឺមាតារបស់អ្នកណាក៏ជាមិត្ររបស់អ្នកនោះដែលមិនមែន

ជាសត្រូវដល់ខ្លួនសោះឡើយ ។

អ្នកដែលមានការងារ ឬតំណើរត្រូវគ្នានឹងខ្លួន ហៅថាសម្លាញ់ ។ នេះគេលបានរួមសុខរួមទុក្ខជាមួយគ្នា អាចជួយគ្នាការពារបំបាត់អន្តរាយដែលកើតឡើងហើយ ឬដែលប្រុងនឹងកើតឡើងឲ្យវិនាសបាត់ទៅ, ទាំងជាអ្នកមានសេចក្តីគប់រកគ្នា ដោយទឹកចិត្តដ៏សុចរិត ប្រាសចាកពុតៈព្រមទាំងមានសេចក្តីស្និទ្ធស្នាលគួរទុកចិត្តគ្នាបាន ឬមានមេត្រីរាប់អានយ៉ាងស្មោះចំពោះគ្នា ហៅថាមិត្រ ។ តែមិត្តក្នុងទីនេះលោកចែកចេញជា ២ ប្រការគឺ មិត្តប្បដិរូប មិត្រប្លមមិនមែនជាមិត្រពិតប្រាកដ ១ ឧបការមិត្ត មិត្រមានឧបការៈ ១ ។ មិត្តប្បដិរូប គឺមនុស្សប្លមមិត្រ ឬ បន្លំធ្វើជាមិត្រមានលក្ខណៈគួរឲ្យសង្កេតបាន ដូចមនុស្សឃើញតែខាងបានអំពីគេ, មនុស្សល្អតែមាត់, មនុស្សប្រចុប, មនុស្សដឹកនាំក្នុងផ្លូវវិនាស ឬ នឹងហៅថាបាបមិត្រ គឺមិត្រអាក្រក់ក៏បាន ព្រោះបាបមិត្រតែងពន្យល់ឲ្យប្រកបកិច្ចដែលមិនគួរប្រកប, តែងដឹកនាំឲ្យធ្វើអំពើអាក្រក់ដោយផ្លូវកាយផ្លូវវាចា, ដឹកនាំឲ្យមានគំនិតអាក្រក់ដែលជាអំពើនាំឲ្យវិនាសខ្លួននឹងទ្រព្យសម្បត្តិ ជាហេតុឲ្យបានទុក្ខលំបាកក្នុងលោកនេះ ព្រមទាំងដឹកនាំឲ្យវិនាសប្រយោជន៍ក្នុងបរលោក គឺណែនាំមិនឲ្យមានសទ្ធាជ្រះថ្លាក្នុងព្រះរតនត្រ័យ, មិនឲ្យសមាទានរក្សាសីល, មិនឲ្យបរិច្ចាគទាន, មិនឲ្យរៀនសូត្រចំណេះវិជ្ជាសិល្បសាស្ត្រដែលគួរសិក្សាឡើយ ។ ព្រោះហេតុ

www.elibraryofcambodia.org

នោះ សាធុជនទាំងឡាយមិនគួរសេពគប់នឹងមិត្តដូច្នោះទេ គួរគេចវេះចៀសវាងជាកម្មិត្តបដិរូប ឬបាបមិត្តឱ្យឆ្ងាយ ព្រោះជាសត្រូវបំផ្លាញគុណសេចក្ដីល្អរបស់មនុស្សទូទៅ ។ ឧបការមិត្ត មិត្តមានឧបការៈ ឬជាមិត្តពិតប្រាកដ មានលក្ខណៈគួរឱ្យសង្កេតបានគឺ ការពារមិត្តដែលប្រហែសហើយ ការពារទ្រព្យរបស់មិត្តដែលប្រហែសហើយ, កាលមានភ័យយកជាទីពឹងបាន, កាលមានធុរៈកើតឡើងជួយចេញទ្រព្យលើសជាងមិត្តនិយាយខ្ទី ឬនឹងហៅថាកល្យាណមិត្តក៏បាន ព្រោះកល្យាណមិត្ត គឺមិត្តដែលបណ្ឌិតគួរពប់រក តែងពន្យល់បុគ្គលដែលចូលមកសេពគប់ឱ្យ[illegible] ដឹកនាំឱ្យធ្វើអំពើកុសលដែលជាកិច្ចត្រូវបានអំណោយផលជាសុខ, ដឹកនាំឱ្យរៀនសូត្រវិជ្ជាសិល្បសាស្ត្រគន្លងលោកនិងធម៌ ដើម្បីឱ្យពួកជនដែលចូលមកសមាគមផងមានសេចក្ដីចំរើន ដោយសិរីសួស្ដីក្នុងលោកនេះនិងបរលោក ។ មិត្តបែបនេះហៅថាឧបការមិត្ត ឬកល្យាណមិត្ត ដែលជាមិត្តពិតប្រាកដ ។ សាធុជនទាំងឡាយ គួរចូលទៅសេពគប់ដើម្បីមាឱ្យនចំណេះវិជ្ជាសិល្បសាស្ត្រផ្សេងៗ ឬដើម្បីឱ្យបានសម្រេចមគ្គផលណាមួយ ។

ប្រយោជន៍នៃការសេពគប់មិត្តនោះ មានជាអនេកប្បការ ព្រោះមនុស្សយើងដែលតាំងនៅជាពួកៗ ជាក្រុមៗ រាប់តាំងពីផ្ទះមួយ រហូតដល់ស្រុកមួយ ប្រទេសមួយ, ត្រូវតែពឹងពាក់ពីនាក់អាស្រ័យគ្នា ជួយ

www.elibraryofcambodia.org

គ្នាក្នុងកិច្ចការផ្សេងៗច្រើនខ្លះតិចខ្លះ ទីងចំធ្វើតែម្នាក់ឯងតាមទំនើងខ្លួន ឥតមានមិត្រសម្លាញ់ជួយជាកម្លាំងផងមិនបានទេ ។ ពិតណាស់, កិច្ចការណាៗ ដែលហួសវិស័យលើសកម្លាំង ហួសអំណាច ដែលបុគ្គលម្នាក់ៗមិនអាចទីងធ្វើឲ្យសម្រេចទាន់កាលវេលាបាន, កិច្ចការនោះៗ ទីងសម្រេចរៀបរយសមតាមបំណងឡើងបាន ក៏ព្រោះមានគ្នីគ្នាដែលជាកល្យាណមិត្រជួយគិតជួយធ្វើផង ។ ដោយហេតុនេះ ទើបសមតាមភាសិតក្នុងសគាថវគ្គសំយុត្តនិកាយថា "សហាយោ អត្ថជាតស្ស ហោតិ មិត្តំ បុនប្បុនំ, សម្លាញ់ជាមិត្ររបស់អ្នកដែលមានកិច្ចធុរៈកើតឡើងរឿយៗ" ដើម្បីបញ្ជាក់ឲ្យឃើញថាមិត្រសម្លាញ់ ជាបច្ច័យដ៏សំខាន់យ៉ាងក្រៃលែង ដែលមនុស្សគ្រប់គ្នាត្រូវតែមានខានពុំបាន ។

www.elibraryofcambodia.org

មនុស្សខាងក្រៅជាមិត្រសម្លាញ់ អាចអំណោយប្រយោជន៍ដូច្នេះហើយ ឯមនុស្សយ៉ាងជិតស្និទ្ធបំផុតគឺមាតារបស់ខ្លួននោះ អ្នកប្រាជ្ញលោកចាត់ថាជាមិត្រយ៉ាងសំខាន់ណាស់ទៅទៀត ព្រោះជាអ្នកមានឧបការៈគុណដល់បុត្តធីតា ព្រមទាំងធ្វើរបស់ដែលជនដទៃនៅក្នុងផ្ទះរបស់ខ្លួនកម្រទីងធ្វើបាន ។ មែនពិត! ជនទាំងឡាយក្នុងផ្ទះរបស់ខ្លួនមានកូនទីងប្រពន្ធជាដើម កាលបើខ្លួនមានរោគបៀតបៀន រមែងខ្ពើមរអើមឬនឿយណាយ ក្នុងការព្យាបាលរក្សារោគ, ចំណែកមាតារមែងសំគាល់លាមកកូនរបស់ខ្លួន ថាហាក់ដូចជាផ្កាមិនខ្ពើមរអើមស៊ូរងលំបាកជាមួយនឹងកូន,

ហេតុនេះឯងទើបលោកចាត់មាតាបិតាជាមិត្រក្នុងផ្ទះរបស់ខ្លួន ៗ មួយទៀត, ពាក្យថាមិត្រ ៗ នេះកុំគប្បីយល់ចិត្តថាហៅបានចំពោះតែមាតានិងមនុស្សដទៃដែលមានសេចក្តីរាប់អានគ្នាប៉ុណ្ណោះឡើយ, សូម្បីបិតាក៏ហៅថាមិត្របានដែរ ព្រោះមាតានិងបិតាទាំងពីរនាក់នេះ រមែងប្រកបដោយមិត្តធម៌ គឺធម៌ដែលកល្យាណមិត្តគប្បីប្រព្រឹត្ត ៤ ប្រការស្មើគ្នាទាំងពីរនាក់ គឺ មានឧបការៈ ១ រួមសុខរួមទុក្ខ ១ ណែនាំប្រយោជន៍ឲ្យ ១ មានសេចក្តីស្រឡាញ់ ១; មិត្តធម៌ ៤ ប្រការនេះមាតាបិតាតែងបង្អោនទៅចំពោះបុត្ត-ធីតា ដោយពេញបរិបូណ៌មិនខ្វះខាត; មិនតែប៉ុណ្ណោះ លោកក៏មានមេត្តាករុណាចំពោះបុត្តធីតាដោយក្រៃលែង លោកប្រាថ្នាសេចក្តីសុខសេចក្តីល្អដ៏លើសលុបដល់បុត្តធីតា, កាលបុត្តធីតាបានទទួលទុក្ខសូម្បីបន្តិចបន្តួច លោកក៏មានចិត្តញាប់ញ័រជានិច្ច បើប្រសិនជាអាចនឹងផ្លាស់ប្តូរទុក្ខរបស់បុត្តធីតាមកទទួលរងខ្លួនឯងបាន លោកក៏ទទួលមួយរំពេចឥតរួញរា សូម្បីឲ្យតែបុត្តធីតាបានសេចក្តីសុខស្រួលបុះ ៗ បំណែកបុត្តធីតារមែងមានសេចក្តីសង្ឃឹមកក់ក្តៅទុកចិត្តជាច្រើន ក្នុងពេលដែលខ្លួនមានមាតាបិតានៅគ្រប់គ្រងបីបាច់ថែរក្សា ព្រោះហេតុនោះ សាធុជនទាំងឡាយ គួរគោរពប្រតិបត្តិកោតក្រែងបូជាចំពោះមាតាបិតាដែលចាត់ជាជាមិត្រដ៏ប្រសើរ ជាទេពតាដំបូងបំផុតមានឧបការគុណដ៏លើសលុបដល់ខ្លួនកុំបីធ្វេសប្រហែសឡើយ ទើបសួស្តីនឹងកើតមានដល់ខ្លួន ទាំងក្នុង

www.elibraryofcambodia.org

ផងលោកនិងបរលោក មិនឃៀនឃ្លាត ។ មាតាបិតាប្រកបដោយព្រហ្មវិហារធម៌មានមេត្តាជាដើម ដែលប្រព្រឹត្តឆ្ពោះទៅរកបុត្តធីតាពល់វេលាយ៉ាងនេះឯងទើបសមនឹងពុទ្ធភាសិតខាងដើមថា "មាតា មិត្តំ សកេ ឃរេ, មាតាជាមិត្រក្នុងផ្ទះរបស់ខ្លួន" ដូច្នេះឯង ។

## ២២. វិមុត្តិ

### អនុត្តរា វិមុត្តិ

ពួកសាធុជនតែងផុតស្រឡះ ព្រោះសេចក្ដីមិនប្រកាន់មាំ

សាធុជន គឺមនុស្សល្អ ធម្មតាមនុស្សល្អទាំងឡាយរមែងមិនមានការប្រកាន់មាំ រមែងផុតស្រឡះចាកអាការជាប់ជំពាក់នឹងវត្ថុគ្រប់យ៉ាង

www.elibraryofcambodia.org

ព្រោះអស់សេចក្ដីប្រកាន់មាំ ក៏ឈ្មោះថាអស់កងទុក្ខទាំងឡាយ, បើនិយាយយ៉ាងខ្ពស់បានដល់ព្រះអរហន្តខីណាស្រព ។

កងទុក្ខទាំងឡាយ កាលបើពោលដោយសង្ខេបបានដល់បញ្ចុបាទានក្ខន្ធ គឺការចូលទៅប្រកាន់មាំចំពោះខន្ធ ៥ គឺ រូប វេទនា សញ្ញា សង្ខារ និងវិញ្ញាណ ប្រកាន់ថារូបរបស់អាត្មាអញ, វេទនា, សញ្ញា, សង្ខារ, វិញ្ញាណរបស់អាត្មាអញ; ប្រកាន់ខន្ធទាំង ៥ នេះថាជាខ្លួនប្រាណ ជាសត្វ ជាបុគ្គល ជាយើង ជាគេ យ៉ាងពិតប្រាកដ ។ តែតាមការពិត ខន្ធ ៥ នោះ ជាអនត្តា គឺសភាពជារបស់មិនមែនខ្លួនទេ ដោយសភាពប្រព្រឹត្តទៅតាមហេតុបច្ច័យ ដោយមិននៅក្នុងអំណាច

បង្គាប់បញ្ជារបស់អ្នកណា, អ្នកណាប្រាប់ថាកុំចាស់កុំឈឺកុំស្លាប់ដូច្នេះ ក៏មិនជឿស្តាប់ទេ រមែងប្រព្រឹត្តទៅតាមសភាពធម្មតា ៗ កាលណាបើបុគ្គលប្រកាន់មាំថាជាខ្លួនប្រាណជាយើងជាគេហើយក៏ជាហេតុឲ្យកើតទុក្ខ ព្រោះប្រែប្រួលមិនឋិតថេរ ដូចរូបធ្លាប់តែស្រស់បស់ក៏ត្រឡប់ក្លាយជាជរាភាព, វេទនាដែលធ្លាប់តែសុខក៏ត្រឡប់ប្រែប្រួលជាទុក្ខ រហូតដល់សញ្ញាសង្ខារ វិញ្ញាណក៏ប្រែប្រួលទៅមិនឋិតថេរនៅដូចគ្នា ៗ បុគ្គលដែលប្រកាន់មាំយ៉ាងនោះ ក៏បានទទួលវិប្បដិសារៈសេចក្តីក្តៅក្រហាយមានសោកៈ បរិទេវៈជាដើម ៗ ធម្មតាវត្ថុទាំងឡាយ កាលកើតឡើងហើយក៏រលត់ទៅតាមសភាពធម្មតា មិនមានរបស់ណាទីងឋិតថេរជាវរៈនៅបាន សមតាមន័យភាសិតក្នុងមហាវគ្គសំយុត្តនិកាយថា “យំកិញ្ចិ សមុទយធម្មំ សព្វន្តំ និរោធធម្មំ, វត្ថុណាមួយ មានការកើតឡើងជាធម្មតា, វត្ថុនោះសុទ្ធតែមានសេចក្តីរលត់ទៅជាធម្មតា” ដូច្នេះ ៗ នេះជាគតិធម៌ដែលនឹងគេចវេះបៀសវាងឲ្យផុតមិនបាន ត្រូវជាប់នៅក្នុងគតិនៃធម្មតាជានិច្ច, បើនៅមានឧបាទានប្រកាន់មាំទើបមិនអាចផុតស្រឡះចាកទុក្ខទៅបានឡើយ ៗ

ឯពួកសាធុជនគឺមនុស្សល្អ បើនិយាយយ៉ាងខ្ពស់ គឺព្រះអរហន្តដ៏ណាស្រេចលោកអស់កិលេសាសវៈ រមែងផុតស្រឡះចាកទុក្ខគឺកិ-លេសទាំងពួង ព្រោះលោកអស់ឧបាទានសេចក្តីប្រកាន់មាំ អស់សេចក្តី

www.elibraryofcambodia.org

ប្រកាន់បំពោះខន្ធធាតុ អាយតនៈតទៅទៀតរហូតដល់វត្ថុគ្រប់យ៉ាង ឃើញពិតតាមសភាពដើម, ធាតុ អាយតនៈ ក៏ប្រព្រឹត្តទៅតាមធាតុ អាយតនៈ, លោកមិនប្រកាន់ថាជាដុំជាកំភួន ប្រកាន់ជាចំណែករាយរងៗមកប្រកបគ្នាឡើង ហើយក៏រលាយបាត់ទៅ មិនទោមនស្សមិនសោមនស្ស ឃើញសុទ្ធតែជាធាតុទាំង៤, ចំណែករឹងៗជាដី, ចំណែករាវៗជាទឹក, ចំណែកក្តៅៗជាភ្លើង, ចំណែករបក់ទៅបក់មកជាខ្យល់ សុទ្ធតែជាធាតុទាំង ៤ មិនមែនជារបស់អ្នកណា គឺជារបស់កណ្តាលៗដោយពិតប្រាកដ ។

ពួកសាធុជនលោកពិចារណាឃើញជាធម្មតាយ៉ាងនេះហើយ លោកក៏ផុតទុក្ខផុតកិលេសជាសមុច្ឆេទប្បហាន ព្រោះការមិនប្រកាន់មាំដែលជាឧបាទានឲ្យកើតទុក្ខ ។ ព្រោះហេតុនោះ លោកទើបបានសម្រេចសុខដ៏ធំទូលាយ ដោយការផុតស្រឡះចាកទុក្ខព្រោះមិនមានឧបាទាន ទើបសមនឹងសុភាសិតខាងដើមថា "អនុបាទា វិមុច្ចន្តិ, ពួកសាធុជនតែងផុតស្រឡះព្រោះសេចក្តីមិនប្រកាន់មាំ" ដូច្នេះឯង ។

www.elibraryofcambodia.org

*

* *

(ដោយមានធនធានស្តួចស្តើងក្នុងការបោះពុម្ពផ្សាយ,
សូមស្ទះអធិប្បាយសុភាសិតនាំគួរដោយសង្ខេបត្រឹមប៉ុណ្ណេះ)

www.elibraryofcambodia.org

www.elibraryofcambodia.org

www.elibraryofcambodia.org